00832127



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 07-Aug-2012, 15:17
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី៩០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

លោក ដាវ អានសាន

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្មី

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្ដម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក វ៉េន ពៅ

លោកស្រី ជេត វណ្ណលី

លោក ឡៃ ជុនធី

លោកស្រី ម៉ារី ហ្គីរ៉ូដ
*(Ms. Marie GUIRAUD)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក សួង ស៊ីគឿន (TCW-694) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សួង ស៊ីគឿន ហៅ គង់ ឬ ធន** (TCW-694)

សួរបន្តដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្ដើមពី៖ .............................................ទំព័រ ៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:២៧]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះនឹងបន្តការស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន ដែលនឹងតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអនុវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះបានកោះអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៥:៤៨]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន នៅក្នុងសវនាការនាព្រឹកនេះ នៅថ្ងៃចន្ទ ទី៦ ខែសីហា ឆ្នាំ២០១២ នេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែជនជាប់ចោទ អៀង សារី តែគាត់អវត្តមានពីបន្ទប់សវនាការ ប៉ុន្តែមានវត្តមាននៅបន្ទប់ខាងក្រោមសាលសវនាការ ដោយគាត់បានលះបង់សិទ្ធិចូលរួមដោយផ្ទាល់ -- លះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់តាមរយៈមេធាវីរបស់ខ្លួន។

លិខិតលះបង់សិទ្ធិនេះបានប្រគល់ជូនមកដល់ក្រឡាបញ្ជីរួចហើយ។ ក្រឡាបញ្ជីក៏កត់សម្គាល់ផងដែរថា មានវត្តមានលោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា *(Ferdinand Djammen-Nzepa)* ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ដោយគណៈមេធាវីនៃព្រះរាជអាជ្ញាចក្រកម្ពុជារួចហើយ។ ហើយដោយឡែកចំពោះសាក្សីបម្រុង ដែលមានរហស្សនាម TCW-490 បានមកដល់ អ.វ.ត.ក ហើយ និងកំពុងត្រូវបានរៀបចំសម្បថដោយក្រឡាបញ្ជីលោក ឌុច ផារី។ សូមអរគុណលោកប្រធាន។

[០៩:០៦:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចទៅលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី ជាមុនសិន។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការដោយនៅ -- សុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។

វេជ្ជបណ្ឌិត ឈា គន្ធាវី គ្រូពេទ្យទទួលពិនិត្យព្យាបាលថែមទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំងនៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះ ហើយបានកត់សម្គាល់ឃើញថាលោក អៀង សារី មានអាការៈហត់ខ្លាំង វិលមុខ ឈឺចង្កេះ ឈឺជើង ហើយបត់ជើងតូចញឹកញាប់ មិនអាចអង្គុយបានយូរ និងបានផ្តល់អនុសាសន៍ថាលោក អៀង សារី គួរតែត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់តាមដានកិច្ចដំណើរការសនាការពីចម្ងាយពីបន្ទប់មួយនៅខាងក្រោមសាលសវនាការនេះ។

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះលោក អៀង សារី មានបញ្ហាសុខភាព ហើយគាត់លះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្ដីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី សុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

[០៩:០៨:៤៤]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងអំឡុងពេលដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទ ជាកិច្ចបន្ត តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថានៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ មានវត្តមានមេធាវីអន្តរជាតិតំណាងដើមបណ្តឹង

រដ្ឋប្បវេណីមួយរូបគឺលោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា។ ហើយដើម្បីអនុវត្តអនុលោកមតាមវិធាន២២ អនុវិធាន(២) ចំណុច(ក) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គជំនុំជម្រះសូមអញ្ជើញលោក ពេជ អង្គ ដែលជាសហមេធាវីជាតិនៃមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីឡើងធ្វើការស្នើសុំទទួលស្គាល់មេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលមានវត្តមាននៅក្នុងបន្ទប់សវនាការនេះ។ ហើយមេធាវីរូបនេះមិនទាន់បាន ទទួលការទទួលស្គាល់ពីអង្គជំនុំជម្រះពីពេលមុនមក។ សូមអញ្ជើញ!

[០៩:០៩:៥៧]

**លោក ពេជ អង្គ៖**

សូមគោរពលោកធាន លោក លោកស្រីចៅក្រមអង្គសវនាការទាំងមូល ដើមបណ្ដឹងរដ្ឋប្បវេណី និងសាធារណជន។ នៅខាងឆ្វេងដៃខ្ញុំនេះ គឺលោកមេធាវី ហ្វែឌីណង់ ចាមិន ហ្សេប៉ា ជាមេធាវីដែលចុះឈ្មោះនៅការិយាល័យនៅទីក្រុង ទូលូស្ស នៃប្រទេសបារាំង។ លោកមេធាវីមានជនជាតិបារាំង -- ជាជនជាតិបារាំង។ លោកបានធ្វើសម្បថនៅចំពោះមុខសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជានៅទីក្រុងភ្នំពេញ នៅឆ្នាំ២០០៨ ហើយជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណី ០០២នេះ។ លោកជាសមាជិកនៃក្រុមមេធាវីគ្មានព្រំដែនបារាំង។

បាទ ដូច្នេះសូមលោកប្រធានមេត្តាទទួលស្គាល់លោកមេធាវី ហ្វែឌីណង់ ចាមិន ហ្សេប៉ា នេះដើម្បីឲ្យលោកមានសិទ្ធិនៅក្នុងការការពារផលប្រយោជន៍របស់ដើមបណ្ដឹងរបស់គាត់តាមផ្លូវច្បាប់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្វែឌីណង់ ចាមិន ហ្សេប៉ា អង្គជំនុំជម្រះទទួលស្គាល់លោកជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីសវនាការ -- នីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះនេះ។ ហើយអនុលោមតាមការទទួលស្គាល់នេះ លោកមានសិទ្ធិ និងបុព្វសិទ្ធិដូចគ្នានឹងមេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែរ។

[០៩:១១:៣៣]

បាទ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ជម្រាបសួរលោក សួង ស៊ីគឿន ខ្ញុំនឹងសួរសំណួរលោកសម្រាប់មួយថ្ងៃនេះពេញតែម្តង។ ដោយសារតែមានពេលខ្លីនោះ ខ្ញុំសូមឲ្យលោកឆ្លើយឲ្យបានច្បាស់ៗ ហើយចំពោះសំណួរដែលខ្ញុំនឹងចោទសួរ។

**សួរបន្តដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** មុននឹងចូលទៅដល់ចំណុចសំខាន់ពាក់ព័ន្ធទៅនឹងក្រសួងការបរទេស ខ្ញុំមានសំណួរបន្តមួយចំនួនទៅនឹងអ្វីដែលលោកបានឆ្លើយកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន។ លោកបាននិយាយអំពីទស្សនកិច្ចរបស់ ខៀវ សំផន, អៀង សារី ដែលគាត់បានចេញពីចិន ហើយបានទៅវៀតណាមខាងជើងនៅខែឧសភា ឆ្នាំ៧៤។ ហើយលោកក៏បានប្រាប់ថា លោកស្ថិតនៅក្នុងក្រុមនៃការធ្វើដំណើរនោះដែរ។ លោកបានបញ្ជាក់ថា ខៀវ សំផន, អៀង សារី បានទៅចូលតំបន់រំដោះពីវៀតណាមមក។ តើលោកដឹងទេថា អៀង សារី គាត់ស្ថិតនៅតំបន់រំដោះប៉ុន្មានដែរនៅពេលធ្វើដំណើរនោះ? លោក លោកនៅហាណូយ ហើយពួកគាត់បន្តទៅតំបន់រំដោះ។ តើលោកដឹងទេថា គាត់នៅរយៈពេលប៉ុន្មានដែរនៅតំបន់រំដោះនោះ?

[០៩:១៣:៣៧]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ជាដំបូង ខ្ញុំសូមគោរពលោកប្រធាន។ សូមគោរពបងៗ សូមគោរពអង្គសវនាការទាំងមូល។ សូមលោកព្រះរាជអាជ្ញាបញ្ជាក់ពីតំបន់រំដោះ ព្រោះកាលនុំងមានរំដោះពីរបីនោះ។ តើតំបន់រំដោះកម្ពុជា តំបន់រំដោះវៀតណាមខាងត្បូង តំបន់រំដោះលាវ -- ឡាវ?

**ស៖** លោកបាននិយាយអំពីដំណើរទស្សនកិច្ចដែលលោកបានចូលរួមជាមួយនឹង ខៀវ សំផន, អៀង សារី ពីចិនមកវៀតណាម ហើយលោកបានធ្វើទស្សនកិច្ចជាផ្លូវការនៅវៀតណាម នៅក្នុងតំបន់រំដោះឡាវ ហើយបន្ទាប់មកទៀតលោកនៅហាណូយ ដើម្បីធ្វើការនៅក្នុងស្ថានីយ៍វិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជា ហើយអៀង សារី, ខៀវ សំផន បានបន្តដំណើរទៅតំបន់រំដោះនៃកម្ពុជា។ ដូច្នេះខ្ញុំចង់ដឹងថា តើអៀង សារី ស្នាក់នៅតំបន់រំដោះនៅកម្ពុជារយៈពេលប៉ុន្មានដែរ តើលោកដឹងដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ បាទ។

[០៩:១៤:៥៨]

**ស៖** ចំណុចទីពីរ ដែលខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់នោះ គឺពេលដែលលោកត្រឡប់មក

ប្រទេសកម្ពុជា បន្ទាប់ពីបានធ្វើការនៅវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជាប្រចាំនៅទីក្រុងហាណូយ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេថា នៅពេលណាលោកចូលមកកម្ពុជា? ពីព្រោះថាចំណុចនេះដូចជាមានភាពផ្ទុយគ្នានៅក្នុងឯកសារជាច្រើនដែលយើងមាន។ ជាអាទិលោក កាលពីព្រហស្បតិ៍នោះលោកនិយាយថាចូលខែមេសា ឆ្នាំ៧៥។ តើមុនខែមេសា ៧៥ ឬក៏ក្រោយខែមេសា ៧៥ ដែលលោកចូលមកប្រទេសកម្ពុជានោះ?

**លោក ស្នួង ស៊ីគឿន៖**

លោកប្រធាន តើខ្ញុំមានសិទ្ធិមិននឹងឆ្លើយនឹងសំណួរដូចជាប់ទាក់ទងអីជាមួយនឹងអង្គហេតុនេះបាទ។

[០៩:១៥:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ ជា -- លោកមានកាតព្វកិច្ចឆ្លើយនឹងសំណួរ ពីព្រោះសំណួរហ្នឹងក៏មានការពាក់ព័ន្ធដែរ។ ដែលពាក់ព័ន្ធជាមួយនឹងរយៈកាលនៃប្រវត្តិសាស្ត្រនៃបក្សកុម្មុយនីស្តកម្ពុជា។

**លោក ស្នួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំថា ខ្ញុំមកដល់ភ្នំពេញនៅខែឧសភា។ ខ្ញុំថាប៉ុណ្ណឹងបាទ។ ខ្ញុំអាចឆ្លើយប៉ុណ្ណឹង។ ព្រោះដំណើរខ្ញុំចេញពីថ្ងៃណា១ គឺថាវាយូរបន្តិចហើយ ប៉ុន្តែគ្រាន់ដឹងថា ខ្ញុំមកដល់ភ្នំពេញនៅថ្ងៃ២៥ ខែឧសភា ឆ្នាំ១៩៧៥ បាទ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាងលេ៖**

**ស៖** សូមអរគុណលោសាក្សី។ តើលោកចាកចេញពីទីក្រុងហាណូយមុន ឬក៏ពេលដែលលោកស្រី អៀង ធីរិទ្ធ មកកម្ពុជា?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ គឺអាចគាត់ត្រឡប់មកវិញមុនខ្ញុំបន្តិច។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលមកនិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញវិញម្តង។ លោកបានបញ្ជាក់ថា លោកមកខែឧសភា ឆ្នាំ៧៥ ហើយលោកធ្វើការនៅមន្ទីរប-២០។ កាលពីថ្ងៃព្រហស្បតិ៍ ប្រហែលជានៅម៉ោង១៥:៤៤ គឺក្នុងពង្រាងនៃប្រតិចារឹកកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុននេះ លោកបានបញ្ជាក់អំពីមូលហេតុជាច្រើន ដើម្បីបញ្ជាក់អំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ជាពិសេស លោកបញ្ជាក់ថាមានការខ្លាចការទម្លាក់គ្រាប់បែករបស់អាមេរិក។ ទី២ គឺខ្លាច

គ្រោះទុរ្ភិក្ស។ ហើយមូលហេតុទី៣ ដែលលោកបានផ្តល់ជូននោះ ខ្ញុំសូមដកស្រង់៖ "គឺការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញមានគោលដៅ ដើម្បីបំបែក បណ្តាក់ខ្សែរយៈខ្លាំង"។ សូមបញ្ចប់ការដកស្រង់។

[០៩:១៨:២៧]

ខ្ញុំចង់ដឹងថា តើនៅក្នុងឱកាសអ្វីដែរ ដែលគេបញ្ជាក់ប្រាប់លោកអំពីមូលហេតុទាំងបី នៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះ? តើលោកចាំអំពីឆ្នាំ ទីកន្លែង ឬក៏កាលៈទេសៈដែលលោកបានដឹងអំពីមូលហេតុទាំងបីនេះដែរឬទេ?

**ឆ៖** ចំណុចទាំងបី ហ្នឹង មូលហេតុនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញហ្នឹង អានេះខ្ញុំសរុបខ្លឹមសារដែលគេ -- ពេលនោះគេបានប្រាប់ខ្ញុំដែរទេ មិនមែន មិនមានឯកសារណា ឬការឧទ្ទេសនាមពីថ្នាក់ដឹកនាំណាដែលប្រាប់ខ្ញុំមួយពីរបី ដូច្នេះទេបាទ។ ដូច្នេះ ខ្ញុំមិនបានចាំថាពេលណា នៅកន្លែងណា ដែលគេ -- ខ្ញុំដឹងពីមូលហេតុនេះទេបាទ។

**ស៖** អរគុណ។ តើពេលណាដែលគេប្រាប់លោកនោះ គឺនៅពេលដែលលោកនៅប-២០ ឬក៏ប-១ ទៅហើយ?

**ឆ៖** ខ្ញុំឆ្លើយអំមិញដូចជាច្បាស់ដែរ មិនដឹងជានៅកន្លែងណា នៅថ្ងៃណា។ មើល៍មកសួរបញ្ជាក់ទៀតយ៉ាងម៉េចហ្នឹង? ព្រោះខ្ញុំប៉ុន្មានឆ្នាំហើយ ហើយខួរក្បាលខ្ញុំចាំដែរ ប៉ុន្តែខ្ញុំមិនចាំ ហើយ ខ្ញុំជម្រាបលោកព្រះរាជអាជ្ញាថា ខ្ញុំសរុបចំណុចនេះ១, ២, ៣ តាមដែលខ្ញុំបានដឹងទេ មិនមានអីគេប្រាប់ខ្ញុំច្បាស់ទេ។

**ស៖** លោកសាក្សី គឺមាននរណាម្នាក់ប្រាប់លោក តើអ្នកណាដែលជាអ្នកប្រាប់លោកនោះ? តើលោកមាននៅចាំទេ?

**ឆ៖** ខ្ញុំបានបញ្ជាក់អំមិញថា ខ្ញុំអ្នកសរុបខ្លួនខ្ញុំ តាមដែលខ្ញុំឯកសារខ្ញុំឮជាតាមខ្ញុំយល់។ តាមមើលទៅគ្រាន់សរុបប៉ុណ្ណឹង ខ្ញុំដូចមិនជាទឹងមោងមិនដឹងខ្យល់អី សរុបប៉ុណ្ណឹងមិនបានអ្វី! ចាំបាច់អ្នកណាប្រាប់ខ្ញុំនោះ?

[០៩:២១:០៦]

**ប្រធានអង្គជំនុំ៖**

លោកសាក្សី ទី១ លោកត្រូវស្គាល់អំពីកាតព្វកិច្ចរបស់លោក យើងបានជម្រាបលោករួចហើយ

កាលពីថ្ងៃព្រហស្បតិ៍ មុននឹងចាប់ផ្ដើមតាំងសំណួរដេញដោល គឺលោកមានកាតព្វកិច្ចឆ្លើយតបទៅនឹងសំណួរដែលសួរ ហើយនូវអ្វីដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឆ្លងបទពិសោធន៍របស់លោកដែលបានជួបប្រទះ ហើយនិងឬក៏លោកបានធ្វើការកត់សម្គាល់។ ក្នុងនាមជាសាក្សី មិនគប្បីផ្ដល់សក្ខីកម្មជាការយល់ឃើញអត្តនោម័តិរបស់ខ្លួនឡើយ។ សំណួរដែលជាក់ច្បាស់ ប្រសិនបើលោកដឹង គឺលោកអាចឆ្លើយថាដឹង ថាចាំ ហើយនិយាយតាមព្រឹត្តិហេតុដែលលោកបានចងចាំតបទៅនឹងសំណួរដែលសួរ ដែលពាក់ព័ន្ធ។ បើលោកមិនចងចាំទេ គឺឆ្លើយថាមិនចាំ ជាការចប់ហើយ។ ចៀសវាងលោកការធ្វើសេចក្ដីសន្និដ្ឋាន ឬផ្ដល់ការយល់នូវគំនិតផ្ទាល់ខ្លួន។

ការយល់ និងមតិយោបល់ដែលបង្ហាញពីការយល់ដឹងផ្ទាល់ខ្លួន លុះត្រាតែគេអ្នកជំនាញទើបចូលរួមនៅក្នុងនីតិវិធីដោយផ្ដល់នូវការពិចារណា នូវការយល់ដឹងរបស់ខ្លួនតាមវិជ្ជាខ្ពង់ខ្ពស់ ដែលមាន តាមវិជ្ជាជីវៈដែលជំនាញនីមួយៗ។ ទី២ គឺសូមឲ្យលោកស្ដាប់សំណួរឲ្យបាន ហើយឆ្លើយតបទៅនឹងក្របខ័ណ្ឌនៃសំណួរដែលបានសួរ។ ប្រសិនបើសួរត្រូវទាមទារឲ្យឆ្លើយខ្លីទេ គឺអាចឆ្លើយខ្លីតបនឹងសំណួរ លើកលែងតែសំណួរដែលសុំឲ្យលោកធ្វើការអត្ថាធិប្បាយ ឬក៏ធ្វើការរៀបរាប់ចំណុចណាមួយដែលពាក់ព័ន្ធទៅនឹងសំណួរ ទើបលោកអាចនិយាយវែងបាន។

[០៩:២៣:០៣]

ម្យ៉ាងទៀត អង្គជំនុំជម្រះសូមរំឭកលោកថា លោកត្រូវឈមនឹងការតាំងសំណួររាប់រយសំណួរឯណោះ ក្នុងរយៈពេលបួនថ្ងៃទៅមុខទៀតនេះ។ អ៊ីចឹងគឺគប្បីសន្សំនូវកម្លាំងពលំរបស់លោក ដើម្បីបំពេញភារកិច្ចជាសាក្សីហ្នឹងឲ្យចប់ចុងចប់ដើម។ អ៊ីចឹងទាល់តែលោកផ្ចង់ៗអារម្មណ៍ ផ្ចង់ការពិចារណាតាមសមត្ថភាពរបស់លោកដែលអាចចាំបាន គឺស្ដាប់សំណួរឲ្យបាន ហើយឆ្លើយតប។ ក្នុងករណីស្ដាប់មិនបានទេ គឺលោកធ្វើដូចមុនអ៊ីចឹង សូមឲ្យអ្នកតាំងសំណួរហ្នឹងគឺតាំងសំណួរសាជាថ្មីម្ដងទៀត ដោយធ្វើផ្ទាល់ក៏បាន ហើយធ្វើតាមរយៈយើងក៏បានដែរ ដើម្បីឲ្យដំណើរការច្បាស់។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងព្យាយាមសួរសំណួរចុងក្រោយអម្បាញ់មិញនេះឡើងវិញ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** តើអ្នកណាឲ្យប្រាកដ ដែលនិយាយប្រាប់លោកថា ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនោះ មានគោលដៅបំបែកខ្សែរយៈគិញរបស់ខ្មាំងនោះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** អត់មាននរណាប្រាប់ខ្ញុំទេបាទ គឺខ្ញុំឮតាមដូចថា គេនិយាយតាមវិទ្យុប៉ុណ្ណឹង។ ហើយខ្ញុំឆ្លៀតឱកាសនេះ អរគុណលោកប្រធានបានរំឭកខ្ញុំ។ ខ្ញុំយល់ច្បាស់ណាស់ អ្វីដែលខ្ញុំឆ្លើយ អ្វីដែលខ្ញុំត្រូវធ្វើ ដូច្នោះ ហើយសំខាន់គឺថា ខ្ញុំទើបនឹងបានដឹងថា ចំនួនរាប់រយ ដូច្នោះខ្ញុំសូមអរគុណ ព្រោះខ្ញុំតែឆ្លើយរបៀបដែលខ្ញុំធ្វើហ្នឹង ខ្ញុំនៅប្រហែលបាន ម៉ោងពីរមិនបានទេ។ សូមអរគុណបាទ។

[០៩:២៥:០០]

**ស៖** បើតាមការផ្សាយរបស់វិទ្យុនោះ ហើយបន្ទាប់មកលោកដឹង ហើយនិងអ្វីដែលបក្សប្រាប់លោក តើមានខ្សែរយៈគិញ ខ្លាំងនៅទីក្រុងភ្នំពេញច្រើនដែរឬទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ព្រោះខ្ញុំជាសកម្មជននៃបក្សកុម្មុយនីស្តកម្ពុជាក្នុងពេលនោះ។ ដូច្នោះ ដូចអស់លោកដឹងស្រាប់ហើយគឺថា ក្នុងសមាជិក -- ក្នុងឋានៈជាបក្ខជនមានភារកិច្ចច្បាស់លាស់។ យើងត្រូវដឹងអ្វីដែលយើងទទួលភារកិច្ចពីបក្ស ហើយធ្វើការងារហ្នឹងក្នុងក្របខ័ណ្ឌភារកិច្ចដែលយើងបានទទួល។ ដូច្នោះស្អីទៀត រឿងខ្លាំង រឿងស្អីក្រៅនេះ យើងមិនមានសមត្ថភាពដឹងទេ ហើយគឺយើងមិនត្រូវការដឹងដែរ ពីព្រោះមានអង្គភាពផ្សេងទៀតគេទទួលខុសត្រូវចំពោះបញ្ហានេះបាទ។

**ស៖** នៅក្នុងពេលដែលលោកជាបក្ខជនយ៉ាងយូរ តើគេនិយាយប្រាប់អំពីការតស៊ូវណ្ណៈដែរឬទេលោកសាក្សី?

**ឆ៖** តាមមើលទៅការតស៊ូវណ្ណៈហ្នឹង មិនមែនខ្ញុំដឹងពេលដែលខ្ញុំជាបក្ខជនរបស់បក្សកុម្មុយ-នីស្តកម្ពុជាទេ។ ការតស៊ូវណ្ណៈហ្នឹង គឺថាខ្ញុំដឹងដោយពេលដែលខ្ញុំអានសៀវភៅរបស់ កាល់ម៉ាក្ស នេះ គឺ *ម៉ាញ៉េហ្វេស ឌុយ ប៉ាកទី កុម្មុយនីស្ត* កាលពីឆ្នាំណាហ្នឹង។ ខ្ញុំដឹងរឿងហ្នឹងតាំងពីនុំងទេ តាំងពីពេលខ្ញុំនៅកម្ពុជាម្លេះមកបាទ។

[០៩:២៧:១១]

**ស៖** បើតាមបក្ស តើមានវណ្ណៈដែលជា -- ដែលមានទំនាស់ដែរឬទេ? ដែលមាន -- ខ្ញុំចង់សំដៅថាទំនាស់ធ្ងន់ធ្ងរនោះ?

**ឆ៖** ខ្ញុំសូមលោកប្រធានឲ្យលោកព្រះរាជអាជ្ញាទៅ ពីព្រោះថាទំនាស់ក្នុងភាសាកុម្មុយនីស្ត ក្នុងភាសាចលនាកុម្មុយនីស្តវាមាន ទំនាស់ហ្នឹងវាមានតាមរយៈកាលប្រវត្តិសាស្ត្ររបស់វា។ ប្រវត្តិសាស្ត្របដិវត្តន៍ប្រជាធិបតេយ្យ បដិវត្តន៍សង្គមនិយម ហ្នឹងវាមានដំណាក់ វាមានសភាពទំនាស់ហ្នឹងវាខុសៗគ្នា។

ដូច្នោះសូមបញ្ជាក់បាទ។

**ស៖** គឺខ្ញុំនិយាយអំពីពេលជម្លៀសប្រជាជនចេញទីក្រុងភ្នំពេញ។ តើលោកអាចបញ្ជាក់បានទេថាមានវណ្ណៈផ្សេងៗអ្វីខ្លះ? ហើយវណ្ណៈអ្វីដែលជាវណ្ណៈយុទ្ធសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជា ហើយបន្ទាប់មកសូមលោកនិយាយអំពីវណ្ណៈផ្សេងៗទៀត?

[០៩:២៨:៤៤]

**ឆ៖** ខ្ញុំសូមជម្រាបថា វណ្ណៈយុទ្ធសាស្ត្ររបស់ចលនាកុម្មុយនីស្ត មិនគ្រាន់តែបក្សកុម្មុយនីស្តកម្ពុជាទេ មែនទែនខ្មែរក្រហម បក្សកុម្មុយនីស្តកម្ពុជាកូនសិស្សគេតើ! កូនសិស្សនៅក្រោយទេទៀត បើយើងនិយាយទៅ យើងថាស្មើនឹងលាវ ឡាវ ចុះ។ កូនសិស្សគេតើ! ដូច្នោះទំនាស់ក្នុងបក្សកុម្មុយនីស្តហ្នឹងគឺថាវណ្ណៈជាមូលដ្ឋានហ្នឹង គឺថាវណ្ណៈ វាមានវណ្ណៈកម្មករជាវណ្ណៈដឹកនាំ។ នេះហើយដែលជាសារជាតិរបស់ចលនាកុម្មុយនីស្តកម្ពុជាបាទ។

**ស៖** សូមអរគុណ។ គឺលោកចង់និយាយថាមានវណ្ណៈកម្មករ អ៊ីចឹងតើមានវណ្ណៈផ្សេងទៀតទេក្រៅពីវណ្ណៈកម្មករនេះ? គឺថានៅក្នុងការតស៊ូវណ្ណៈហ្នឹង អាចមានវណ្ណៈផ្សេងទៀតដែរឬទេ? ហើយការតស៊ូហ្នឹង តស៊ូប្រឆាំងវណ្ណៈអ្វីខ្លះ?

[០៩:៣០:០៥]

**លោក សួង ស៊ីគឿន៖**

សូមលោកប្រធាន ឲ្យលោកព្រះរាជអាជ្ញាបញ្ជាក់ដូចខ្ញុំបាននិយាយដំណាក់កាល។ នេះនិយាយជារួមអ៊ីចឹងយើងពិបាកនឹងឆ្លើយឲ្យចំៗណាស់ ព្រោះវាដំណាក់កាលតស៊ូវាមានដំណាក់កាលរបស់វា។

**ប្រធានអង្គជំនុំ៖**

មានៗបញ្ហាបកប្រែភាសា!

**អ្នកបកប្រែ៖**

លោកប្រធាន ឥឡូវយើងអាចដំណើរការទៅវិញបានហើយ សូមអធ្យាស្រ័យ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញបន្តលោកតំណាងសហព្រះរាជអាជ្ញា! សូមលោកតំណាងសហព្រះរាជអាជ្ញារៀបចំសំណួរឲ្យបានងាយ ហើយជាក់ច្បាស់ទៅដើម្បីឲ្យ សម្រួលដល់ការដេញដោលឲ្យបានឆាប់រហ័ស។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សីនៅពេលដែលទីក្រុងភ្នំពេញត្រូវបានរំដោះបានហើយ ក្រោយមកមានការជម្លៀសប្រជាជនចេញ។ តើមានវណ្ណៈសង្គមប៉ុន្មាននៅក្នុងសង្គមខ្មែរបើតាមបក្ស -- ហើយសូមឱ្យលោករៀបរាប់លម្អិតអំពីវណ្ណៈសង្គមទាំងអស់នោះ? សូមផ្ដល់ឈ្មោះផង តើវណ្ណៈអ្វីខ្លះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** នៅពេលជម្លៀសចេញពីភ្នំពេញ ខ្ញុំឃើញ -- តាមខ្ញុំដឹងគឺគេជម្លៀសទាំងអស់។ ទាំងវណ្ណៈកសិករ វណ្ណៈកម្មករ វណ្ណៈអនុធន វណ្ណៈមូលធន វណ្ណៈនាយទុនអី ជម្លៀសចេញទាំងអស់បាទ។

[០៩:៣២:៣១]

**ស៖** លោកឆ្លើយទៅនឹងសំណួរមុន លោកមិនបានទៅនឹងសំណួរអម្បាញ់មិញនេះទេ។ ក្នុងចំណោមអ្នកជម្លៀស តើមាននាយទុន មានសក្តិភូមិ មានម្ចាស់ដី ឬក៏មានពួកគហបតីអីដែរឬទេ?

**ឆ៖** ខ្ញុំដូចជាបានឆ្លើយថា វណ្ណៈតែទាំងអស់ហ្នឹង បើមនុស្សជម្លៀសចេញទាំងអស់ពីភ្នំពេញបាទ។

**ស៖** ខ្ញុំនឹងបង្ហាញឯកសារមួយជូនលោកនាពេលមុននេះ ប៉ុន្តែមុននឹងចូលដល់ឯកសារ ខ្ញុំសួរសំណួរបឋមមួយចំនួន គឺពាក់ព័ន្ធទៅនឹងបុគ្គលម្នាក់ដែលគិតថាជាអ្នកសរសេរឯកសារនោះ។ តើលោកស្គាល់លោក ជួន ប្រាសិទ្ធ ដែរឬទេ? តើគាត់ធ្វើការនៅក្រសួងការបរទេសដែរឬទេ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បាទ ខ្ញុំស្គាល់លោក ជួន ប្រាសិទ្ធ ជាមិត្តភក្តិជិតស្និទ្ធរបស់ខ្ញុំ ហើយគាត់ធ្វើការនៅក្រសួងការបរទេសបាទ។

**ស៖** តើលោកអាចស្គាល់អក្សររបស់គាត់ដែរឬទេ ព្រោះថាលោកជាមិត្តជិតស្និទ្ធរបស់គាត់?

**ឆ៖** លោកប្រធាន សូមឲ្យព្រះរាជអាជ្ញាបញ្ជាក់ផង ព្រោះអក្សរវាមានបីទាន ថាពីរចុះ។ អក្សរខ្មែរ ហើយនិងអក្សរឡាតាំង។ ក្នុងឡាតាំងហ្នឹងមានបារាំង និងអង់គ្លេស។ ឲ្យសហព្រះរាជអាជ្ញាសូមបញ្ជាក់អក្សរផងបាទ។ បើតាមខ្ញុំចាំយល់ គាត់និយាយអំមិញជាអក្សរខ្មែរទេ ព្រោះយើងនៅលើទឹកដីខ្មែរ តើជាអក្សរខ្មែរ ឬយ៉ាងម៉េចបាទ?

[០៩:៣៤:៤៧]

**ស៖** បាទ ពិតហើយលោក គឺអក្សរខ្មែរ។

**ឆ៖** អាហ្នឹងអាស្រ័យលើឯកសារហ្នឹងទេ តាមខ្ញុំដឹងលោក ជួន ប្រាសិទ្ធ ដូចគាត់មិនសូវជាអ្នកសរសេរជាខ្មែរអីទេបាទ។

**ស៖** ទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតថា លោកអាចបញ្ជាក់ប្រាប់អំពីទិន្នន័យនៅក្នុងឯកសាររបស់ ជួន ប្រាសិទ្ធ នេះ គឺជារបស់ ជួន ប្រាសិទ្ធ ពិតមែន ព្រោះថាលោកជាមិត្តជិតស្និទ្ធរបស់គាត់។

[០៩:៣៥:៤២]

**លោក គង់ សំអុន៖**

សូមទោសលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

តាមរយៈអ្នកបកប្រែអំមិញ ខ្ញុំបានស្តាប់ឮថា សហព្រះរាជអាជ្ញាធ្វើការសន្និដ្ឋានថា សាក្សីជាអ្នក ថាអាចធ្វើការសន្និដ្ឋានទៅលើអក្សររបស់លោក ជួន ប្រាសិទ្ធ បាន។ បើសិនជា នេះជាសម្តីរបស់សហព្រះរាជអាជ្ញាមែន ខ្ញុំគិតថា មិនមែនជាសេចក្តីថ្លែងត្រឹមត្រូវទេ ហើយលោកអាចសួរបញ្ជាក់ដោយបង្ហាញអក្សរនោះឲ្យបានច្បាស់ ហើយមិនបាច់ធ្វើការសន្និដ្ឋានបែបនេះទេបាទ។ សូមអរគុណ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ប្រហែលជាខ្ញុំអាចសួរសំណួរឡើងវិញ។ លោកៗជាមិត្តជិតស្និទ្ធរបស់លោក ជួន ប្រាសិទ្ធ តើលោកអាចគិតថា លោកមានលទ្ធភាពក្នុងការស្គាល់នូវទិន្នន័យ ដែលកំណត់អត្តសញ្ញាណរបស់បុគ្គលដែលមាននៅក្នុងឯកសារនេះដែរឬទេ? ហើយគាត់ -- ដូចជាឧទាហរណ៍ដូចថា លោកអាចប្រាប់ថា គាត់មានឈ្មោះបដិវត្តន៍អ្វីខ្លះ? គាត់មានគ្រួសារដែរឬទេ? មានកូន ឬអីអ៊ីចឹងទៅ...។ល។

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំអាចធ្វើបាន ព្រោះខ្ញុំស្គាល់គាត់ច្បាស់ណាស់បាទ។ អក្សរខ្មែរ អក្សរឡាតាំង ជាអង់គ្លេស ជាបារាំងក៏ខ្ញុំអាចដែរ ប៉ុន្តែវាយូរបន្តិចហើយ ហើយទាល់ខ្ញុំឃើញឯកសារហ្នឹងបានខ្ញុំអាចសន្និដ្ឋានបាន។ ខ្ញុំមិនច្បាស់ដូចអ្នកខ្លះទេ ព្រោះអក្សរគាត់ ខ្ញុំដឹងថា បើថាអក្សរខ្មែរ អក្សរគាត់អត់ស្អាត

ទេ។ ខ្ញុំនិយាយ ដូចថាមិនស្អាត បើអ្នកខ្លះអក្សរគេស្អាត មើលទៅយើងចំណាំបានបាទ។

[០៩:៣៧:៤៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមបង្ហាញនូវឯកសារមួយ ដែលមានលេខ D366/7.1.831។ នេះគឺជាប្រវត្តិរូប ដែលសរសេរដោយលោក ជួន ប្រាសិទ្ធ ផ្ទាល់ នៅសម័យកម្ពុជាប្រជាធិបតេយ្យ ដែលចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៧៦។ ទំព័រដែលអាចបង្ហាញនេះគឺ ទំព័រដំបូង ដើម្បីបញ្ជាក់អត្តសញ្ញាណ នៃឯកសារនេះ បន្ទាប់មកគឺទំព័រទី១៩ ជាភាសាខ្មែរ ដែលមានលេខ ERN 0069554, ERN ជាភាសាបារាំង ទំព័រទី១៣ ដែលមានលេខ 00810048, ជាភាសាអង់គ្លេស ERN ទំព័រទី១២ 00082507។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីដាក់បង្ហាញឯកសារនេះ ជាភាសាខ្មែរជូនលោកសាក្សីរូបនេះ ដើម្បីគាត់ពិនិត្យមើល។ សូមលោកប្រធានអនុញ្ញាត។

[០៩:៣៩:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤១:២២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋតុលាការទទួលឯកសារជាក្រដាស ពីតំណាងសហព្រះរាជអាជ្ញា យកទៅជូនសាក្សីពិនិត្យ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី សូមលោកពិនិត្យមើលទំព័រ គឺទំព័រទី១ ដែលមានបញ្ជាក់អំពីឈ្មោះបដិវត្តន៍ និងប្រពន្ធរបស់គាត់ កូន ឬក៏បងប្អូនរបស់គាត់ជាដើម។ ហើយលោកអាចបញ្ជាក់ប្រាប់ខ្ញុំបានទេ ថាតើ បុគ្គលនេះហើយឬជា ជួន ប្រាសិទ្ធ មែនទេដែលលោកធ្វើការ -- ដែលលោកស្គាល់នៅក្រសួងការ បរទេស មន្ទីរប-១ នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! ចាំអង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់មេធាវីការពារក្តី លោក នួន ជា។ សូមអញ្ជើញលោកមេធាវី!

[០៩:៤២:៤៤]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់។ ខ្ញុំសូមជំទាស់វិធីសាស្ត្រសួរសំណួររបស់សហព្រះរាជអាជ្ញា។ ទី១ គាត់ប្រកាសថា គាត់នឹងនិយាយពីឯកសារមួយបន្ទាប់មួយ ហើយគាត់និយាយអំពីអ្នកដែលចងក្រងឯកសារ។ នេះហើយជាសំណួរមួយ គឺច្រើនទាក់ទងទៅនឹង ជួន ប្រាសិទ្ធ។ របៀបដែលគាត់សួរសំណួរពេលនេះ ទៅសួរសាក្សីនេះ គឺឲ្យសាក្សីបញ្ជាក់ថា តើនេះជាឯកសាររបស់ ជួន ប្រាសិទ្ធ ដែរឬទេ? ហើយគឺសហព្រះរាជអាជ្ញា មិនមានឱកាសនេះដើម្បីសួរឲ្យបញ្ជាក់ពីយថាភាពឯកសារនេះទេ ទាក់ទងពីទម្រង់ឯកសារ។ បាទ ហើយពីកម្រងនៃសំណួរ ដែលសហព្រះរាជអាជ្ញាបានសួរនេះ ខ្ញុំសូមជំទាស់បាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំមិនគិតថា ការសួរបែបនេះ ជាការនាំមុខទេ។ ខ្ញុំគ្រាន់តែសួរចង់ដឹង ឲ្យគាត់ផ្តល់អំពីអត្តសញ្ញាណរបស់បុគ្គលនេះ។ ហើយខ្ញុំចង់ថាតើអត្តសញ្ញាណនៅក្នុងឯកាសារនេះ វាពិតជាបុគ្គលដែលគាត់ស្គាល់នៅក្នុងមន្ទីរប-១ ហ្នឹងដែរឬទេ? នេះ គ្រាន់តែជាសំណួរធម្មតាទេ។

[០៩:៤៤:០៥]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា និងសំអាងហេតុ គឺត្រឹមត្រូវ។ ការចាប់ផ្តើមនៃសំណួរបែបនេះ គឺជាសំណួរនាំមុខហើយ។ បង្ហាញជាអ្នកពាក់ព័ន្ធឈ្មោះ អ្នកពាក់ព័ន្ធរួចទើបតាំងសំណួរជាក្រោយ ហើយដាក់ឯកសារជាក្រោយ ដើម្បីឲ្យសាក្សីពិនិត្យ។ លោកមេធាវី គប្បីធ្វើការផ្លាស់ប្តូរនូវទម្រង់នៃការបែបតាំងសំណួរបែបនេះ។ លោកតំណាងសហព្រះរាជអាជ្ញា! កែសម្រួលវិញ មិនមែនមេធាវីទេ គឺតំណាងសហព្រះរាជអាជ្ញា។

[០៩:៤៤:៥៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** លោកសាក្សី តើលោកអាចប្រាប់បានទេ អ្នកណាជាអ្នកសរសេរឯកសារនេះ? ហើយលោកស្គាល់ ស្គាល់អក្សររបស់គាត់ និងស្គាល់អត្តសញ្ញាណរបស់គាត់ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំពិនិត្យឃើញថា សហព្រះរាជអាជ្ញាសួរ ហើយគាត់រៀបឃ្លា ប៉ុន្តែសំណួរគឺនៅដដែល។ ទីមួយគាត់បានផ្តល់ព័ត៌មានទៅឲ្យសាក្សី ហើយគាត់នឹងសួរឲ្យសាក្សីឆ្លើយតាមថាតើ -- បាទ ពីមុនគាត់សួរថា ឯកសារហ្នឹងរបស់លោក ជួន ប្រាសិទ្ធ ឥឡូវនេះគាត់សួរថាតើអ្នកណា? អ៊ីចឹងគាត់សួរ តើគាត់ -- ថាតើគាត់ស្គាល់អក្សរដៃ ឬក៏អត្តសញ្ញាណអក្សរ ហើយនិងអត្តសញ្ញាណបុគ្គលហ្នឹងដែរឬទេ? ដូច្នេះជាសំណួរនាំមុខ ហើយប៉ុន្តែបើសួរបែបនេះគឺថាសួរម្យ៉ាងខាងដើមក៏នាំមុខ ហើយសួរបែបនេះក៏នាំមុខដែរបាទ។

[០៩:៤៦:១៨]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ជាធម្មតា គឺនៅក្នុងតុលាការនេះគឺយើងអាចសួរសំណួរមួយចំនួនដើម្បីឲ្យបញ្ជាក់ថា តើសាក្សីនេះគាត់អាចផ្តល់អត្តសញ្ញាណឯកសារបានដែរឬទេ? ដូច្នេះហើយខ្ញុំធ្វើការសួរគាត់ ដើម្បីឲ្យគាត់ដឹងថាតើគាត់ស្គាល់លោក ជួន ប្រាសិទ្ធ ដែរឬអត់? ដូច្នេះជាការត្រឹមត្រូវក្នុងការសួរគាត់ថាគាត់ស្គាល់ឯកសារនេះដែរឬទេ? ហើយឈ្មោះដែលមានចេញនៅក្នុងឯកសារនេះ គឺជារបស់គាត់ហ្នឹងហើយ។

**ប្រធានអង្គជំនុំ៖**

បានហើយ! សេចក្តីជំទាស់ និងការកត់សម្គាល់របស់មេធាវីការពារក្តីត្រឹមត្រូវ។ លោកមេធាវីអាចតាំងប្តូរសំណួរបន្តទៅសំណួរថ្មីទៀត ពីព្រោះលោកចាប់ផ្តើមដំបូង គឺលោកបង្ហាញនូវអញ្ញាណឯកសាររួចហើយ ទើបតាំងសំណួរដេញដោលចំពោះសាក្សី។ បានន័យដឹកមុខរួចហើយ ឯកសារហ្នឹង។ ជារបស់ សួង ស៊ីគឿន រួច -- អ៎!របស់ ជួន ប្រាសិទ្ធ រួចហើយ បានលោកតាំងសំណួរ ហើយដឹកនាំការសួរនោះ បានវានាំឲ្យមានបញ្ហា។

សូមលោកបន្តសំណួរថ្មីទៀតដែលមិនមានលក្ខណៈតាំងសំណួរបែបនាំមុខ។ ប្រសិនបើឯកសារនេះមិនពាក់ព័ន្ធ នៅតែគ្មានសំណួរដែលអាចតាំងសំណួរចៀសវាងពីការនាំមុខបានទេ សូមប្តូរទៅសំណួរពាក់ព័ន្ធនឹងឯកសារថ្មីទៀត។ នៅបញ្ហាច្រើនណាស់ ដែលមានការពាក់ព័ន្ធនឹងការតាំងសំណួរដេញដោល

ចំពោះសាក្សីនេះ។

[០៩:៤៨:០៥]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឲ្យសួរៗសាក្សីនេះ ថាតើគាត់ស្គាល់ឯកសារនេះដែរឬទេ? ឬមួយក៏ខ្ញុំត្រូវតែចូលទៅប្រធានបទមួយទៀតលោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ឯកសារនេះដោយសារលោកបានបង្ហាញនូវការសួរដឹកមុខតាំងពីដំបូងរួចហើយ។ អ៊ីចឹងសំណួរផ្សេងទៀតដែលពាក់ព័ន្ធនឹងឯកសារនេះ គឺចៀសវាងពីការសួរនាំមុខមិនបានទេ ពីព្រោះលោកបង្ហាញហើយថាឯកសារនេះជាឯកសាររបស់ សួង ស៊ីគឿន -- របស់ ជួន ប្រាសិទ្ធ រួចហើយ។ អ៊ីចឹងបានន័យថា ការដឹង ការគិតរបស់សាក្សីហ្នឹង គិតអ៊ីចឹងរួចទៅហើយ។ អ៊ីចឹងសំណួរផ្សេងទៀតក៏វានៅតែក្នុងនឹង -- ក្នុងប្រភេទសំណួរនាំមុខហ្នឹងដែរ។

[០៩:៤៩:៤២]

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា! ឯកសារអំមិញនេះ គឺលោកអាចបន្តតាំងសំណួរដេញដោលទៅលើខ្លឹមសារ ដែលលោកមានបំណងសួរបាន។

[០៩:៥០:០០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។

ខ្ញុំគ្រាន់តែចង់អានសម្រង់មួយចេញពីជីវប្រវត្តិនេះ ហើយយើងគិតថា នេះជាប្រវត្តិរូបរបស់លោក ជួន ប្រាសិទ្ធ ហើយ។ ដូចដែលខ្ញុំបានប្រាប់អម្បាញ់មិញនេះ គឺថាទំព័រទី១៣ ជាភាសាបារាំង។ ទំព័រ១៩ ជាភាសាខ្មែរ ហើយនិងទំព័រ១២ ជាភាសាអង់គ្លេស។ ខ្ញុំសូមអានឃ្លាមួយ ហើយសូមការឆ្លើយតបពីសាក្សីចំពោះឃ្លាមួយនេះ។ សម្រង់នេះចាប់ផ្ដើមដោយចំណងជើងលេខ២ "អំពីបដិវត្តន៍សង្គមនិយមនៅកម្ពុជា"។

ដូច្នេះលោកប្រធាន ខ្ញុំសូមអនុញ្ញាតដាក់បញ្ចាំងសម្រង់នេះនៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

00832146



**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំសូមអានសម្រង់នេះ៖ “២) អំពីបដិវត្តន៍សង្គមនិយមនៅកម្ពុជា៖ ក្នុងមុននឹងបានចូលមកក្នុងប្រទេសចុងឆ្នាំ១៩៧៥នេះ ខ្ញុំមិនបានចាប់អារម្មណ៍ច្បាស់លាស់ថា ថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ជាថ្ងៃបញ្ចប់ដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យទាំងស្រុងនោះទេ។ នៅស្មានថា បដិវត្តន៍នេះត្រូវបន្តមួយរយៈពេលទៀត។ ឯវិធានការធំដូចជាដកប្រជាជន មិនចាយលុយ ខ្ញុំក៏ចាប់អារម្មណ៍មិនដល់កម្រិត ដោយមិនឃើញថា វិធានការនេះជាវិធានការតស៊ូវណ្ណៈយ៉ាងខ្លាំងក្លាក្នុងការបន្តធ្វើបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយម។ នៅពេលនោះ ខ្ញុំយល់សភាពការណ៍នេះ ថាជាវិធានការចាំបាច់ដែលសភាពក្រោយសង្គ្រាមវិនាសកម្មឲ្យយកដូច្នោះ”។ សូមបញ្ចប់ការដកស្រង់។

លោកសាក្សី ខ្ញុំចង់ដឹងថា អ្វីដែលសរសេរនៅក្នុងប្រយោគមួយនេះត្រូវគ្នានឹងព័ត៌មានដែលលោកបានស្តាប់ឮពីវិទ្យុ ឬក៏បានស្តាប់ពីសមាជិកបក្សកុម្មុយនីស្តកម្ពុជាមួយចំនួនពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជន និងការលុបបំបាត់ការចាយលុយនោះ?

[០៩:៥៣:១២]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

អរគុណលោកប្រធាន សូមអរគុណលោក លោកស្រីទាំងអស់ ទាំងនៅក្នុងបន្ទប់ ក្រៅសវនាការ។ បើសិនណាយើងអានទៅលើសារនេះឲ្យបានប្រុងប្រយ័ត្ននោះ គឺសារនេះនិយាយអំពីស្ថានភាពផ្លូវចិត្តរបស់អ្នកណាម្នាក់។ ឥឡូវនេះ គាត់សួរឲ្យសាក្សីរៀបរាប់ចំពោះស្ថានភាពផ្លូវចិត្តរបស់សាក្សីរបស់រឿងនេះ។ ខ្ញុំយល់ឃើញថា មិនត្រឹមត្រូវទេការធ្វើបែបនេះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ព័ត៌មាននេះគឺថាវាមានទំនាក់ទំនងទៅនឹងអ្វីដែលលោកសាក្សីបានឆ្លើយ។ គាត់ថាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺដើម្បីបំបែកខ្សែគិញរបស់ខ្មាំង។ ដូច្នេះ ខ្ញុំចង់បានការឆ្លើយតបពីសាក្សីទៅនឹងអ្វីដែលមានសរសេរនៅក្នុងប្រវត្តិរូបនេះ គឺថាបើយើងមើលទៅ គឺថាវាមិនខុសអំពីមាគ៌ារបស់បក្សនោះទេ គឺវាស្របទៅនឹងមាគ៌ារបស់បក្ស។

[០៩:៥៤:៣៤]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៥:២៦]

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីអន្តរជាតិការពារក្ដីលោក អៀង សារី មិនសមស្រប។ អង្គជំនុំជម្រះត្រូវការស្ដាប់ចម្លើយតបរបស់សាក្សី តបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាចុងក្រោយអម្បាញ់មិញនេះ។ សេចក្ដីជំទាស់គ្មានប្រសិទ្ធភាព។

សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញា! ជាសំណួរចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើលោកចងចាំ។ ហើយបើលោកមិនចាំទេ គឺលោកអាចឲ្យតំណាងសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីម្ដងទៀត។

**លោក សួង ស៊ីគឿន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំក៏មានមតិអ៊ីចឹងដែរ សូមលោកព្រះរាជអាជ្ញាតាំងសំណួរម្ដងទៀតបាទ។

[០៩:៥៦:២៥]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** នៅក្នុងសម្រង់ដែលខ្ញុំបានអានអម្បាញ់មិញនេះ គឺនិយាយអំពីវិធានការធំៗដូចជាការជម្លៀសប្រជាជន ហើយនិងការលុបបំបាត់លុយកាក់។ ហើយសាក្សី -- អ្នកនិពន្ធឯកសារនេះគាត់បាននិយាយថាជាវិធានការធំៗក្នុងការតស៊ូវណ្ណៈ ដើម្បីបន្តការធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម។ តើអ្វីដែលសរសេរនៅក្នុងប្រវត្តិរូបនេះ? ត្រូវនឹងអ្វីដែលលោកបានស្ដាប់ឮនៅក្នុងវិទ្យុ ឬក៏ស្ដាប់ឮពីបក្សផ្ទាល់ពាក់ព័ន្ធនឹងការមិនចាយលុយ ហើយនិងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនេះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** តាមខ្ញុំដឹងមានតែនៅស្រុកខ្មែរទេដែលមានជម្លៀសប្រជាជនចេញពីទីក្រុង ហើយមិនចាយលុយ។ ខ្ញុំចង់និយាយពីប្រទេសសង្គមនិយម ដូច្នេះនៅនេះលោក ជួន ប្រាសិទ្ធ ក៏ដូចខ្ញុំដែរ ខ្ញុំមិនយល់ ខ្ញុំអត់ដឹងថាក្នុងវិធានការធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនេះមានជម្លៀសប្រជាជនចេញ *(ឮមិនច្បាស់)* និងអត់ចាយលុយទេ ព្រោះនៅប្រទេសចិន នៅវៀតណាម គេជម្លៀសដែរប្រជាជនខ្លះៗ

ហើយគេនៅចាយលុយ។ ដូច្នេះ ខ្ញុំឆ្លើយបានតែប៉ុណ្ណឹងទេបាទ លោកប្រធាន។ ហើយបើតាមខ្ញុំយល់អានេះ វាដូចថាវាលោតហួស វាប្លែក។ ស្រុកយើងប្លែកគេអាកន្លែងហ្នឹងបាទ។

[០៩:៥៨:២១]

**ស៖** សូមអរគុណ។ លោកសាក្សី ឥឡូវនេះខ្ញុំសូមអានសម្រង់នៃប្រវត្តិរូបដែលលោកបានផ្ដល់ជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារលេខ D154.3។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

ខ្ញុំអនុញ្ញាតពីអង្គជំនុំជម្រះបង្ហាញអំពីឯកសារប្រវត្តិរូបមួយនេះនៅទំព័រជាភាសាខ្មែរ 00003501 រហូតទៅដល់ 3502, ជាភាសាបារាំង 00290797, ជាភាសាអង់គ្លេស 00816742។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ហើយមានឯកសារជាក្រដាសឲ្យលោកមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ!

[១០:០០:១៦]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** លោកសាក្សី លោកបានផ្ដល់ជូនសហចៅក្រមស៊ើបអង្កេតនូវឯកសារជាភាសាបារាំងដែលលោកបានបកប្រែចេញពីភាសាអង់គ្លេស តើឯកសារខ្មែរដែលបានផ្ដល់ជូនលោកនេះ គឺជាប្រវត្តិរូបបដិវត្តន៍ដែលលោកបានសរសេរនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ហើយលោកបានផ្ដល់ជូនឯកសារនេះជាភាសាបារាំងជូនទៅសហចៅក្រមស៊ើបអង្កេត។

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ឯកសារដែលខ្ញុំមាននៅក្នុងដៃហ្នឹងជាប្រវត្តិរូបរបស់ខ្ញុំមែន។

**ស៖** សូមអរគុណលោកសាក្សី។ នៅទំព័រដែលខ្ញុំបានបង្ហាញអម្បាញ់មិញនេះ គឺជាភាសាខ្មែរ 3501 ទៅដល់ 3502 លោកបានអះអាងដូចតទៅនេះ។ លោកបានប្រាប់ថា "ខ្ញុំឯកភាពទាំងស្រុងជាមួយបក្សទៅលើទស្សនៈ លើបញ្ហាមិនចាយលុយ គ្មានផ្សារ គ្មានប្រាក់ខែ បញ្ហាជម្លៀសប្រជាជនពីទីក្រុង ពីបញ្ហាធ្វើសហករណ៍ ពីការបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយម...។ល។ លោកសាក្សី តើបញ្ហាទាំងអស់នេះ ជាបញ្ហាសំខាន់ៗដែលបក្សបានសម្រេច ហើយយើងមិនអាចជំទាស់តវ៉ាទៅនឹងការសម្រេចនេះបានទេ នៅក្នុងការសរសេរប្រវត្តិរូបនោះ តើអ៊ីចឹងមែនទេ លោកសាក្សី?

**ឆ៖** បាទ គឺថា ក្នុងឋានៈជាបក្ខជន ចូលមកបម្រើ បំពេញភារកិច្ចដែលបក្សប្រគល់ឲ្យ យើងត្រូវតែអនុវត្តមាគ៌ារបស់បក្ស ដូច្នោះបក្សសម្រេចថាម៉េច បក្សឲ្យយើងធ្វើអី គឺថាយើងធ្វើ។ ហើយនៅពេលនោះគឺថា យើងយល់ថាជាវិធានការចាំបាច់ ដើម្បីជាផលប្រយោជន៍ដល់បដិវត្តន៍របស់យើង។ ដូច្នោះការ -- យើងមិនមានចោទសួរអីវែងឆ្ងាយ គិតគូរអីវែងឆ្ងាយ យើងខំតែបំពេញភារកិច្ច ៗដែលបក្សបានប្រគល់ឲ្យយើងបាទ។

[១០:០៣:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិ ការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ មិនជំទាស់ទេ ប៉ុន្តែឯកសារនៅលើអេក្រង់ ដែលខ្ញុំ -- ភាគីផ្សេងទៀតមិនបានឃើញឯកសារ A -- E នោះទេ។ ប្រហែលជាមានបញ្ហាបច្ចេកទេស។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតធ្វើម៉េចឲ្យយើងខ្ញុំបានឃើញឯកសារនោះផងបាទ។

[១០:០៣:៥៦]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធានខ្ញុំនឹងត្រឡប់មកនិយាយពីប្រវត្តិរូបនេះ ហើយនិងកាលៈទេសៈដែលប្រវត្តិរូបនេះត្រូវបានសរសេរ ហើយខ្ញុំមិនចោទសំណួរនៅពេលនេះទេ ហើយយើងនឹងមាន -- យើងអាចដោះស្រាយបញ្ហាបច្ចេកទេសបាននៅបន្តិចទៀតនេះ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ឥឡូវនេះខ្ញុំសូមត្រឡប់មកនិយាយអំពីជំពូកថ្មីមួយទៀត ហើយនិងខ្ញុំដឹងថា លោកនៅទីនេះមិនមែនជាជនជាប់ចោទទេ។ លោកសាក្សី គឺថាលោកនៅទីនេះ ដើម្បីបំភ្លឺព្រឹត្តិការណ៍នៅចន្លោះឆ្នាំ ៧៥-៧៩ ហើយខ្ញុំសូមចោទសំណួរមួយចំនួនទាក់ទងទៅនឹងទំនាក់ទំនងរបស់លោកជាមួយនឹងលោក អៀង សារី។ លោកបាននិយាយកាលពីថ្ងៃព្រហស្បតិ៍មុនថា លោកបានជួបគាត់នៅដើមឆ្នាំ១៩៥៧ ហើយគាត់បានយល់ព្រមយកលោកធ្វើជាសមាជិកលួចលាក់នៅក្នុងចលនាតស៊ូ។

[១០:០៤:៥០]

ហើយលោកក៏បានបញ្ជាក់ផងដែរថា នៅខែតុលា ឆ្នាំ១៩៥៧ អៀង សារី បានផ្ញើសំបុត្រមួយ

ទៅលោក ខៀវ សំផន ហើយខៀវ សំផន បានទទួល ហើយលោកបានទទួលលោកជាសមាជិករបស់ក្រុមនិស្សិត ម៉ាក្សស៊ីស នៅប៉ារីស។ ហើយបន្ទាប់មកទៀតលោកបាននិយាយថា ក្លាយជាបក្ខជនពេញសិទ្ធិនៅបក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ១៩៧១ នៅប៉េកាំង នៅក្នុងពេលពិធីមួយដែលលោក អៀង សារី ជាប្រធាន។ ក្នុងឋានៈជាបក្ខជនពេញសិទ្ធិនៃបក្សកុម្មុយនីស្តកម្ពុជា តើអៀង សារី ធ្លាប់សុំឲ្យលោកធ្វើអ្វីមួយដើម្បីបក្សនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជាដែរឬទេ?

[១០:០៥:៤៤]

**លោក ស្នួង ស៊ីគឿន៖**

**ឆ៖** ពេលដែលខ្ញុំនៅជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងប៉េកាំង នៅឆ្នាំ១៩៧០, ៧១, ៧២, ៧៣ ហើយពាក់កណ្តាល៧៤ហ្នឹង គឺលោក អៀង សារី បានចាត់តាំងឲ្យខ្ញុំធ្វើជាតំណាងរបស់ទីភ្នាក់ងារសារព័ត៌មានកម្ពុជា អា.កា.អ៊ី ប្រចាំទីក្រុងប៉េកាំង បាទ។

**ស៖** បាទសូមអរគុណ។ ហើយនៅពេលក្រោយបន្តិចទៀត នៅពេលដែលយកលោកត្រឡប់មកពីធ្វើមកពីអាហ្វ្រិក និងអឺរ៉ុបជាមួយលោក ខៀវ សំផន, អៀង សារី នៅខែមេសា ឆ្នាំ១៩៧៤ គឺនៅក្នុងយន្តហោះ គឺថាតើអ្នកណាប្រាប់លោកថា លោកនឹងត្រឡប់មកប្រទេសកម្ពុជាឆាប់ៗនៅក្នុងតំបន់រំដោះនៅប្រទេសកម្ពុជា តើអ្នកណាអ្នកប្រាប់លោក?

**ឆ៖** ពេលហ្នឹងគឺ លោក អៀង សារី បាទ។

**ស៖** បាទ សូមអរគុណ។ នៅខែឧសភា ឆ្នាំ១៩៧៤ លោកបានជូនដំណើរលោក អៀង សារី និង ខៀវសំផន ទៅទស្សនកិច្ចផ្លូវការនៅហាណូយ ហើយនិងតំបន់រំដោះនៅប្រទេសឡាវ ហើយតើអ្នកណាជាអ្នកផ្តល់ការណែនាំដល់លោក ឲ្យលោកនៅហាណូយដើម្បីធ្វើការនៅក្នុងវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជាជាមួយ អៀង ធីរិទ្ធ?

[១០:០៧:៣៩]

**ឆ៖** បាទ គឺលោក អៀង សារី ដដែល។

**ស៖** កាលពីថ្ងៃព្រហស្បតិ៍មុន គឺថាលោកបាននិយាយអំពីដែលថា លោកបានទៅប-២០ នៅជិតស្ទឹងត្រែង រយៈពេលប្រហែល១ខែ។ តើលោកធ្វើការនៅក្រសួងណាដែរកាលនោះ?

**ឆ៖** កាលនោះអត់ទាន់មានជាក្រសួងអីទេបាទ ខ្ញុំនៅធ្វើការនៅជាមួយនឹងលោក អៀង សារី។ លោក អៀង សារី ជាអ្នកទទួលខុសត្រូវចំពោះខ្ញុំបាទ។

**ស៖** ហើយបន្ទាប់មកទៀត តើលោកបានចូលធ្វើការក្រសួងការបទេស ហើយអ្នកណាជាអ្នកដឹកនាំក្រសួងនុ៎ង?

**ឆ៖** ក្រសួងការបរទេស គឺថាដឹកនាំដោយលោក អៀង សារី គាត់ជា -- ក្នុងឋានៈគាត់ជារដ្ឋមន្ត្រី -- ក្នុងឋានៈឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសបាទ។

[១០:០៨:៥៧]

**ស៖** តើលោកនៅធ្វើការក្រសួងការបរទេសរហូតដល់ខែមករា ឆ្នាំ១៩៧៩ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំនៅធ្វើការនៅក្រសួងការបរទេស រហូតដល់ខែមករា ឆ្នាំ១៩៧៩ បាទ។

**ស៖** បាទឥឡូវយើងនឹងត្រឡប់មកនិយាយអំពីមុខងារផ្សេងៗ នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេសនេះ ពេលក្រោយ។ តើនៅក្រោយឆ្នាំ១៩៧៩ លោកនៅតែបន្តធ្វើការជាមួយលោក អៀង សារី ឧទាហរណ៍ដូចជានៅក្នុងចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យដែរឬទេ?

**លោក សួង ស៊ីគឿន**

លោកប្រធាន តើខ្ញុំមានកាតព្វកិច្ចឆ្លើយនឹងសំណួរនេះ ព្រោះហួសពីក្របខ័ណ្ឌនៃតុលាការនេះនេះ។

[១០:១០:០១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សូមគោរពសហភាគា ព្រះរាជ-អាជ្ញា លោកអ្នកទាំងឡាយ។

សំណួររបស់សហព្រះរាជអាជ្ញាអំមិញនេះ គឺចាកពីបរិបទ -- រយៈពេលរបស់តុលាការនេះហើយ គឺឈានហួសពីឆ្នាំ -- ខែមករា ឆ្នាំ១៩៧៩ ហើយចូលបរិបទមួយដែលមិនពាក់ព័ន្ធនៅក្នុងដីកាដំណោះស្រាយ។ ដូច្នេះ ខ្ញុំសូមជំទាស់នឹងសំណួរបែបនេះ។ សូមអរគុណ។

[១០:១០:៤៣]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ លោកប្រធាន ខ្ញុំដឹងៗថា វាហួសឆ្នាំ១៩៧៩ ហើយក៏ប៉ុន្តែគ្រាន់ជាសំណួរដើម្បីធ្វើការវាយតម្លៃថាតើសាក្សីនៅតែបន្តមានទំនាក់ទំនងជាមួយ អៀង សារី ក្រោយឆ្នាំ១៩៧៩ ដែរឬទេ តែប៉ុណ្ណឹង

ទេ។ ហើយខ្ញុំមិនចោទសំណួរអីលើសហ្នឹងទេ។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់មេធាវីជាតិការពារក្តីលោក អៀង សារី មិនសមស្របទេ។ អង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយតបរបស់សាក្សីទៅនឹងសំណួរដែលសួរចុងក្រោយដោយតំណាងសហព្រះរាជអាជ្ញា។

សាក្សីឆ្លើយតបទៅនឹងសំណួរនេះ!

[១០:១២:២៨]

**លោក សួង ស៊ីគឿន៖**

បាទ សូមលោកប្រធានឲ្យលោកព្រះរាជអាជ្ញាបញ្ជាក់សំណួរម្តងទៀតបាទ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាតាំងសំណួរចុងក្រោយរបស់លោកសាជាថ្មីម្តងទៀត ពីព្រោះសាក្សីអាចភ្លេចសំណួរដែលលោកសួរហើយ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ អង្គាល់អម្បាញ់មិញនេះ ខ្ញុំចង់ដឹងថា ក្រោយឆ្នាំ១៩៧៩ លោកតែនៅតែបន្តធ្វើការជាមួយលោក អៀង សារី ឧទាហរណ៍ដូចជានៅក្នុងចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យជាដើម។ តើលោកនៅតែបន្តធ្វើការជាមួយគាត់ដែរឬទេ?

[១០:១៣:១២]

**លោក សួង ស៊ីគឿន៖**

**ឆ៖** សូមលោកប្រធានឲ្យលោកព្រះរាជអាជ្ញាបញ្ជាក់ទៀត ព្រោះពេលហ្នឹងវារឿងរយៈកាលប្រវត្តិសាស្ត្រថ្មីទៀត។ ដូច្នេះខ្ញុំអាចថា ខ្ញុំបន្តជាមួយលោក អៀង សារី ក៏បាន ខ្ញុំអាចថា ខ្ញុំបន្តជាមួយអ្នកផ្សេងទៀតក៏បានដែរបាទ។ ឲ្យគាត់ -- ជាពិសេសកាលបរិច្ឆេទពីឆ្នាំណាទៅឆ្នាំណា ហើយសូមឲ្យច្បាស់បន្តិចបាទ សួរឲ្យច្បាស់ៗបន្តិច ស្រួលខ្ញុំឆ្លើយបាទ។

**ស៖** បាទ លោកសាក្សី ឥឡូវនេះយើងលោតទៅមុខបន្តិច។ យើងនិយាយអំពីការបង្កើតចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យរហូតដល់ការចុះចូលរបស់ អៀង សារី មកក្នុងទីក្រុងភ្នំពេញក្នុង

រដ្ឋាភិបាលរហូតដល់ឆ្នាំ១៩៩៦។

[១០:១៤:៣២]

**ឆ៖** គឺក្រោយឆ្នាំ១៩៧៩ ខ្ញុំចង់បញ្ជាក់អ៊ីចេះទេ ចង់បញ្ជាក់ថា លោក អៀង សារី គាត់ជាអ្នកប្រើខ្ញុំ។ ក៏ប៉ុន្តែមិនមែនគាត់ជាអ្នកសម្រេចត្រូវប្រើខ្ញុំទៅណាមកណាទេ ព្រោះបញ្ហាជនមួយចំនួនគឺជោគវាសនាគឺសម្រេចលើគណៈមជ្ឈិបក្ស គណៈអចិន្ត្រៃយ៍មជ្ឈិមបក្ស គណៈអចិន្ត្រៃយ៍មជ្ឈិមបក្ស ហើយជាពិសេសគឺសម្រេចលើ ប៉ុល ពត ហ្នឹងហ្មង។ ដូច្នោះ ចាត់តាំងឲ្យទៅធ្វើនៅនេះ ធ្វើនៅនោះ មិនមែនលោក សារី គាត់អ្នកចាត់តាំងទេ គឺលោក សារី គឺគ្រាន់ថា ឥឡូវភារកិច្ចឲ្យខ្ញុំទៅធ្វើនៅកន្លែងណា គឺរដ្ឋមន្ត្រី ឬអ្នកទទួលខុសត្រូវនៅកន្លែងនោះទទួលខុសត្រូវ ព្រោះក្នុងរយៈពេលនេះ ខ្ញុំធ្លាប់ធ្វើការជាមួយនឹងលោក អៀង សារី ក៏មាន ប៉ុនខ្ញុំធ្លាប់នៅជាប់ជាមួយលោក ខៀវ សំផន ក៏មានដែរបាទ។ ខ្ញុំចង់ជម្រាបប៉ុណ្ណឹង ដូច្នោះ។

[១០:១៥:៥២]

**ស៖** បាទ ខ្ញុំមិនប្រាកដថា លោកបានឆ្លើយតបនឹងសំណួរខ្ញុំទេ គឺថាអម្បាញ់មិញនោះ ខ្ញុំនិយាយពីរយៈពេលក្រោយឆ្នាំ១៩៧៩ គឺថាចន្លោះឆ្នាំ៨០ និង៩០។ ឥឡូវយើងត្រឡប់មកនិយាយពី៧៥ ដល់៧៩វិញ គឺថារយៈពេលដែលថា លោកបានធ្វើការជាមួយលោក អៀង សារី តើលោកអ្នកសហការដ៏ជិតស្និទ្ធជាមួយ អៀង សារី នៅក្នុងរយៈកាលនេះដែរឬទេ?

**ឆ៖** លោកប្រធាន ខ្ញុំដូចមិនយល់ពាក្យហ្នឹងទេ សហការជិតស្និទ្ធម៉េច? ឥឡូវចង់ឲ្យលោកព្រះរាជអាជ្ញាហ្នឹងសួរឲ្យច្បាស់បន្តិចបាទ ព្រោះខ្ញុំមិនយល់អារឿងស្និទ្ធ ជិតស្និទ្ធ មិនជិតស្និទ្ធ។

**ស៖** បើយើងត្រឡប់មកនិយាយពីមុខងារបន្តិចទៀត។ លោកធ្វើការនៅក្រសួងការបរទេសហើយតើលោក -- ក្នុងឋានៈលោកជាអ្នកធ្វើការបុគ្គលិកនៅប-១ ហើយដែលជិតស្និទ្ធនឹង អៀង សារី នៅក្នុងការងារលោកនោះ តើលោកជាសហការីជិតស្និទ្ធជាមួយលោក អៀង សារី ដែរឬទេ?

[១០:១៧:២៤]

**ឆ៖** ខ្ញុំ លោកប្រធាន ខ្ញុំចង់ឲ្យព្រះរាជអាជ្ញាហ្នឹង បញ្ជាក់ពីជិតស្និទ្ធហ្នឹងយ៉ាងម៉េច អាហ្នឹងជិតស្និទ្ធហ្នឹង ជួនកាលយើងធ្វើការ -- សូមអត់ទោស ខ្ញុំអត់សួរចង់និយាយអីឲ្យវែងឆ្ងាយ ប៉ុន្តែខ្ញុំចំណាំមើលខាងផ្នែកបរទេសអន្តរជាតិមកសួរសំណួរខ្ញុំ ដូចអត់ស្គាល់ស្រុកខ្មែរប៉ុន្មាន ហើយជាពិសេសរឿងចលនាកុម្មុយនីស្ត គឺមិនស្គាល់តែម្ដង។ នេះ! ទាំងសួរពីមុនក៏អ៊ីចឹង សួរក្រោយក៏អ៊ីចឹង។ មិនដឹងយ៉ាងម៉េចអ៊ីចឹង

ជិតស្និទ្ធហ្នឹងមានន័យថាម៉េច វាថាឲ្យច្បាស់បន្តិចមើល៍ ព្រោះក្នុងឋានៈជាបក្ខជន គឺមិនមែនជិតស្និទ្ធនឹងបុគ្គលទេ គឺថាជិតស្និទ្ធនឹងមាគ៌ា គឺជិតស្និទ្ធនឹងអ្នកដែលថា ភារកិច្ចដែលយើងបានគឺថា -- ព្រោះឧបមាថាខ្ញុំធ្វើការជាមួយនឹងលោក អៀង សារី មិនមែនមានន័យថា ខ្ញុំដូចថា គាត់ឲ្យខ្ញុំធ្វើអី ខ្ញុំចេះតែធ្វើនោះទេ។ នៅក្នុងក្របខ័ណ្ឌភារកិច្ចរបស់ខ្ញុំ បានខ្ញុំធ្វើដែរ ហើយការខ្លះមានការខ្វែងគំនិតគ្នាពិភាក្សាគ្នាហើយ ប៉ុន្តែគាត់គឺថា ថ្នាក់ក្រោមទទួលស្ដាប់ថ្នាក់លើ ភាគតិចស្ដាប់ភាគច្រើន វាមានគោលការណ៍របស់កុម្មុយនីស្ត វាមានមួយពីរបីហ្នឹង តាមមើលទៅគួរតែខ្ញុំមិនដឹងម៉េចទេ ប៉ុន្តែគួរតែអ្នកបរទេសមកធ្វើការនៅស្រុកខ្មែរ ទី១ គឺស្គាល់ស្រុកខ្មែរ, ទី២ ខ្មែរក្រហមហ្នឹង វាមានខ្មែរផង វាមានក្រហមផង។ ដូច្នោះតោងស្គាល់អ្វីទៅហៅថា “ក្រហម” ចលនាកុម្មុយនីស្តហ្នឹង។ អាហ្នឹងបានយល់ខ្មែរ ឃើញទេ! ខ្ញុំថា ខ្ញុំមិនចង់និយាយទេ ប៉ុន្តែជាពិសេសហ្នឹង ដូចជិតស្និទ្ធវាពិបាកនិយាយណាស់ បើថា ខ្ញុំអាចឆ្លើយថា ជិតស្និទ្ធ ព្រោះខ្ញុំស្គាល់គាត់តាំងពីក្មេង ទាំងគាត់ទាំងប្រពន្ធគាត់ គឺថាទៅបាយទឹកអាហ្នឹងជិតស្និទ្ធហើយ ប៉ុន្តែមិនមានន័យថា គាត់ឲ្យខ្ញុំធ្វើអី ខ្ញុំធ្វើនុ៎ងទេ មានជជែកពិភាក្សាគ្នា ហើយតាមខ្ញុំស្គាល់គាត់ គាត់ចូលចិត្តអ៊ីចឹង។ និយាយរួមទាំងអស់ លោក ខៀវ សំផន អ៊ីចឹងដែរ ចូលចិត្តគឺថា ស្មើភាព។

[១០:២០:០០]

សូមជម្រាបថា យើងជាជនកុម្មុយនីស្ត ហើយជាសមាជិកបក្ស ឡេនីន -- អ៎! វង់ ឡេនីន នៅស្រុកបារាំង។ យើងមកពីមជ្ឈដ្ឋានផ្សេងៗគ្នាស្គាល់ផ្សេងៗគ្នា ប៉ុន្តែចលនានេះរឹងណាស់ ខុសត្រូវអីប៉ុនទុកតែយើងមានខ្វែងមតិគ្នា មិនយល់គ្នា ប៉ុន្តែយើងស្រឡាញ់គ្នា ដូចបងប្អូនសាច់មួយឈាមមួយអ៊ីចឹង។ ហេតុដូច្នេះ ហើយបានជានៅពេលនេះ ខ្ញុំ -- មិនមានពេលនេះ ខ្ញុំឈឺចាប់ណាស់ ដែលពួកដឹកនាំខ្មែរក្រហមហែកហួរគ្នា កាប់សម្លាប់គ្នា ឈឺចិត្តណាស់។ ហើយខ្ញុំឈឺចិត្តណាស់ ដែលឃើញបងៗមកអង្គុយខាងនោះ នៅខាងនោះ ព្រោះ--

[១០:២០:៤៥]

**ប្រធានអង្គជំនុំ៖**

បានហើយសាក្សីចាំស្ដាប់សំណួរ។ ស្ដាប់សំណួរ ឆ្លើយតបនឹងសំណួរ។ យើងជម្រាបរំឭកលោកច្រើនលើកច្រើនសាហើយ ប្រសិនបើលោកព្យាយាមក្នុងការអត្ថាធិប្បាយក្រៅ ចេញក្រៅពីសំណួរកាន់តែច្រើននោះ គឺនឹងមានបញ្ហា ការខាតបង់កម្លាំងរបស់លោក និងពេលវេលា ក្នុងការតាំងសំណួរដេញដោល ដើម្បីឈានដល់ការចប់តាមគម្រោងផែនការដែលបានគ្រោងទុកនោះ។ ហើយសូមស្ដាប់

សំណួរឲ្យបាន ហើយចៀសវាងនិយាយឲ្យប៉ះពាល់ទៅដល់ភាគី ដែលមានសិទ្ធិក្នុងការតាំងសំណួរ។ នេះជាអង្គជំនុំជម្រះ ប្រសិនបើលោកដឹង គឺលោកឆ្លើយថា ដឹង។ បើលោកមិនដឹង គឺថាមិនដឹងទៅ។

សូមបន្តតាំងសំណួរលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ លោកសាក្សី ខ្ញុំប្រើពាក្យ “លោក” ដែលលោកប្រើនៅក្នុងចម្លើយសាក្សីរបស់លោក ហើយត្រូវបានបកប្រែជាភាសាបារាំង។ គឺថាបារាំងនោះ គេប្រើពាក្យថា *“ប្រូស កូឡាបូរ៉ាទ័រ”*។ ឥឡូវ ខ្ញុំសូមអានចម្លើយរបស់លោកមួយ គឺថា E3/42, D167 គឺជាចម្លើយរបស់លោក ដែលលោកផ្ដល់ជូន នៅខែឧសភា ឆ្នាំ២០០៩។ លោកសាក្សី ខ្ញុំសូមផ្ដល់ឯកសារនេះ ទៅលោកសាក្សី ហើយនិងអានសម្រង់ មួយចំនួន -- មួយដែលមាននៅក្នុងទំព័រខ្មែរ គឺ 00327209 ដល់ 010, ជាភាសាបារាំង គឺទំព័រទី៨ ហើយអង់គ្លេស គឺERN 00327219។ ហើយខ្ញុំសូមអនុញ្ញាតបញ្ចាំងសម្រង់នេះ ទៅលើអេក្រង់ លោកប្រធាន។

**[១០:២២:៥០]ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ហើយមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ ជាក្រដាសពីតំណាងសហ ព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

[១០:២៣:១៩]

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ខ្ញុំមិនអានទាំងអស់ទេ គឺថាខ្ញុំអានចម្លើយដែលលោកឆ្លើយតបទៅនឹងសំណួរមួយ ដែល ចាប់ផ្ដើមដូច្នេះ៖ “អៀង សារី មិនបានប្រាប់ខ្ញុំដោយផ្ទាល់ទេ គាត់បាននិយាយពីរឿងនេះ នៅក្នុងកិច្ច ប្រជុំមួយរបស់នាយកដ្ឋាននយោបាយទូទៅ ដែលមានការចូលរួមអំពីសហការីរបស់គាត់ ដូចជា ជួន ប្រាសិទ្ធ, គាត ឈន់, តូច ខាំឿន, ឱក សុគន្ធ, ចាន់ យូរ៉ាន់, ពេជ្រ ប៊ុនរ៉េត និងខ្ញុំផ្ទាល់ និងអ្នកស្រី សួរ សែ ដែលជាលេខាសាខាបក្ស។ ជួន ប្រាសិទ្ធ និង គាត ឈន់ ត្រូវបានចោទប្រកាន់ជាភ្នាក់ងាររបស់ ស៊ី.អ៊ី.អា ហើយនិងគណៈកម្មាធិការសន្តិសុខបានសម្រេចចិត្តចាប់ខ្លួនគាត់។ អៀង សារី បានពន្យល់ថា ក្រសួងមិនអាចដំណើរការដោយគ្មានពួកគេនោះទេ។ យើងត្រូវយល់ថា គាត់មានការទុកចិត្តលើពួកគាត់ ទាំងស្រុង។ អ្នកទាំងនេះ ក៏ដូចជាខ្ញុំដែរ គឺស្ថិតនៅក្នុងរង់ម៉ាក្ស-ឡេនីន ដែលលោក អៀង សារី ជា ស្ថាបនិកជាមួយ កេង វ៉ាន់សាក់ និង រ័ត្ន សាមឿន”។

[១០:២៤:៣៥]

បាទ នៅក្នុងសម្រង់នេះ យើងនិយាយអំពីសហការីជិតស្និទ្ធ ហើយនិងការទុកចិត្តលើសហការីទាំងអស់នេះ។ តើលោក អៀង សារី នៅក្នុងក្របខ័ណ្ឌការងារនោះ តើគាត់ទុកចិត្តដែរឬទេ លោកសាក្សី?

**លោ សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំថាអានេះគឺ ខ្ញុំពិបាកនឹងឆ្លើយដែរបាទ។ ព្រោះក្នុងការតស៊ូវណ្ណៈ ក្នុងការតស៊ូផ្ទៃក្នុងរបស់បក្ស ពាក្យទុកចិត្តហ្នឹងដូចជា ពិបាកថា ទុកចិត្តឬមិនទុកចិត្តវា ដូចខ្ញុំបាននិយាយអំមិញគឺ យើងប្រៀបផ្ទឹមៗ វិនិច្ឆ័យអ្វីមួយៗ គឺដោយផ្ទុះបញ្ចាំងទៅតាមមាគ៌ារបស់បក្ស។ ដូច្នោះ ខ្ញុំមិនចង់ថា ឥឡូវទៅសួរគាត់វិញទេ ព្រោះវាៗ អាហ្នឹងវាមិនគួរសមចំពោះគាត់ទេ ប៉ុនថា ខ្ញុំថា វាមានកម្រិតទុកចិត្ត យើងគិតថា ១០០ភាគរយមិនមានទេ ប៉ុនអាចថា ខ្ញុំថា ៥១ភាគរយចុះ អាហ្នឹងក៏ខ្ញុំជាប់មធ្យមភាគដែរ ដូច្នេះមិនមានបញ្ហាអីទេបាទ។ ខ្ញុំនិយាយដើម្បីស្រួលយល់តែប៉ុណ្ណឹងទេបាទ។ ព្រោះបញ្ហាទុកចិត្តមិនទុកចិត្តក្នុងជីវភាពផ្ទៃក្នុងរបស់បក្ស ដូចគេមិនមានចោទបញ្ហាហ្នឹងទេបាទ។ ព្រោះអ្វីក៏ជាការវិវត្តន៍ អ្វីជាការតស៊ូស្រួចស្រាល់ ក្នុងរយៈពេលនេះគឺថា ទុកចិត្តអ្នកនាំនៅលើយើង ទុកចិត្តយើង មួយរយៈពេលទៀត ក្នុងកាលៈទេសៈថ្មី ប្រវត្តិសាស្ត្រថ្មី រូបភាពគូទំនាស់ថ្មី អាហ្នឹងការទុកចិត្តហ្នឹងវាអាចប្រែប្រួលទៅតាមហ្នឹងដែរបាទ។ សូមបាទ។

[១០:២៧:១០]

**ស៖** បាទសូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមត្រឡប់មកនិយាយអំពីមុខងារជាបន្តបន្ទាប់ដែលលោកបានបំពេញនៅក្នុងក្រសួងការបរទេស។ តើលោកអាចជម្រាបខ្លីៗអំពីមុខងារផ្សេងៗ និងឋានៈផ្សេងៗដែលលោកកាន់កាប់ជាបន្តបន្ទាប់នៅក្រសួងការបរទេសចន្លោះឆ្នាំ១៩៧៥ ដល់ ៧៩។ ហើយបន្ទាប់មកទៀត យើងនឹងត្រឡប់មកនិយាយអំពីមុខងាររបស់លោកទាំងអស់នេះ។

**ឆ៖** ខ្ញុំចង់ជម្រាបថា ក្រសួងការបរទេសគឺលោក អៀង សារី គាត់ចាត់តាំងខ្ញុំបីនាក់បាទ។ ខ្ញុំ លោក គាត ឈន់ និងមិត្តភក្តិរបស់ខ្ញុំម្នាក់ដែលជាសមាជិករង់ម៉ាក្ស-ឡេនីន នៅប៉ារីស គឺថា រស់ សារិន ឲ្យរៀបចំក្រសួងការបរទេសនៅ គេហៅថា ផ្ទះកោង ឥឡូវជាទីស្នាក់ការគណៈរដ្ឋមន្ត្រីនោះបាទ។ ផ្ទះកញ្ចក់ ផ្ទះកោង ហើយចូលមកគឺ ខ្ញុំកាន់កាប់នៅ៧៥ហ្នឹង ជាអ្នកទទួលខុសត្រូវផ្នែកអាស៊ីអាគ្នេយ៍ ហើយនិងផ្នែកអឺរ៉ុប។ បន្ទាប់មក ជាអនុប្រធានទីវីកា រួចមកជាប្រធាន ចាប់តាំងពីឆ្នាំ -- ចាប់តាំង

ពីខែមិថុនា ឆ្នាំ១៩៧៧ ជាប្រធានផ្នែកព័ត៌មានឃោសនាការនៃក្រសួងការបរទេស ហើយជាអ្នកនាំពាក្យរបស់ក្រសួងការបរទេសបាទ រហូតដល់ឆ្នាំ១៩៧៩។

[១០:២៩:០៥]

**ស៖** តើលោកជាអនុប្រធានខាងពិធីការដែរឬទេ? ហើយនិងជាសមាជិកផ្នែកនយោបាយ?

**ឆ៖** បាទ ខ្ញុំភ្លេច ខ្ញុំជាអនុប្រធានផ្នែកពិធីការ ហើយជាសមាជិកផ្នែកនយោបាយនៃក្រសួងការបរទេស។ ផ្នែកនយោបាយក្រសួងការបរទេសហ្នឹង អ្នកដឹកនាំគឺ លោក អៀង សារី ផ្ទាល់បាទ។

**ស៖** បាទ សូមអរគុណ។ តើអ្នកណាជាប្រធានផ្នែកពិធីការ នៅពេលដែលលោកជាអនុប្រធានកាលហ្នឹង?

**ឆ៖** ជាអ្នកស្រី សួរ សែ គាត់ជាភរិយារបស់លោក ពេជ្រ ប៊ុនរ៉េត បាទ។ ពេជ្រ ប៊ុនរ៉េត ជាតំណាងរបស់កម្ពុជាប្រជាធិបតេយ្យអមគណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមកិច្ចរបស់អង្គការសហប្រជាជាតិប្រចាំអាស៊ីប៉ាស៊ីហ្វិក។ គេហៅ *អេសកាប* នៅបាងកក បាទ។

**ស៖** តើលោកធ្លាប់ជាប្រធានៗទីភ្នាក់ងារ អា.កា.អ៊ី នៅរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះឆ្នាំ៧៥-៧៩។ លោកបាននិយាយពីរឿងនេះ នៅពេលលោកនៅ ប៉េកាំង ហើយបន្ទាប់ពីខែឧសភា ឆ្នាំ១៩៧៥ ហ្នឹងលោកជាអ្នកទទួលខុសត្រូវនៃភ្នាក់ងារ ទីភ្នាក់ងារសារព័ត៌មាននេះ តើអីចឹងមែនទេ?

**ឆ៖** ដល់ចូលមកក្នុងប្រទេស គឺថាលោក ប៉ុល ពត ហ្នឹងចាត់តាំងខ្ញុំជាប្រធានទីភ្នាក់ងារព័ត៌មានកម្ពុជា។ គឺលែងជា អា.កា.អ៊ី ហើយ គឺថាទីភ្នាក់ងារព័ត៌មានកម្ពុជា គឺខុសគ្នាត្រង់ថា អា.កា.ប៉េ. ៗ។ ដូច្នេះអីចឹងបាទ។

[១០:៣១:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនូវបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់មួយ ខ្វះដប់នាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:២៧]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងនិយាយដោយសង្ខេបទេ ខ្ញុំចង់ជូនដំណឹងដល់អង្គជំនុំជម្រះជាមុនថា យើងនឹង ៗមើលវិធានផ្ទៃក្នុង និងទាក់ទងទៅនឹងលោក -- ប្រកាស សេចក្តីប្រកាសរបស់លោក ហោ ណាំហុង នៅក្នុងខេមបូឌារ ដេលី កាលពីសប្តាហ៍មុន គឺថាជាការរំខានដល់កិច្ចការតុលាការ។

[១០:៥៣:៤១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើដូច្នេះទេ ហើយអង្គជំនុំជម្រះបានជម្រាបជូនលោករួចហើយ។ ប្រសិនបើមានបញ្ហាអី លោកដាក់ឯកសារលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះ ដើម្បីអង្គជំនុំជម្រះពិនិត្យពិចារណាសម្រេច។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** មុនពេលសម្រាក លោកសាក្សី យើងបាននិយាយអំពីទីភ្នាក់ងារសារព័ត៌មាន ហើយនិងសារព័ត៌មានរបស់កម្ពុជា។ លោកនិយាយថា ប៉ុល ពត បានតែងតាំងលោកជាប្រធាន ហើយតែងតាំងលោកជាប្រធាននេះ ដោយទទួលសំណើពីអ្នកណា? តើលោកត្រូវបានតែងតាំងជាប្រធាននេះតាម រយៈ

សំណើពីអ្នកណា?

**លោក សួង ស៊ីគឿន៖**

**ឆ៖** អត់មានតាមរយៈសំណើអ្នកណាទេ គឺថាគាត់តែងតាំងខ្ញុំដោយផ្ទាល់របស់គាត់តែម្តង។

[១០:៥៥:០០]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន គ្រាន់តែជាឃ្លាខ្លីមួយដែលខ្ញុំចង់ដកស្រង់នៅក្នុងឯកសារ E3100 ឬក៏ D91/25 ខ្ញុំមិនដឹងថា គួរតែបញ្ចាំងនៅលើអេក្រង់ដែរឬអត់ទេ ពីព្រោះថា លោកសាក្សីគឺថា ឲ្យគាត់ -- លោក ប៉ុល ពត តែងតាំងគាត់តាមសំណើរបស់លោក អៀង សារី។ ខ្ញុំមិនដឹងថា គួរចាំបាច់ឲ្យយោង ទាំងស្រុងតែម្តងនោះទេ ជាភាសាខ្មែរគឺថា 00204148, ភាសាអង់គ្លេសទំព័រទី -- បារាំងទំព័រទី៣ គឺថា 003636 (ស៊ីក) បើសិនជាលោកប្រធានចាត់ទុកថា ត្រូវតែបញ្ចាំងនោះ ខ្ញុំអាចបញ្ចាំងទៅលើអេក្រង់ ហើយនិងឲ្យមួយច្បាប់ទៅលោកសាក្សី ហើយបើមិនដូច្នោះទេគឺថា គ្រាន់តែសុំឲ្យលោកសាក្សីនោះ បញ្ចេញប្រតិកម្មនូវ -- ទៅនឹងពាក្យពេចន៍ដែលគាត់បាននិយាយ ជូនទៅសហចៅក្រមស៊ើបអង្កេតហ្នឹង ជាការគ្រប់គ្រាន់ហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ ទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកទៅជូនសាក្សី ពិនិត្យ ហើយដាក់បង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** បាទសម្រង់គឺមាននិយាយថា ជាភាសាបារាំងគឺថានៅចុងទំព័រទី៣ “ដោយ អៀង សារី ណែនាំ ប៉ុល ពត បានឲ្យខ្ញុំទទួលខុសត្រូវជាភ្នាក់ងារសារព័ត៌មានកម្ពុជា ហើយទាក់ទងការងារផ្សាយ ជាភាសាបរទេស ហើយនិងការអប់រំពេលព្រឹកហ្នឹង ខ្ញុំទទួលការណែនាំពីលោក អៀង សារី”។ បាទ សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើទីភ្នាក់ងារ អា.កា.អ៊ី ហ្នឹងធ្វើអីដែរ? ហើយមុខងារ អា.កា.អ៊ី ហ្នឹង អ្វីដែរ? ទីភ្នាក់ងារសារព័ត៌មានកម្ពុជា?

[១១:៥៨:០៤]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ក្នុងឯកសារនេះគឺ ចំពោះផ្នែកទីភ្នាក់ងារសារព័ត៌មាន គឺប៉ុល ពត ចាត់តាំងឲ្យខ្ញុំទទួលខុស

ត្រូវដោយមានការបង្គាញពីលោក អៀង សារី។ ខ្ញុំសូមបញ្ជាក់ថា អានេះគឺ ពាក្យថាការបង្គាញនេះ ខ្ញុំពេលដែលខ្ញុំមើលក្នុងឯកសារនេះពេលនុ៎ងគឺថា ខ្ញុំមិនបានយកចិត្តទុកដាក់ឲ្យច្បាស់ទេបាទ។ ប៉ុន្តែមែនទែនមិនមែនអ៊ីចឹងទេ គឺព្រោះអី ព្រោះលោក អៀង សារីហ្នឹង គាត់ប្រឆាំង មិនប្រឆាំងទេ គាត់មិនឯកភាពនឹងការតែងតាំងហ្នឹងទេ។ ព្រោះអី? ព្រោះការងារខ្ញុំច្រើន វាអាច វាប៉ះពាល់ដល់ភារកិច្ចធំនៅក្រសួងការបរទេស។ ព្រោះទីភ្នាក់ងារសារព័ត៌មាននេះគឺ មែនទែនត្រូវក្រសួងព័ត៌មាន និងឃោសនាការក្រសួងរដ្ឋមន្ត្រីសារព័ត៌មានៗឃោសនាការជាអ្នកទទួល ម៉េចក៏ឲ្យមកខ្ញុំទទួលវិញ។ ដូច្នេះ កន្លែងនេះខ្ញុំមានការខ្វះខាត គឺខ្ញុំមិនបានយល់ពាក្យបង្គាញហ្នឹងបាទ។

[១០:៥៩:២២]

ដូច្នោះ វាការពិតទៅ គឺថាលោកអៀង សារី គាត់មិនឯកភាពចំពោះសេចក្តីតែងតាំងនេះទេ គាត់បានណែនាំខ្ញុំជំទាស់។ ខ្ញុំបានជំទាស់ ពេលនុ៎ងខ្ញុំបានមិនព្រមទទួលទេ។ ប៉ុន្តែពេលនុ៎ងគឺថា លោក ប៉ុល ពតគាត់បានថា អ្ហឺ! មិនមានបញ្ហាអីទេ មិត្តធ្វើតែអត្ថបទតែប្រាំអត្ថបទបានហើយម្តងៗ។ អ៊ីចឹងវាប្រាំអត្ថបទមានអីពិបាក។ ធ្វើប្រាំអត្ថបទ កុំឲ្យធ្វើ២០, ៣០ អត្ថបទអាហ្នឹងវាពិបាកប្រចាំថ្ងៃ។ ខ្ញុំក៏ទទួលយកទៅបាទ។ ហ្នឹងខ្ញុំសូមបញ្ជាក់។ ហើយខ្ញុំសូមបញ្ជាក់ពីឈ្មោះ មិនមែនជា អា.កា.អ៊ី ទេ ព្រោះ អា.កា.អ៊ី ពេលមុន៧៥។ នេះគឺថា អា.កា.ប៉េ វាដូចនេ៎ -- ប៉ុន្តែគ្រាន់ អា.កា.ប៉េ ជំនាន់សង្គមរាស្ត្រនិយមគឺ *អាហ្សង់ ខ្មែរ ដឺប្រេស* នេះ *អាហ្សង់ កម្ពុជា ដឺប្រេស*។ “កា” ហ្នឹងពីជំនាន់សង្គមនិយមគេថាខ្មែរ ប៉ុន្តែជំនាន់កម្ពុជាប្រជាធិបតេយ្យ គឺកម្ពុជាបាទ ប៉ុន្តែអក្សរកាត់ដូចតែគ្នាបាទ។

**ស៖** តើ អា.កា.ប៉េ ហ្នឹងធ្វើអ្វីដែរ? ហើយលោកសរសេរអត្ថបទអ្វីខ្លះ? ហើយអត្ថបទហ្នឹងសរសេរដើម្បីអ្នកណាដែរ?

[១១:០០:៥៣]

**ឆ៖** អានេះគឺជាទីភ្នាក់ងារសារព័ត៌មាន គឺថាជូនដំណឹង។ ដំណឹងវាមានច្រើនប្រភេទ គឺដំណឹងក្នុងប្រទេស និងដំណឹងអន្តរជាតិ។ ដូច្នោះមិនមានអីខុសប្លែកពីទីភ្នាក់ងារព័ត៌មានផ្សេងៗទេបាទ។

**ស៖** នៅក្នុងសម្រង់ដែលខ្ញុំបានអានអម្បាញ់មិញនេះ គឺថាមានសរសេរថា “លោកជាប្រធានផ្នែកផ្សព្វផ្សាយជាភាសាបរទេសនៃវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យ”។ តើផ្សព្វផ្សាយជាភាសាបរទេសអ្វីខ្លះ?

**ឆ៖** ក្នុងពេលហ្នឹង គឺខ្ញុំជាអ្នកទទួលខុសត្រូវសរសេរ បកប្រែ ថតសំឡេង ផ្សាយ។ ដូច្នោះ

ការងារនោះមួយថ្ងៃៗ នៅឆ្នាំ១៩៧៧ និង១៩៧៨ វាធ្វើការរហូតដល់ម៉ោងបួនកន្លះភ្លឺ។ ម៉ោងបួនកន្លះហ្នឹងគឺថាអត្ថបទទាំងហ្នឹងត្រូវថត ទាំងថតសំឡេងត្រូវរួចរាល់ទាំងអស់ មុនយកទៅឲ្យវិទ្យុនៅស្ទឹងមានជ័យហ្នឹងផ្សាយ ព្រោះវិទ្យុគេផ្សាយម៉ោងប្រាំ។ ក្នុងរយៈពីរឆ្នាំហ្នឹង ខ្ញុំបានសម្រាកតែកន្លះម៉ោងទេមួយថ្ងៃ សូមជម្រាប។ ហើយផ្សាយជាភាសាអី ផ្សាយជាភាសាៗវៀតណាម ភាសាអង់គ្លេស ភាសាបារាំង ភាសាចិន ហើយនិងរៀបតុងផ្សាយជាភាសាថៃ គឺខាងផ្នែកខ្ញុំធ្វើទាំងអស់។

[១១:០៣:០០]

**ស៖** បើខ្ញុំយល់ថា ការផ្សព្វផ្សាយជាភាសាចិន ហើយនិងភាសាវៀតណាមនេះ យើងដឹងថាផ្សាយទៅកាន់អ្នកណា។ ប៉ុន្តែជាភាសាបារាំងនោះ តើធ្វើការផ្សព្វផ្សាយសម្រាប់អ្នកជាភាសាអង់គ្លេស?

**អ្នកបកប្រែ៖**

បាទ សូមទោស អ្នកបកប្រែសូមកែប្រែជាភាសាអង់គ្លេស។

**ឆ៖** មែនទែន គឺភាសាអង់គ្លេសប្រទេសនៅអាស៊ីអាគ្នេយ៍ជុំវិញ លើកលែងតែវៀតណាម និងលាវ គេស្តាប់ភាសាអង់គ្លេសទាំងអស់។

**ស៖** ទាក់ទងទៅនឹងខ្លឹមសារនៃការផ្សព្វផ្សាយទាំងអស់នេះ តើខ្លឹមសារជាក់លាក់អ្វីទៅ? តើវាជាការផ្សព្វផ្សាយឃោសនា ឬក៏លោកផ្សព្វផ្សាយតែសុន្ទរកថា ឬក៏បទយកការណ៍លើព្រឹត្តិការណ៍ដែលកើតឡើងមាននៅក្នុងប្រទេស? លោកអាចបញ្ជាក់បំភ្លឺត្រង់ចំណុចនេះបានដែរឬទេ?

**ឆ៖** ការផ្សព្វផ្សាយហ្នឹង វាផ្សព្វផ្សាយពីសកម្មភាពបង្កបង្កើនផល ពីការដូចថា ព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងប្រទេស ហើយនិងផ្សព្វផ្សាយពីសកម្មភាពអន្តរជាតិរបស់កម្ពុជាប្រជាធិបតេយ្យនៅលើសកលលោកបាទ។

**ស៖** តើលោកទទួលសេចក្តីណែនាំពីអ្នកណាទាក់ទងទៅនឹងការផ្សព្វផ្សាយជាភាសាបរទេសនេះ?

[១១:០៥:០០]

**ឆ៖** នេះគឺ ការផ្សព្វផ្សាយនេះគឺវាឃ្លាតឆ្ងាយពីសេចក្តី -- ឃ្លាតចាកពីការទទួលខុសត្រូវរបស់លោក អៀង សារី គឺថា ខ្ញុំទទួលផ្ទាល់ពីលោក ប៉ុល ពត តែម្តងបាទ។

**ស៖** លោកបាននិយាយថា លោកត្រូវបានតែងតាំងជាប្រធានផ្នែកព័ត៌មានឃោសនាការចាប់ពីឆ្នាំ១៩៧៧ គឺ មិថុនា ៧៧ តើការងារនេះ ខុសពីការងារទីភ្នាក់ងារព័ត៌មានកម្ពុជាយ៉ាងម៉េចដែរ? តើផ្នែកនេះធ្វើអ្វីដែរ នៅក្នុងក្រសួងការបរទេសនេះ?

**ឆ៖** ផ្នែកនេះវាទាក់ទងផ្ទាល់នឹងការងារបរទេសបាទ។ ជាដំណឹងអន្តរជាតិ ជាការផ្សព្វផ្សាយសកម្មភាពទូតរបស់យើងនៅអន្តរជាតិ ហើយនិងសកម្មភាពៗទូតរបស់ប្រទេសជាមិត្តនៅលើកម្ពុជា ដូចជាទទួលសារតាំង ដូចដំណើរទស្សនកិច្ចគណៈប្រតិភូបរទេសនៅកម្ពុជាប្រជាធិបតេយ្យបាទ។

**ស៖** តើនៅក្នុងផ្នែកឃោសនាការនិងព័ត៌មានដែលនៅក្នុងក្រសួងនេះ តើមានៗផ្នែកបកប្រែឯកសារ ឬក៏អត្ថបទសារព័ត៌មានដែរឬទេ ជាភាសា -- ពីភាសាបរទេសមកភាសាខ្មែរ?

**ឆ៖** វា -- ហ្នឹងការបកប្រែហ្នឹងវាពីខ្មែរទៅភាសាបរទេស ពីភាសាបរទេសមកខ្មែរអាហ្នឹងជាការធម្មតា ជាកិច្ចការប្រចាំថ្ងៃរបស់ផ្នែកនេះបាទ។

**ស៖** តើក្នុងចំណោមឯកសារ ហើយនិងអត្ថបទដែលត្រូវបកប្រែជាភាសាខ្មែរនោះ តើមានឯកសារ ឬក៏អត្ថបទណាដែលមកពីប្រទេស -- បស្ចិមប្រទេសដែរឬទេ ហើយដែលទាក់ទងទៅនឹងស្ថានភាពនៃប្រទេសកម្ពុជានៅពេលនោះ?

**ឆ៖** ខ្ញុំចាំមិនបានទេ ប៉ុន្តែមិនមែនភារកិច្ចរបស់ -- ផ្ទាល់របស់ផ្នែកនេះទេបាទ ព្រោះមានៗអង្គការចាត់តាំងផ្សេងទៀតដែលគេទទួលភារកិច្ចនេះ។ ក្រៅពីក្រសួងការបរទេសបាទ។

[១១:០៨:៤០]

**ស៖** តើនៅក្នុងក្រសួងការបរទេស តើមានផ្នែកខាងទទួលស្តាប់ព័ត៌មានជាភាសាបរទេសដែរឬទេ?

**ឆ៖** បាទ គឺផ្នែកខ្ញុំហ្នឹងហើយដែលទទួលស្តាប់ព័ត៌មានជាភាសាបរទេស គឺថាជាភាសាបារាំង អង់គ្លេស ចិន និង វៀតណាមបាទ។

**ស៖** តើស្តាប់ព័ត៌មានជាភាសាបរទេសនេះ ក្នុងបំណងអ្វី? តើលោកត្រូវរាយការណ៍ពេលដែលស្តាប់ហើយនោះ ថារាយការណ៍អំពីខ្លឹមសារនៃការផ្សព្វផ្សាយទាំងអស់នេះ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ អាហ្នឹងវាមានព្រឹត្តិបត្រប្រចាំថ្ងៃ មានព្រឹត្តិបត្រប្រចាំអាទិត្យ ហើយមានព្រឹត្តិបត្រប្រចាំខែដែរបាទ។ ជាដំណឹងបរទេសទាក់ទងនឹងសភាពការណ៍នៅក្នុងកម្ពុជាប្រជាធិបតេយ្យពេលនោះបាទ។

[១១:១០:០៧]

**ស៖** តើក្នុងកម្មវិធីផ្សាយទាំងអស់នេះគឺថា មានកម្មវិធីបារាំង អន្តរជាតិ ឬក៏ប៊ី.ប៊ី.ស៊ី ឬសំឡេងអាមេរិកាំង ឬក៏កម្មវិធីផ្សព្វផ្សាយផ្សេង នៃសារព័ត៌មានអន្តរជាតិផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ មាន គឺថាខ្ញុំទទួលភារកិច្ច និងអនុញ្ញាតឲ្យស្តាប់វិទ្យុទាំងអស់នោះបាទ។

**ស៖** តើនៅក្នុងកម្មវិធីផ្សព្វផ្សាយទាំងអស់នេះ គេមាននិយាយអំពីការចោទប្រកាន់ដល់កម្ពុជាប្រជាធិបតេយ្យ ដែលធ្វើឧក្រិដ្ឋកម្មទៅលើប្រជាជនរបស់ខ្លួនដែរឬទេ?

**ឆ៖** ធម្មតាព័ត៌មាន វាមានខ្លះហើយបាទ ប៉ុន្តែដល់ខ្ញុំថា ខ្ញុំមិនមានបកដូចថារាយការណ៍ព័ត៌មាននេះប្រាប់អ្នកដឹកនាំទេបាទ។

[១១:១១:២៨]

**ស៖** បាទ ក្នុងឋានៈជាអ្នក -- ជាកូនចៅរបស់ អៀង សារី តើលោកមិនមានកាតព្វកិច្ចក្នុងការរាយការណ៍លើខ្លឹមសារ នៃកម្មវិធីផ្សាយទាំងអស់នេះទេឬ?

**ឆ៖** អាហ្នឹងភារកិច្ចរបស់ខ្ញុំគឺផ្សាយរាយការណ៍ មានសេចក្តីរាយការណ៍ ហើយតាមដែលខ្ញុំស្គាល់គាត់ គឺលោក សារី គាត់មានសំណូមពរដូច្នេះ។ អ្វីដែលគេផ្សាយ យើងត្រូវរាយការណ៍ដូចដែលគេផ្សាយ កុំកាឡៃ កុំថែមថយ កុំបំបាត់។ ក៏ប៉ុន្តែឲ្យរាយការណ៍នេះជារាយការណ៍ផ្ទាល់មាត់ មិនមែនជារាយការណ៍ជាលាយលក្ខណ៍អក្សរទេ ព្រោះបើរាយការណ៍លាយលក្ខណ៍អក្សរវា ឯកសារហ្នឹងអាចធ្លាក់ទៅអ្នកដែលសមាជិកធម្មតា វាទៅជារឿងផ្សេងទៅវិញបាទ។

**ស៖** ខ្ញុំមិនច្បាស់ថាយល់ចម្លើយលោកទាំងស្រុងទេគឺថា លោកធ្វើការរាយការណ៍ផ្ទាល់មាត់ទៅលោក អៀង សារី ទាក់ទងទៅនឹងខ្លឹមសារនៃកម្មវិធីផ្សព្វផ្សាយទាំងអស់នេះ។ ដូច្នេះថា តើសារព័ត៌មានអន្តរជាតិដែលចោទប្រកាន់លើរបបកម្ពុជាប្រជាធិបតេយ្យ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។ អ៊ីចឹងគឺថា លោកបានផ្តល់ដំណឹងដល់ អៀង សារី ដែរឬទេ អំពីខ្លឹមសារនៃសារព័ត៌មានទាំងអស់នេះ?

**ឆ៖** ខ្ញុំបានជម្រាបអំមិញហើយគឺថា លោក អៀង សារី គាត់មានសំណូមពរដូច្នេះ។ រាយការណ៍អ្វីក៏ដោយមិនមែនត្រឹមតែសារព័ត៌មានបរទេស និយាយអំពីសភាពការណ៍នៅកម្ពុជាប្រជាធិបតេយ្យទេ រាយការណ៍នៅក្នុងប្រទេស រាយការណ៍អ្វីក៏ដោយ គាត់ -- ការណែនាំរបស់គាត់រាយការណ៍ឲ្យដូចដែលព្រឹត្តិការណ៍ដែលកើតជាក់ស្តែងកុំថែម កុំថយ គឺថាចំពោះគាត់។ ដូច្នេះ បញ្ហានេះដែលជាបញ្ហាមួយដែលតាមខ្ញុំស្គាល់គាត់ គាត់ចូលចិត្តអ៊ីចឹង។ ហើយគាត់មិនចូលចិត្តបញ្ចើចបញ្ចើ គាត់មិនចូលចិត្តនេះទេ គាត់ចូលចិត្តតែច្បាស់ៗ គឺសាមញ្ញធម្មតា។

[១១:១៣:៥២]

ហេតុនេះហើយបានជាចំពោះគាត់ វាយការណ៍អ៊ីចឹងទៅមិនមានចោទជាបញ្ហាទេ ព្រោះក្នុងបរិយាកាសពេលនោះ បើយើងវាយការណ៍ដូចដែលវិទ្យុសហរដ្ឋ -- សំឡេងសហរដ្ឋអាមេរិកនិយាយអ៊ីចឹងគឺថា គេអាចចោទថា យើងហ្នឹងយល់ដូចវិទ្យុសំឡេងសហរដ្ឋអាមេរិកអ៊ីចឹង គឺថាដូច្នោះជា -- គេហៅថា ធ្វើអី ធ្វើសតិសម្ព័ន្ធ ពាក្យ"សតិសម្ព័ន្ធ"ហ្នឹង។ វាមានអ៊ីចឹង ប៉ុន្តែចំពោះខ្ញុំធ្វើការផ្ទាល់ជាមួយគាត់គឺគាត់មិនមានគំនិតនេះទេ ព្រោះយើងវាយការណ៍ក្នុងឋានៈជាអ្នកដឹកនាំប្រទេស ក្នុងឋានៈជាអ្នកទទួលខុសត្រូវផ្នែកក្រសួងការបរទេស យើងត្រូវក្តាប់សភាពការណ៍ជាក់ស្តែង អ្វីដែលកើតឡើងមានជាក់ស្តែង មិនមែនតាម មិនមែនវាយការណ៍តាមចិត្តដែលយើងចង់នោះទេបាទ។ មិនមែនវាយការណ៍ដើម្បីនឹងយកជើងយកដៃ ហើយដើម្បីឲ្យអ្នកដឹកនាំហ្នឹងគឺថា សប្បាយចិត្ត ពេញចិត្តនឹងយើងទេបាទ។ អានេះជាចំណុចមួយដែលខ្ញុំសូមបំភ្លឺទាំងអស់គ្នា ដែលខ្ញុំធ្វើការជាមួយគាត់។

**ស៖** បាទ សូមអរគុណ។ តើលោក អៀង សារី ធ្លាប់បានប្រាប់លោកថា ខ្លួនគាត់ផ្ទាល់នោះបាន វាយការណ៍លើព័ត៌មានដែលលោកបានប្រាប់គាត់ ទាក់ទងនឹងឧក្រិដ្ឋកម្មទៅថ្នាក់ដឹកនាំខ្មែរក្រហមផ្សេងទៀតដែរឬទេ?

[១១:១៥:៣១]

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។

**ស៖** តើតួនាទីរបស់លោកនៅក្រសួងការបរទេសនោះ លោកក្នុងឋានៈលោកជាអ្នកនាំពាក្យនៅក្រសួងការបរទេសនេះ ហើយអ្នកណាជាមេផ្ទាល់របស់លោក?

**ឆ៖** មេផ្ទាល់របស់ខ្ញុំគឺ លោក អៀង សារី ប៉ុន្តែនៅផ្នែកខ្លះគឺ ខ្ញុំធ្វើការផ្ទាល់ជាមួយនឹង ប៉ុល ពត តែម្តងបាទ។ ក្នុងឋានៈគាត់ជាលេខាបក្ស គាត់អាចប្រើខ្ញុំ ធ្វើអីខ្ញុំបាន បានដូចថា ស្របច្បាប់តាមច្បាប់ពេលនោះណា តាមការចាត់តាំងពេលនោះបាទ។

**ស៖** បាទ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីកិច្ចប្រជុំនៅប-១ នៅក្នុងក្រសួងការបរទេស តើមានកិច្ចប្រជុំអ្វីខ្លះដែលកើតមានឡើងនៅប-១ ដែលលោកបានចូលរួមនៅចន្លោះឆ្នាំ១៩៧៥-៧៩?

**ឆ៖** ការប្រជុំមានច្រើនជំពូក គឺថាទី១ ប្រជុំសាខារបស់បក្សប្រចាំក្រសួងទាំងមូល។ អាហ្នឹងប្រជុំតាមខ្ញុំចាំ ប្រជុំដូចជាកន្លះខែម្តង។ រួចពីហ្នឹង គឺថាប្រជុំការងារ ប្រជុំការងារតាមផ្នែក អាហ្នឹងបីថ្ងៃម្តង។ ប្រជុំការងារតាមជាក្រសួងទូទៅ អាហ្នឹងដូចមួយខែម្តង។ ខ្ញុំមិនចាំបរិច្ឆេទច្បាស់លាស់ទេ ហើយប្រជុំរៀនសូត្រស៊ីជម្រៅ អាហ្នឹងធ្វើ៣ខែម្តង ឬ៦ខែម្តង អាហ្នឹងប្រជុំច្រើនថ្ងៃបាទ។ ប្រជុំ១អាទិត្យ

ឬយ៉ាងតិចណាស់ក៏បីបួនថ្ងៃដែរ មានការពាក់ព័ន្ធអ្នកដែលពាក់ព័ន្ធធ្វើជីវទស្សន៍ គេហៅថា ធ្វើជីវទស្សន៍ អ្នកដែលបានចូលរួមប្រជុំនៅម្នាក់ៗបាទ។

[១១:១៨:០២]

**ស៖** បាទ ខ្ញុំសូមត្រឡប់មកនិយាយពីកិច្ចប្រជុំមួយចំនួន។ ខ្ញុំសូមឲ្យបំភ្លឺទាក់ទងទៅនឹងកិច្ចប្រជុំរៀនសូត្រ ដែលៗលោកនិយាយតើកិច្ចប្រជុំទាំងអស់នេះ អាចច្រឡំគ្នានឹងមហាសន្និបាត នៃក្រសួងដែរឬទេ ឬក៏ខុសគ្នា?

**ឆ៖** តាមខ្ញុំចាំគឺថា វាខុសគ្នាបាទ។ សន្និបាតក្រសួងហ្នឹង ដូច ខ្ញុំដូចមិនចាំថា គេធ្វើសន្និបាតអីទេក្រសួង ប៉ុន្តែការរៀនសូត្រវគ្គយូរ ១អាទិត្យអីហ្នឹង គឺថាមានបាទ។

**ស៖** បាទ សូមអរគុណ។ តើលោក អៀង សារី បានចូលរួមក្នុងប្រភេទប្រជុំណាខ្លះ ហើយគាត់បានធ្វើអ្នក ជាអ្នកដឹកនាំកិច្ចប្រជុំអ្វីខ្លះ? ហើយ ឬក៏គាត់ទៅចូលរួមតែកិច្ចប្រជុំមួយចំនួននោះទេ ដែលទាក់ទងទៅនឹងក្រសួងទាំងមូល ឬក៏ផ្នែកមួយចំនួននៃក្រសួង?

**ឆ៖** គឺប្រជុំអប់រំនយោបាយវែងយូរ ១អាទិត្យអីហ្នឹងគាត់ចូលរួមផ្ទាល់ គាត់ជាអ្នកខទ្មេសនាមឯកសារ ហើយប្រជុំខ្លះ ដូចប្រជុំផ្នែកនយោបាយ អ៊ីចឹង គាត់ចូលរួម។ ប្រជុំអីទៀតពេលខ្លះ គាត់ចូលរួម ពេលខ្លះគាត់មិនបានចូលរួមទេ គាត់ទុកឲ្យប្រធានផ្នែកដំណើរការបាទ។

[១១:២០:០៤]

**ស៖** ហើយប្រជុំបក្ស ឬក៏ប្រជុំសាខាបក្សនោះ តើលោក អៀង សារី ធ្វើជាប្រធានកិច្ចប្រជុំទាំងអស់នេះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាថា ក្រសួងការបរទេស វាចែកជាពីរផ្នែក គឺផ្នែកមន្ទីរ ហើយនិងផ្នែកការិយាល័យ។ ផ្នែកមន្ទីរនោះ គឺផ្នែកបង្កបង្កើនផល ផ្នែកសន្តិសុខ ផ្នែកការងារ ដូចដាំបាយ ដូចអ៊ីចឹង។ ហើយផ្នែកការិយាល័យ គឺថាផ្នែកការងារទូត អ្នកការទូតតែម្តង។ ហើយផ្នែកមន្ទីរហ្នឹងគឺមានការចាត់តាំងផ្សេង មានការចាត់តាំងសាខាបក្សផ្សេង ហើយខាងផ្នែកមន្ទីរហ្នឹង មានចាត់តាំងសាខារបស់បក្សផ្សេង។ លោក អៀង សារី គាត់ចូលរួមប្រជុំផ្នែកបក្ស ទាំងពីរផ្នែកហ្នឹង គឺថាផ្នែកបក្សខាងផ្នែក ន៎ ផ្នែកមន្ទីរ ហើយផ្នែកខាងបក្ស គឺខាងផ្នែកការងារទូតនេះបាទ។

[១១:២១:៣៧]

**ស៖** ហើយទាក់ទងទៅនឹងផ្នែកការិយាល័យនេះ តើលោកមិនមែនជាសមាជិកដែរឬទេ? តើ

លោកនៅក្នុងផ្នែកនាយកដ្ឋានការទូត។ អ៊ីចឹងលោកជាសមាជិកខាងនាយកដ្ឋានការទូត ឬយ៉ាងម៉េច?

**ឆ៖** ផ្នែកការិយាល័យហ្នឹង គឺថាមានសាខារបស់បក្ស ហើយសាខានេះ គឺថាមានលោកស្រី សូរ សែ ជាលេខារបស់បក្ស ហើយខ្ញុំជាសមាជិកដែរ។ ហើយផ្នែកការងារទូតហ្នឹង វាចែកជាផ្នែកទូទៅ គឺថាមួយជាផ្នែកលេខាធិការដ្ឋានរបស់ក្រសួង ផ្នែកពិធីការ ផ្នែកបង្កបង្កើនផល ផ្នែកការងារនយោបាយ ហើយផ្នែករបស់ខ្ញុំ គឺថាផ្នែកឃោសនានិងព័ត៌មាន បាទ។

**ស៖** តើ សូរ សែ បានប្រាប់លោកថា គាត់ជាអ្នកដឹកនាំសាខាបក្សនោះ ថាគាត់ជាកូនចៅរបស់ អៀង សារី ដែរឬទេ? គាត់មានប្រាប់លោកថា គាត់ជាកូនចៅរបស់លោក អៀង សារី ដែរឬទេ?

[១១:២៣:១៤]

**លោក សួង ស៊ីគឿន៖**

សូមលោកព្រះរាជអាជ្ញាឲ្យលោក -- លោកប្រធាន! ឲ្យព្រះរាជអាជ្ញាបញ្ជាក់ថា កូនចៅហ្នឹង មានន័យថាម៉េចបាទ?

**ប្រធានអង្គជំនុំ៖**

សូមតាំងសំណួរម្តងទៀត លោកតំណាងសហព្រះរាជអាជ្ញា! គាត់មិនយល់សួរថា កូនចៅហ្នឹង ថាម៉េច វា -- កូនចៅសាច់ញាតិលោហិត ឬក៏យ៉ាងម៉េច? ពាក្យ កូនចៅនេះ ពាក្យសាមញ្ញទេ ហើយ បើពាក្យផ្លូវការនោះ គឺអាចលោកគប្បីប្រើពាក្យផ្សេង ប្រសិនបើជាអត្ថន័យជាបុគ្គលិក ឬជាកម្មាភិបាល ជាមន្ត្រីរាជការនោះ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណដែលបានបំភ្លឺ។ ខ្ញុំនិយាយនៅក្នុងក្របខ័ណ្ឌក្រសួងការបរទេស ដោយថា អៀង សារី គាត់ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការបរទេស ហើយនិងរដ្ឋមន្ត្រីក្រសួងការបរទេស ហើយ សូរ សែ គាត់ជាលេខាសាខាបក្ស នៅក្នុងក្របខ័ណ្ឌការងារក្រសួងការបរទេស តើគាត់ស្ថិតនៅ ក្រោមឱវាទ ឬក៏ការដឹកនាំរបស់លោក អៀង សារី ដែរឬទេ?

[១១:២៤:៤៣]

**ឆ៖** បាទ ក្នុងឋានៈគាត់ជាប្រធាន -- គាត់ធ្វើប្រធានពីរ។ គាត់ប្រធានលេខាធិការដ្ឋានផង ប្រធានផ្នែកពិធីការផង ហើយមែនទែនបើឯនោះ ហើយប្រធានសាខាបក្សនៃផ្នែកការិយាល័យ គឺផ្នែក ការងារទូត បាទ។ ដូច្នោះច្បាស់ហើយ គាត់នៅក្រោមការទទួលខុសត្រូវរបស់លោក អៀង សារី។

**សៈ** បាទ សូមអរគុណ។ នៅក្នុងប្រភេទប្រជុំទាំងអស់ដែលលោកបានលើកឡើងនេះ ថាតើមានវគ្គអប់រំរៀនសូត្រដែរឬទេ រយៈពេលវែង ហើយដែល-- តើអ្នកណាអ្នកចូលរួមវគ្គប្រជុំទាំងអស់នេះ?

**ឆៈ** ក្នុងការប្រជុំរៀនសូត្រវគ្គវែង គឺកម្មាភិបាលសំខាន់ៗរបស់ក្រសួង គឺមិនមែនគ្រាន់តែប្រធានផ្នែកទេ គឺថាសមាជិកផ្នែកធម្មតា ប៉ុន្តែកម្មាភិបាលទាំងអស់ចូលរួមបាទ។

**សៈ** តើគោលបំណងនៃវគ្គប្រជុំរៀនសូត្រនេះ មានគោលបំណងអ្វី?

**ឆៈ** ការរៀនសូត្រនេះ វាគោលបំណងទីមួយ ឲ្យក្ដាប់សភាពការណ៍នៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅក្នុងប្រទេស ហើយឲ្យអ្នកចូលរួមប្រជុំហ្នឹងក្ដាប់បាននូវភារកិច្ចចំពោះមុខរបស់សមាជិកម្នាក់ៗ។ ហើយបន្ទាប់មកក៏មានវិធីពាក់ព័ន្ធឆ្លងជីវទស្សន៍នៃអ្នកចូលរួមម្នាក់ៗបាទ។

[១១:២៧:២៥]

**សៈ** ហើយតើលោកអាចនិយាយអំពីប្រធានបទដែលគេនិយាយនៅក្នុងវគ្គអប់រំរៀនសូត្រនេះដែរឬទេ? ឧទាហរណ៍ ថាតើ អៀង សារី បាននិយាយអំពីអ្វីខ្លះនៅក្នុងវគ្គប្រជុំរៀនសូត្រទាំងអស់នេះ?

**ឆៈ** គឺក្នុងការប្រជុំវគ្គវែងហ្នឹង គឺគាត់ច្រើនមានឯកសាររបស់បក្សមកឧទ្ទេសនាមបាទ។ គាត់មិនមែនឧទ្ទេសនាមតែមាត់ទទេទេ មានឯកសារបស់បក្សឧទ្ទេសនាម។ ហើយខ្ញុំមិនបានចាំច្បាស់ទេ ពីព្រោះឯកសារហ្នឹង ឯកសារអ្វីខ្លះហ្នឹង ប៉ុន្តែខ្ញុំគ្រាន់ដឹងថា ឯកសារហ្នឹង គឺថាជាសភាពការណ៍ ទូទៅទាំងក្នុងប្រទេស ទាំងក្រៅប្រទេស នៃបដិវត្តន៍ដែលកំពុងប្រព្រឹត្តឡើងក្នុងកម្ពុជាប្រជាធិបតេយ្យ នៅលើទឹកដីកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងភារកិច្ចដែលត្រូវធ្វើតទៅទៀតបាទ។

**សៈ** ទាក់ទងទៅហ្នឹងប្រធានបទដែលនិយាយអំពីកិច្ចការផ្ទៃក្នុងប្រទេស តើមានប្រធានបទតូចៗដែលនិយាយលើកឡើងដែរទេ? តើគេមានធ្លាប់និយាយពីខ្មាំងផ្ទៃក្នុងដែរឬទេ?

[១១:២៨:១២]

**ឆៈ** បាទអាហ្នឹងច្បាស់ហើយ គឺថា ឯកសារនិយាយអំពីសភាពការណ៍នៅក្នុងប្រទេស និយាយអំពីខ្មាំងផ្ទៃក្នុងហ្នឹងហើយ។

**សៈ** បាទ ឥឡូវយើងនឹងត្រឡប់មកនិយាយកន្លែងនេះនៅពេលក្រោយទៀត។ តើលោកអាចសង្ខេបបានទេ ថាតើអ្នកណាជាខ្មាំងបង្កប់ដែលថា មានសរសេរនៅក្នុងអត្ថបទ ដែលលោក អៀង សារី បានបង្ហាញនៅក្នុងវគ្គអប់រំរៀនសូត្រនេះ?

**ឆ៖** គឺខ្មាំងហ្នឹងវាមានច្រើនប្រភេទ។ ខ្មាំងក្រៅប្រទេស ខ្មាំងក្នុងប្រទេស ហើយខ្មាំងក្នុងពួងផ្ទៃក្នុងរបស់យើងម្នាក់ៗ។ ខ្មាំងក្រៅប្រទេស អាហ្នឹងយើងដឹងហើយក្នុងពេលនោះ មានអ្នកណាខ្លះ? គឺមាន គឺចក្រពត្តិអាមេរិក ក្រោយមកគឺថាចាប់ពីឆ្នាំ១៩៧០ ចុង៧៧ ចុង៧៨ គឺថាមានប្រទេសវៀតណាម អាហ្នឹងជាខ្មាំងជារួម ហើយមានភ្នាក់ងារចារកម្មផ្សេងៗរបស់បស្ចិមប្រទេស របស់គួកម៉េងតាំង របស់ស៊ីអ៊ីចឹង។ ហើយខ្មាំងក្នុងប្រទេស គឺជារួម ភ្នាក់ងាររបស់មហាអំណាចទាំងនោះ។ ជាពិសេសគឺថាខ្មាំងដែលបង្កប់ស៊ីរ៉ូងក្នុងជួបបក្ស ក្នុងជួរកងទ័ព និងក្នុងជួរ និងក្នុងចំណោមប្រជាជន។ ក៏ប៉ុន្តែឯកសារពេលនោះសង្កត់ធ្ងត់គឺខ្មាំងពួងផ្ទៃក្នុងរបស់យើង ដែលជាទិសដៅសំខាន់បំផុតនៃបដិវត្តន៍សង្គមនិយម គឺខ្មាំងពួងផ្ទៃក្នុងយើងគឺស្អី កេរដំណែលសង្គមចាស់ កេរដំណែលវណ្ណៈជិះជាន់ដែលមានជាប់នៅក្នុងខ្លួនយើងគឺស្អី គឺការលោភលន់ បុណ្យស័ក្តិ ការរស់នៅដោយប្លែកពីប្រជាជន ការរស់នៅចាយវាយហួសហេតុលើសពីសេចក្តីដូចថា ប្រជាជនដែលធ្វើបង្កបង្កើនផលបានជាដើមហ្នឹងបាទ។ សំខាន់បំផុតគឺថាខ្មាំងពួងផ្ទៃក្នុងនេះហើយដែលជាសត្រូវធំបំផុតចំពោះបក្ខជនម្នាក់ៗបាទ។ អាហ្នឹងខ្ញុំសរុបប៉ុណ្ណឹង។

[១១:៣២:៣៩]

**ស៖** សូមអរគុណ។ អម្បាញ់មិញនេះ លោកបានប្រើពាក្យមួយថាត្រូវតែជម្រះចេញអ្នកដែលត្រូវការលុយ ហើយអ្នកជិះជាន់កេងប្រវ័ញ្ច។ តើឯកសារដែលបញ្ជាក់នេះជាឯកសារអ្វី ហើយលោកអៀង សារី បាននិយាយអ្វីខ្លះពាក់ព័ន្ធទៅនឹងជម្រះខ្មាំងសត្រូវចេញនេះ? តើការជម្រះខ្មាំងសត្រូវនេះមានន័យថាយ៉ាងម៉េចដែរ?

**ឆ៖** ជម្រះ ឥឡូវខ្ញុំនិយាយពេល -- នៅពេលនោះ ដែលតាមដែលខ្ញុំយល់នៅពេលនោះ គឺថាជម្រះដូចថាជម្រះខ្មាំងសត្រូវគឺសំខាន់ គឺថាបុគ្គលសត្រូវហ្នឹង បុគ្គលខ្មាំងហ្នឹងវាជាបន្ទាប់បន្សំទេ ប៉ុន្តែការយល់ទំនៀមទម្លាប់រស់នៅ របៀបរបបធ្វើការងារ វាមួយខ្សែរបស់វាហ្នឹង ដែលយើងត្រូវជម្រះព្រោះយើងកម្ទេចបុគ្គលហ្នឹង មិនជាពិបាកទេ ក៏ប៉ុន្តែយើងកម្ចាត់ពីក្នុងខ្លួនយើងនេះ នូវកេរដំណែលរបស់វណ្ណៈសក្តិភូមិ វណ្ណៈនាយទុន វណ្ណៈជិះជាន់នេះ ពិបាកណាស់។ អាបញ្ហានេះ គឺជាទិសដៅសំខាន់បំផុតនៃការ ៗអប់រំនៅពេលនោះ។

[១១:៣៤:៣៧]

**ស៖** សូមអរគុណ។ តើបក្សគាត់ធ្វើយ៉ាងម៉េចដែរ ដើម្បីកំណត់អត្តសញ្ញាណ ឬក៏ស្វែងរកខ្សែ

រយៈខ្លាំង?

**ឆ៖** ចំណុចនេះគឺថា និយាយពីបក្សហ្នឹង លោកព្រះរាជអាជ្ញា ចង់និយាយកម្រិតណា? នៅតាមមូលដ្ឋាន នៅតាម នៃពីខាងលើ ឬយ៉ាងម៉េច? ព្រោះខ្ញុំ បើនៅក្នុងកន្លែងខ្ញុំផ្ទាល់ អាហ្នឹងខ្ញុំអាចនិយាយបាន ប៉ុន្តែក្រៅពីនេះ ខ្ញុំអត់ដឹងទេ ខ្ញុំនិយាយមិនបានទេ បាទ។

**ស៖** សូមឲ្យលោកកម្រិតត្រឹមតែអ្វីដែលគេនិយាយនៅក្នុងមន្ទីរប-១ ពាក់ព័ន្ធទៅនឹងវិធី ឬក៏របៀបក្នុងការកំណត់អត្តសញ្ញាណខ្សែរយៈខ្លាំង? ហើយបន្ទាប់មក គឺត្រូវតែជម្រះ ឬក៏កម្ចាត់ខ្សែរយៈទាំងអស់នោះ?

**ឆ៖** ខ្ញុំមិនអាចនិយាយបានពីមន្ទីរប-១ ទេ ព្រោះខ្ញុំមិនបានដឹងទេ បាទ។ ហើយមិនមែនជាក្នុងក្របខ័ណ្ឌការងាររបស់ខ្ញុំ និងភារកិច្ចរបស់ខ្ញុំទេ។ ភារកិច្ចរបស់ខ្ញុំនៅផ្នែកព័ត៌មាន និងឃោសនាការនៃក្រសួងការបរទេសនេះ អាហ្នឹងបានខ្ញុំអាចនិយាយបាន។ សូមលោកព្រះរាជអាជ្ញា សួរខ្ញុំឲ្យច្បាស់ក្នុងបញ្ហាហ្នឹង។ បញ្ហាឯទៀត ខ្ញុំអត់ដឹងទេ។ ខ្ញុំមិនត្រូវការដឹង ហើយក៏ជា -- គឺថាជាការណែនាំ ហើយជាការចាំបាច់ក៏ខ្ញុំ -- គេមិនឲ្យខ្ញុំដឹងដែរបាទ។

[១១:៣៦:៥៥]

**ស៖** យើងនឹងត្រឡប់មកនិយាយអំពីចំណុចនេះវិញនៅពេលក្រោយ។ ឥឡូវនេះ ខ្ញុំបន្តអំពីកិច្ចប្រជុំដដែល។ លោកបាននិយាយអំពីកិច្ចប្រជុំផ្ទៃក្នុងនៅក្នុងផ្នែកនីមួយៗ។ ប្រសិនបើខ្ញុំមិនច្រឡំទេ គឺថាមានការប្រជុំគ្នា៣ថ្ងៃម្តង។ តើអ្នកណាជាអ្នកសុំឲ្យលោកជួបប្រជុំគ្នាជាទៀងទាត់បែបនេះ? ហើយអ្នកណាជាអ្នកកំណត់អំពីកម្មវត្ថុនៃកិច្ចប្រជុំផ្ទៃក្នុងរបស់ផ្នែកនីមួយៗនេះ?

**ឆ៖** អាហ្នឹង វាធម្មតា អ្នកទទួលខុសត្រូវជាអ្នកកំណត់ហើយ ប៉ុន្តែដូច៣ថ្ងៃម្តង មានអ្នកខ្លះធ្វើ៣ថ្ងៃម្តង អ្នកខ្លះ -- កន្លែងខ្លះគេធ្វើ១ថ្ងៃម្តង។ គឺថាប្រជុំការងារអត់មានអីទេ គ្រាន់តែរាយការណ៍ពីការងារដែលយើងបានធ្វើ ពីភារកិច្ចដែលយើងអនុវត្តមានការទិតៀន ស្វ័យទិតៀនតិចតួច ហើយកំណត់ដាក់ការងារទៅធ្វើទៅ៣ថ្ងៃខាងមុខទៀត ឬក៏១អាទិត្យខាងមុខទៀត។ ដូច្នោះ អ្នកខ្លះ ផ្នែកកន្លែងខ្លះ គេធ្វើ៣ថ្ងៃម្តង កន្លែងខ្លះគេធ្វើប្រចាំថ្ងៃ ខ្លីៗ។ ហើយអាហ្នឹងធម្មតា ស្រេចតែនៅខាងក្រោមហ្នឹងសម្រេចទៅ ខាងលើគ្រាន់តែថាឲ្យមានប្រជុំ។ ការងារ វាមានប្រជុំការងារ មានប្រជុំជីវភាព ហើយនិងមានប្រជុំឆ្លងជីវទស្សន៍ធំយូរ។

[១១:៣៨:៥៣]

**សះ** នៅពេលដែលមានកិច្ចប្រជុំនៅក្នុងផ្នែកឃោសនាព័ត៌មានរបស់លោកនេះ តើលោកមានពឹងផ្អែកទៅលើឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ ដើម្បីពិភាក្សាជាមួយនឹងសមាជិកផ្សេងៗនៅក្នុងផ្នែករបស់លោកនោះ?

**ឆះ** នៅក្នុងផ្នែកហ្នឹង គឺថាភាគច្រើនមិននិយាយតែភារកិច្ចទេបាទ ព្រោះខាងនយោបាយ ខាងផ្នែកនយោបាយ គឺថាមានផ្នែកផ្សេងទៀត ឬមានការប្រជុំរួម គេបានបំពេញការងារនេះហើយ។ ខាងការងារខ្ញុំធ្វើ គិតគូរតែពីការបំពេញភារកិច្ចប្រចាំថ្ងៃ ប្រចាំអាទិត្យប៉ុណ្ណោះ។ ហើយនិងការ ដូចថាជួយកសាងគ្នាពីការខ្វះខាតក្នុងការងារ ក្នុងការកិច្ចដំណើរការស្រាលៗទេ មិនមែនជាចូលជាជម្រៅអីប៉ុន្មានទេបាទ។

[១១:៤០:០៤]

**សះ** តើមានបុគ្គលិកប៉ុន្មាននាក់ធ្វើការនៅក្នុងផ្នែកឃោសនាការ និងព័ត៌មានរបស់លោកនេះ?

**ឆះ** ផ្នែកនេះបុគ្គលិកក៏បើប្រៀបធៀបច្រើនដែរ ប្រហែលមាន២០នាក់ទេបាទ។

**សះ** តើ ឡុង នរិន្ទ ជាសមាជិកស្ថិតនៅក្នុងផ្នែករបស់លោកនេះដែរឬទេ?

**ឆះ** បាទ គាត់ជាសមាជិកនៅក្នុងផ្នែកនេះ មុនគាត់ទៅទទួលបន្ទុកជាផ្នែកពិធីការបាទ។

**សះ** តើលោក ស្វាយ បូរី ស្ថិតនៅក្នុងផ្នែកនេះដែរឬទេ?

**ឆះ** លោក ស្វាយ បូរី គាត់នៅផ្នែក -- គាត់ចូលមកក្រសួងការបរទេសក្នុងរយៈពេលថ្មីទេ -- ខ្លីទេបាទ។ តាមខ្ញុំចាំ ដូចគាត់មិនទាន់ចាត់តាំងនៅក្នុងផ្នែកណាច្បាស់លាស់ទេ គាត់នៅដូចថាជា ដូចជាបុគ្គលិកអណ្តែតអីចឹង គឺនៅផ្នែកច្រើន គេយកទៅដាក់នៅផ្នែកលេខាធិការដ្ឋាន ជាអ្នកធ្វើ -- ទទួលបន្ទុកខាងធ្វើឯកសារបាទ។

[១១:៤១:៥៤]

**សះ** សូមអរគុណលោកសាក្សី។ នៅពេលដែលមានកិច្ចប្រជុំផ្ទៃក្នុងនៅក្នុងផ្នែករបស់លោក តើលោកត្រូវរាយការណ៍អំពីខ្លឹមសារនៃកិច្ចប្រជុំនេះទៅកាន់លោក អៀង សារី ដែរឬទេ?

**ឆះ** បាទនេះគឺថាជាភារកិច្ចរបស់ខ្ញុំ ហើយជាខ្លឹមសារនៃការចាត់តាំងផ្ទៃក្នុងដែរ ត្រូវធ្វើដូច្នេះបាទ។

**សះ** តើលោករាយការណ៍នេះជាលាយលក្ខណ៍អក្សរ ឬក៏ដោយផ្ទាល់មាត់នៅពេលមានកិច្ចប្រជុំផ្ទៃក្នុង ក្នុងផ្នែករបស់លោកនេះ?

**ឆ៖** គឺរបៀបធ្វើការងាររបស់ -- នៅពេលនោះគឺច្រើនរាយការណ៍ផ្ទាល់ទេ មិនមានឯកសារជាលាយលក្ខណ៍អក្សរទេបាទ។

**ស៖** ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំប្រធានផ្នែក ឬក៏ប្រធាននាយកដ្ឋានផ្សេងៗ ប្រសិនបើខ្ញុំមិនច្រឡំទេ លោកបានបញ្ជាក់ថា លោក អៀង សារី ជាប្រធាននៅក្នុងអង្គប្រជុំនេះ។ តើលោកអៀង សារី គាត់មានតួនាទីអ្វីឲ្យពិតប្រាកដនៅក្នុងពេលប្រជុំប្រធានផ្នែកផ្សេងៗ? តើគាត់ធ្វើអ្វីដែរនៅក្នុងពេលប្រជុំនោះ? តើលោកអាចជម្រាបពីចំណុចនេះបានទេ?

**ឆ៖** គាត់ជាប្រធានប្រជុំ ហើយប្រជុំប្រធានផ្នែកហ្នឹងគឺថាច្រើនក្នុងកាលៈទេសៈសំខាន់ៗ។ ប៉ុន្តែឲ្យខ្ញុំចាំបានច្បាស់លាស់ហ្នឹង ខ្ញុំមិនមានចាំទេបាទ។

[១១:៤៤:២០]

**ស៖** តើមានផ្នែកនៃកិច្ចប្រជុំបែបនេះ ដែលថាមានអ្នកចូលរួមជាប្រធានផ្នែកសម្រាប់ធ្វើការរាយការណ៍ ឬក៏នៅក្នុងកិច្ចប្រជុំហ្នឹងមានតែលោក អៀង សារី ទេ ដែលគាត់ជាអ្នកធ្វើបទឧទ្ទេសនាមនោះ តើលោកចាំទេ?

**ឆ៖** បាទ គឺថាមានតែគាត់ទេបាទធ្វើសេចក្តី គឺថារាយ -- គេហៅថា ឧទ្ទេសនាមពីសភាពការណ៍នៅក្នុងប្រទេស និងសភាពការណ៍នៅក្រៅប្រទេសបាទ។ ហើយនិងភារកិច្ច ហើយនិងភារកិច្ចដែលយើងត្រូវបំពេញទៅថ្ងៃមុខបាទ។

**ស៖** ក្នុងពេលប្រជុំប្រធានផ្នែកផ្សេងៗ ឬក៏កិច្ចប្រជុំផ្សេងទៀត ពាក់ព័ន្ធទៅនឹងមាគ៌ានយោបាយរបស់បក្ស តើលោក អៀង សារី មានប្រាប់លោកអំពីចំណុចនេះទេ? ហើយលោក អៀង សារី គាត់ធ្លាប់ប្រាប់ដល់ប្រធានផ្នែកផ្សេងៗ អំពីសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ដែរឬទេ?

[១១:៤៥:៥៧]

**ឆ៖** អាហ្នឹងធម្មតាគាត់មានវិធានការ ឬព្រឹត្តិការណ៍អីសំខាន់ គឺថាគាត់ជូនព័ត៌មាន គាត់បានប្រាប់ អាហ្នឹងជាធម្មតាទេបាទ។ ប៉ុន្តែឲ្យថាខ្ញុំចាំថា ព័ត៌មានព្រឹត្តិការណ៍នោះអ្វីខ្លះ គឺខ្ញុំមិនបានចាំទេ។

**ស៖** តើលោកមានចាំទេថា គាត់ធ្លាប់និយាយអំពីសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិមបក្សដែរឬទេ? អាចជាទៀងទាត់ ឬក៏យូរៗម្តង?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែគឺគាត់មិនបានប្រាប់អីច្រើនដងទេ យូរៗម្តងទេ បើសេចក្តីសម្រេចអីប៉ុន្តែគាត់មិនដែលថាសេចក្តីសម្រេចគណៈអចិន្ត្រៃយ៍អីជាអីចឹងទេ គឺច្រើននិយាយអំពីសេចក្តីសម្រេច

របស់បក្ស និយាយជាបក្សរួមតែម្ដងបាទ។

**សៈ** សូមអរគុណ។ អម្បាញ់មិញនេះលោកបាននិយាយថា សន្និបាត -- មហាសន្និបាតប្រព្រឹត្តទៅនៅក្នុងក្រសួងការបរទេស។ ពាក្យថា “មហាសន្និបាត” នេះដូចជាចម្លែកណាស់ គឺថាមានកិច្ចប្រជុំធំនៅក្នុង១អាទិត្យម្ដង តើយើងហៅថាជាសមាជ ឬក៏មហាសន្និបាត? តើប៉ុន្មានខែ ឬក៏ប៉ុន្មានឆ្នាំម្ដង ដែលលោក អៀ សារី រៀបចំកិច្ចប្រជុំទូទៅ ដែលយើងហៅថាជា “មហាសន្និបាត” នេះ?

[១១:៤៨:២៦]

**ឆៈ** ខ្ញុំមិនបានចាំថាខ្ញុំថា “មហាសន្និបាត” ប៉ុន្តែខ្ញុំ តាមដែលខ្ញុំចាំដែលខ្ញុំបាននិយាយថាដូចមិនមានមហាសន្និបាតចាត់តាំងអី ប្រចាំឆ្នាំ ប្រចាំ៦ខែនៃក្រសួងដូចដែលគេធ្លាប់ធ្វើទេបាទ។ ក៏ប៉ុន្តែគ្រាន់តែមានការប្រជុំធំ ហើយការចាត់តាំងអ្នកណាធ្វើជាប្រធានផ្នែក អ្នកណាមកក្នុងផ្នែកអីក៏ៗមានអត់ប្រកាសអីដែរបាទ។ ដូច្នេះមិនអាចថាបានមានៗ មហាសន្និបាត ឬសន្និបាតប្រចាំឆ្នាំ ប្រចាំប្រាំ៦ខែនៅក្នុងក្រសួង។ គ្រាន់តែមានការប្រជុំអប់រំរយៈវែង គឺថាពី១អាទិត្យអ៊ីចឹងទៅ ហើយក្នុងការប្រជុំរយៈវែងហ្នឹង គឺត្រូវបញ្ចប់ដោយមានពិធីផ្លងជីវទស្សន៍ៗ គឺថាផ្លងជីវទស្សន៍ ជីវទស្សនបដិវត្តន៍របស់សមាជិកម្នាក់ៗ ដែលបានចូលរួមក្នុងអង្គប្រជុំនេះបាទ។

**សៈ** សូមអរគុណ។ លោកក៏បាននិយាយផងដែរអំពីកិច្ចប្រជុំសាខាបក្ស ដែលមានលោក អៀង សារី ជាអ្នកដឹកនាំ គឺថារៀងរាល់១៥ថ្ងៃម្ដង បើសិនខ្ញុំបើមិនច្រឡំទេ។ តើអ្នកណាខ្លះជាអ្នកមចូលរួមនៅក្នុងកិច្ចប្រជុំសាខាបក្សនេះ គឺថាប្រហែលជាមានប៉ុន្មាននាក់ដែរ ដែលជាបក្ខជនចូលរួមនៅក្នុងកិច្ចប្រជុំបែបនេះនៅមន្ទីរប-១ នោះ?

[១១:៥០:១៥]

**ឆៈ** ខ្ញុំសូមបញ្ជាក់ទៀត គឺថាសាខាបក្សហ្នឹងមានពីរ។ សាខាបក្សរបស់មន្ទីរ១ ប-១ ហ្នឹង ហើយសាខាបក្សមួយទៀតរបស់ផ្នែកការងារទូត គឺហៅថាការិយាល័យ។ លោក អៀង សារី គាត់ចូលរួមប្រជុំសាខាបក្ស គឺថាសាខារបស់បក្សបក្ខជនទាំងពីរសាខាហ្នឹង អាហ្នឹងគាត់ធ្វើប្រធាន ក៏ប៉ុន្តែបើសាខាការិយាល័យហ្នឹង គឺគាត់មិនបានចូលរួមអីផ្ទាល់ទេ។ គាត់ទុកឲ្យតែលេខារបស់សាខាហ្នឹងប្រជុំ ហើយខ្ញុំដឹងបក្ខជននៅក្នុងសាខាខាងការិយាល័យហ្នឹង ខ្ញុំ -- ដូច្នោះខ្ញុំដឹងតែបក្ខជនទាំងនុ៎ងទេ។ គឺបក្ខជនហ្នឹង គឺថា មានខ្ញុំបាទ, មានមិត្ត អ៊ិន សុភាព -- លោក អ៊ិន សុភាព, មាន លោក គាត ឈន់, លោក ជួន ប្រាសិទ្ធ, លោក តូច ខាំឿន, លោក ពេជ្រ ប៊ុនរ៉េត, លោក សូ ផន។ សូ ផន គឺថាជាលេខារបស់

គាត់ផ្ទាល់។ ដូចមានតែប៉ុណ្ណឹងទេ។ ហើយមានម្នាក់ពីរទៀតមកនៅក្នុង -- មកពីមូលដ្ឋាន ខ្ញុំមិនសូវចាំទេបាទ។

[១១:៥២:០៣]

**ស៖** ដោយមិន -- តើលោកដឹងទេ ថាតើមានកិច្ចប្រជុំផ្សេងណាទៀតដែលមានលោក អៀង សារី ដែលជាប្រធាននោះ? គឺថាលោកបានបញ្ជាក់អម្បាញ់ថា សួរ សែ គាត់ជាអ្នកដឹកនាំកិច្ចប្រជុំ។

**ឆ៖** ខ្ញុំមិនដឹងជានៅសាខាបក្សនៃផ្នែកមន្ទីរគាត់បានចូលរួម មិនបានចូលរួមទេបាទ។ ប៉ុន្តែខ្ញុំថាគាត់ម្តង ឬពីរដងក្នុងប៉ុន្មានឆ្នាំហ្នឹង គឺថាគាត់បានប្រជុំអ្នកទទួលខុសត្រូវនៃផ្នែកទាំងពីរ។ ទាំងផ្នែកមន្ទីរ ទាំងផ្នែកការិយាល័យនៅក្នុងក្រសួងការបរទេសបាទ។

**ស៖** នៅក្នុងកិច្ចប្រជុំជាវៀងរាល់ខែរបស់សាខាបក្សនេះ តើមានផ្នែកណាមួយសម្រាប់ជាវគ្គជីវទស្សន៍គឺ គឺមានន័យថា ទិតៀន និងស្វ័យទិតៀនដែរឬទេ?

**ឆ៖** ការឆ្លងជីវទស្សន៍ធ្វើ ទិតៀន ស្វ័យទិតៀន ច្រើនធ្វើនៅក្នុងក្របខ័ណ្ឌប្រជុំរួមរយៈពេលយូរ។ រយៈពេលប្រជុំសាខារបស់បក្សប្រចាំខែនេះ គឺមិនមានធ្វើឆ្លងជីវទស្សន៍អីទេ គឺធ្វើតែទិតៀន និងស្វ័យទិតៀនតែប៉ុណ្ណោះបាទ។

[១១:៥៤:០៨]

**ស៖** ពាក់ព័ន្ធទៅនឹងកិច្ចប្រជុំទិតៀន និងស្វ័យទិតៀននេះ តើគេធ្វើបែបហ្នឹងដើម្បីគោលដៅអ្វីដែរ? លោកបានឆ្លើយថា មានការទិតៀន ឬក៏ស្វ័យទិតៀននៅក្នុងផ្នែករបស់លោក ហើយនិងនៅក្នុងផ្នែកសាខាបក្ស បើតាមការកត់សម្គាល់របស់លោកឃើញនោះ តើលោកដឹងទេ ថាតើកិច្ចប្រជុំទិតៀនស្វ័យទិតៀននេះ មានគោលដៅបែបណាដែរ?

**ឆ៖** គឺគោលដៅ គឺកសាងទស្សនៈបដិវត្តន៍ និងគោលជំហរបដិវត្តន៍របស់សមាជិកម្នាក់ៗ តាមគោលការណ៍ថែទាំជំងឺ ដើម្បីសង្គ្រោះមនុស្ស បាទ។ ព្រោះក្នុងអង្គការកុម្មុយនីស្តការកសាងទស្សនៈ និងលោកទស្សនៈគឺទស្សនៈបដិវត្តន៍ លោកទស្សនៈបដិវត្តន៍ ជាមូលដ្ឋាននៃការកសាង។ ហើយដើម្បីនឹងឲ្យមានជំហរបដិវត្តន៍ មានជំហរវណ្ណៈអធនរឹងមាំ និងច្បាស់លាស់។ នេះជាទិសដៅសំខាន់។ ទិសដៅបន្ទាប់បន្សំ គឺដើម្បីឲ្យបុគ្គលដែលទទួលការកសាងនេះមានស្មារតី និងមានឆន្ទៈមោះមុត ក្លៀវក្លា ដើម្បីបន្តបំពេញភារកិច្ច បម្រើបក្ស បម្រើបដិវត្តន៍ បម្រើប្រជាជនបាទ។

**ស៖** តើលោកយល់ការធ្វើទិតៀន បែបទិតៀនហ្នឹងយ៉ាងម៉េច? តើមានអ្នកផ្សេងគេទិតៀននឹង

លោកដែរឬទេ? តើការធ្វើបែបនេះជាការធ្វើមួយដែលមានលក្ខណៈងាយស្រួល ឬក៏ជាការងារដែលធ្វើឲ្យសមាជិកដែលចូលរួមក្នុងកិច្ចប្រជុំនុំងមានការភ័យខ្លាច?

[១១:៥៧:១១]

**ឆ៖** គឺតាមពិសោធន៍កន្លងមក ក្នុងផ្នែកខ្ញុំគឺ បើចំពោះខ្ញុំ -- បើចំពោះរូបខ្ញុំវិញ គេទិតៀនពីរចំណុច គឺថាអាហ្នឹងចៀសមិនផុតទេ។ រាល់ពេលប្រជុំ ហើយសឹងគ្រប់សមាជិកដែលចូលប្រជុំហ្នឹង គេទិតៀនខ្ញុំលើពីរចំណុច។ ចំណុចទី១ មានការអប់រំនៅបរទេស។ គឺក្នុងការអប់រំនៅបរទេស គឺមានទាំងពីទស្សនៈ មានទាំងរបៀបរបបរស់នៅ មានទាំងពីអាការដើរហ្នឹង បើថាយើងដើរក្រពាត់ដៃខាងក្រោយខ្នងអាហ្នឹងក៏គេទិតៀនដែរណេះ។ វាមានចំណុច បើថាយើងហូបបាយ យើងសម្លឹងតែចានយើង ក៏គេទិតៀនដែរ។ គឺថាបើថាយើងហូបបាយជុំគ្នា យើងត្រូវជូសបាយឲ្យគេមុន យើងមើលគេមុន មុននឹងយើងគិតគូរដល់ខ្លួនយើង។ ដូច្នោះវា -- ក្នុងការអប់រំនេះ គឺល្អិតណាស់ ហើយបើសិនជាម្នាក់ៗទទួលនូវការអប់រំនេះរាប់ឆ្នាំហ្នឹង ខ្ញុំឃើញស្រុកខ្មែរយើងប្រហែលទៅជាលោកសង្ឃទាំងអស់ មើលទៅបាទ។ អាហ្នឹងនេះ បើចំពោះខ្ញុំគេទិតៀនគឺថា ខ្ញុំទទួលការអប់រំពី -- តាំងពីសម្ដីសំដៅនិយាយស្ដីអ៊ីចឹង។

[១១:៥៨:៣៣]

ទី២ គឺថាទិតៀនអំពី មានគ្រួសារបរទេស ហ្នឹងទិតៀនពីរហ្នឹង។ ហើយអ្នកតិចណាស់ដែលមិនដែលមានទិតៀនខ្ញុំហើយស្រួលយល់ទេ អ្នកដែលមិនទិតៀនខ្ញុំហ្នឹងគឺថា គេមានឋានៈដូចខ្ញុំអ៊ីចឹងដែរ។ អាហ្នឹងការទិតៀន។ ក៏ប៉ុន្តែមនុស្សក្នុងការទិតៀននេះគឺថា វាមានទិដ្ឋភាពល្អដែរ គឺអ្នកខ្លះគឺថាខ្លាចដែរទិតៀនព្រោះមិនចង់ឲ្យគេទិតៀនអ៊ីចឹង ដូច្នោះចេះតែខំ។ ណេះ ចេះតែខំបំពេញភារកិច្ច ខំសម្របខ្លួនអ៊ីចឹងទៅ វាចេញជារឿងមួយផ្សេងទៅទៀត។ គឺរយៈពេលនុំងអ្នកណាដែលត្រង់ អ្នកណាដែល -- គឺថាគ្មានក្នុងគ្មានក្រៅ ខ្ញុំមិននិយាយតែកន្លែងខ្ញុំទេ ខ្ញុំនិយាយជាពិសោធន៍ទូទៅគឺដូចចេះតែមានបញ្ហា។ ប៉ុន្តែអ្នកគេប្រសប់ អ្នកខ្លះគេប្រសប់ដែរ គេចេះសម្របៗទៅ ប៉ុន្តែដល់ពេលសភាពការណ៍វាអនុគ្រោះ វាជារឿងបញ្ហាមួយទៀត។ អាហ្នឹងគឺថា ដូចថា ជាការវាយតម្លៃនៃការស្វ័យទិតៀន និងទិតៀន។ បាទ ខ្ញុំមិននិយាយវែងឆ្ងាយ ព្រោះរឿងហ្នឹងវាវែងឆ្ងាយតទៅទៀតបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសម្រាកដើម្បីពិសាថ្ងៃត្រង់ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញ

ចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលកន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សី ហើយនិងមេធាវីប្រឹក្សារបស់គាត់ ក្នុងអំឡុងពេលឈប់សម្រាកពិសាថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះនៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេី ប៉ោះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានទទួលព័ត៌មានថាលោក នួន ជា មានការឈឺក្បាល ឈឺនៅចង្កេះ ហើយមិនអាចមានការផ្តង់អារម្មណ៍បានទេ។ ដូច្នេះ គាត់ស្នើសុំចូលទៅនៅបន្ទប់ខាងក្រោមដើម្បីតាមដានដំណើរការនីតិវិធីនៅបន្ទប់ខាងក្រោមលោកប្រធាន។

[១២:០១:១៦]

**ប្រធានអង្គជំនុំ៖**

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការនៅរសៀលនេះ។

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយលោក នួន ជា បានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យមេធាវីការពារក្តីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាម នូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

[១២:០២:០៥]

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈ

ពេលដំណើរការសវនាការនៅរសៀលនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកលោក នួន ជា ឲ្យនៅក្នុងបន្ទប់ ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៣ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:២៩]

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និង--

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល។ សូមអធ្យាស្រ័យដោយសារឡើងមកកាត់បន្តិច។ ពីព្រឹកមិញ ខ្ញុំមានការកត់សម្គាល់មួយ ឃើញថា មានការបកប្រែពីភាសាខ្មែរ មកភាសាអង់គ្លេស មានការខុស។ ហើយខុសនេះ វាកំហុសធ្ងន់ធ្ងរ ហើយចំណុចត្រង់នោះ ចំណុចត្រង់ថា សាក្សីគាត់បាននិយាយថា “សត្រូវខ្លាំងសត្រូវដែលសំខាន់ និងធំជាងគេបំផុតនោះ គឺខ្លាំងសត្រូវដែលនៅក្នុងពួដខ្លួនយើង ខ្លួនឯងផ្ទាល់ ដែលយើងត្រូវ -- ដែលបុគ្គលម្នាក់ៗត្រូវតែលុបបំបាត់ និងជម្រះ”។ ក៏ប៉ុន្តែភាសាអង់គ្លេសទៅជាបកប្រែថា “ត្រូវតែលុបបំបាត់ ជម្រះអ្នកទាំងឡាយណាដែលមានភាពជាខ្មាំងសត្រូវនៅក្នុងខ្លួនទៅវិញ”។ អានេះខុសគ្នា។

[១៣:៣៣:២១]

តាមសាក្សី គាត់ថា "ត្រូវលុបបំបាត់ភាពជាខ្មាំងសត្រូវរបស់បុគ្គលរបស់ខ្លួនយើងម្នាក់ៗ" ប៉ុន្តែ បកប្រែអង់គ្លេសទៅជា "ត្រូវលុបបំបាត់អ្នកទាំងឡាយណា ដែលមានភាពជាសត្រូវខ្មាំង នៅក្នុងខ្លួនយើងទៅវិញ"។ នេះខ្ញុំសូមជម្រាប ហើយសូមបញ្ជាក់ពីកំហុសនៃការបកប្រែនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយដោយសារភាសាអង់គ្លេង និងភាសាបារាំង ជាភាសាបកប្រែ ព្រោះសាក្សីបានឆ្លើយច្បាស់លាស់ ហើយខ្លឹមសារ គឺដូចលោកមេធាវីបានបង្ហាញអម្បាញ់មិញអ៊ីចឹង គឺគាត់បានឆ្លើយច្បាស់អំពីខ្មាំងក្នុងខ្លួនផ្ទាល់ម្នាក់ៗនេះឯង ដែលមានខ្លឹមសារមិនដូចគ្នានឹងភាសាអង់គ្លេស ដែលបកប្រែជាភាសា -- ចេញពីភាសាខ្មែរ ដែលជាសម្ដីរបស់សាក្សីរបស់និយាយនោះទេ។ បាទ បញ្ហានេះគឺយើងនឹងពិនិត្យ ដើម្បីធ្វើការកែសម្រួលលើប្រតិចារឹកដែលមានបញ្ហាដូច្នេះ។

បាទ អង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅលោកតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

[១៣:៣៤:៥០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម ជាទីគោរព!

មុននឹងពេលសម្រាកថ្ងៃត្រង់នេះ យើងបាននិយាយអំពីវគ្គជីវទស្សន៍ ទិតៀន និងស្វ័យទិតៀន។ ហើយសាក្សី លោកបានរៀបរាប់ថា លោកត្រូវបានគេរិះគន់ទិតៀន ដោយមូលហេតុជាច្រើន ដោយសារលោកទទួលការអប់រំនៅបស្ចិមប្រទេស និងលោកមានភរិយាជាជនជាតិបរទេស។ តើការទិតៀនដដែលៗប្រឆាំងទៅនឹងបក្ខជនម្នាក់ អាចបណ្ដាលឲ្យមាន -- នៅពេលចុងក្រោយនោះ គឺថាមានការដាក់ទណ្ឌកម្ម ឬក៏ការស៊ើបសួរអង្កេត ឬក៏តាមដានពិសេសណាមួយ។ តើករណីនេះធ្លាប់មានដែរឬទេ?

**ឆ៖** មិនមានទេ ព្រោះនេះគ្រាន់តែបញ្ហាទិតៀនមិនមែនជា ខ្ញុំបានប្រព្រឹត្តិអំពើជាក់ស្ដែងខុសពីមាគ៌ា ឬខុសពីសេចក្ដីច្បាប់រដ្ឋទេបាទ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំចង់បង្ហាញនូវសាក្សីនូវឯកសារមួយទៀត ដែលគាត់បាន ខ្លួនគាត់ផ្ទាល់បានដាក់ជូនសហចៅក្រមស៊ើបអង្កេត គឺជា នេះគឺជាឯកសារព្រាងរបស់គាត់ គឺថាឯកសារដែល មាន "ខ្សែជីវិត

អ្នកបដិវត្តន៍” គឺថា E3/40 ហើយនិង IS3.9 វគ្គដែលយើងចាប់អារម្មណ៍នោះគឺថា ដែលខ្ញុំចង់បង្ហាញនៅអេក្រង់នោះ នៅទំព័រជាភាសាខ្មែរ គឺថា 00583628, ជាភាសាបារាំង គឺ 00079025 ទៅដល់ 26 នៅចុងក្រោយ, ហើយភាសាអង់គ្លេស 00813097។

[១៣:៣៧:៣៦]

បាទ ខ្ញុំមានសំណួរមួយ ដែលយើង -- ជាសំណើរជាភាសាបារាំង ដែលសរសេរដោយដៃគាត់តែម្តង ហើយយើងមានការបកប្រែជាមកជាភាសាខ្មែរ ដោយ អាយ.ធី.យូ យើងនេះ។ ខ្ញុំមិនដឹងថាយើងត្រូវបញ្ជូនឯកសារជាសំណៅជាភាសាអីទេ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ហើយបើសិនជាមានទាំងពីរលោកអាចជូនសាក្សីទាំងពីរទៅ ដើម្បីឲ្យគាត់ពិនិត្យមើល។ ជាពិសេសគឺឯកសារដើម ដែលជាភាសាបារាំង ដែលគាត់ដែលជាអ្នកសរសេរដោយផ្ទាល់ដៃរបស់គាត់។

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

[១៣:៣៨:២៧]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេះ**

**សៈ** ដើម្បីឲ្យគ្រប់ជ្រុងជ្រោយ លោកសាក្សី គឺថាមិនមែនជាសំណៅជាចុងបញ្ចប់នៃអត្ថបទសរសេរដៃរបស់លោកទេ ដែលគឺថាគឺជាសំណៅមួយដែលលោកសរសេរបានមុនហ្នឹងបន្តិច ពីព្រោះថាវាមិនមែនជាអត្ថបទទាំងមូលនោះទេ គឺជាសម្រង់។ ប្រហែលជាលោកអាចប្រាប់យើងថា នេះជាសំណៅនៃអត្ថបទសរសេរដៃរបស់លោក ដែលមានចំណងជើងថា“ខ្សែជីវិតបញ្ញាជនខ្មែរក្រហមម្នាក់”។

**លោក សួង ស៊ីគឿន៖**

**ឆៈ** បាទ សូមជម្រាបថា អត្ថបទដែលខ្ញុំមាននៅដៃនេះ ជាអត្ថបទដែលខ្ញុំសរសេរព្រាងតាមការកំណត់របស់សាកលវិទ្យាល័យប៉ារីសទី១០ ម៉ុងទែរ នៅឆ្នាំ២០០០ ដើម្បីខ្ញុំបានបន្តធ្វើជាបេក្ខជនសម្រាប់បណ្ឌិតខាងចិត្តសាស្ត្រនយោបាយ។ នៅទីនោះ គេតម្រូវឲ្យខ្ញុំសរសេរចំនួន ៤០ទំព័របាទ។

[១៣:៤០:០៤]

**សៈ** បាទ សូមអរគុណលោកសាក្សី។ ខ្ញុំសូមឲ្យលោកអានជាទំព័របារាំង មើលទំព័របារាំងថាទំព័រ៤០-៤១ ដែលមានលេខ ERN 00079025 ដល់ 26 នៅចុងក្រោយ។ លេខរបស់លោក --

លេខទំព័ររបស់លោកគឺថា៤០-៤១។ នៅពេលនោះ លោកនិយាយអំពីកិច្ចប្រជុំជីវទស្សន៍ដែលគេទិតៀន លោកជាច្រើនចំណុច ហើយនៅចុងទំព័រ៤០នេះ គឺថាខ្ញុំនឹងអានសម្រង់នេះ លោកនិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "យើងរស់នៅក្នុងភាពភ័យខ្លាច ខ្លាចធ្វើអ្វីមិនល្អ ហើយនិងការធ្ពោះធ្លយ ឬក៏ការភ្លេចភ្លាំងនៅក្នុងការបំពេញភារកិច្ចរបស់ខ្លួន បញ្ចប់ភារកិច្ចរបស់ខ្លួន ហើយដែលថាអ្នកដែលធ្វើនោះអាចនឹងគ្រោះថ្នាក់ធំ ពីព្រោះថា យើង -- គេអាចបកស្រាយថាជាទង្វើវិទ្ធង្សនា ឬក៏ក្បត់។ រស់នៅក្នុងបរិយាកាសបែបនេះ គឺថាវាពិបាកនឹងទ្រាំទ្រណាស់។ ខ្ញុំមានអារម្មណ៍ថា ការទទួលការអប់រំបែបបស្ចិមប្រទេស ហើយនិងការរៀបការជាមួយនារីបរទេសនេះ វាធ្វើ -- វាហាក់ដូចជាពិការភាពរបស់ខ្ញុំមួយ ដែលខ្ញុំមិនអាចឆ្លងកាត់បាន។

[១៣:៤១:៤២]

**ប្រធានអង្គជំនុំ៖**

សូម សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីចៅក្រមជាទីគោរព។ ខ្ញុំសោកស្តាយដែលបានកាត់ផ្តាច់លោកសហព្រះរាជអាជ្ញា។ ខ្ញុំជំទាស់ ព្រោះថាយើងយល់ស្របថាឯកសារដែលយើងប្រើនេះ គឺជាឯកសារដែលអង្គជំនុំជម្រះបានចេញសេចក្តីសម្រេចហើយ។ ហើយដែលសម្រេចនោះ បញ្ជាក់ថា វាវត្ថុជាក់លាក់មួយចំនួនដែលអាច -- សហព្រះរាជអាជ្ញាអាចប្រើប្រាស់បានក្នុងការចោទសំណួរទៅសាក្សី សួង ស៊ីគឿន។ ក៏ប៉ុន្តែវាហាក់ដូចជាទំព័រដែលសហព្រះរាជអាជ្ញាទើបតែអាននេះ ជាទំព័រដែលជាផ្នែកខាងតុលាការអនុញ្ញាតនោះទេ។ អ៊ីចឹង ខ្ញុំគ្រាន់តែសុំជំទាស់ក្នុងចំណុចនេះ ដើម្បីកុំឲ្យទៅពេលក្រោយ កុំឲ្យមានការលំបាក។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប ខ្ញុំគិតថាមានការច្រឡំឯកសារពីរ។ ឯកសារនេះ គឺថានៅក្នុងសំណុំរឿងយូរណាស់ហើយ ហើយត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះ ហើយលេខ E3/40។ ហើយសំណើ E216 មានទាំងស្រុងតែម្តង គឺឯកសារជាសរសេរដោយដៃរបស់លោកសាក្សីនេះដែលមានចំណងជើងថា "ខ្សែជីវិតអ្នកបដិវត្តន៍ខ្មែរក្រហម" ហើយនៅលើសំណៅនេះ ដែលមាន៣០០ទំព័រ។ ហើយអង្គជំនុំជម្រះចេញសម្រេចលើសំណៅនេះ ហើយឯកសារដែលខ្ញុំដាក់បង្ហាញនេះ គឺថាមាននៅ

ក្នុងសំណុំរឿងរួចហើយ ហើយៗមិនមានការជជែកតវ៉ាជំទាស់អីនោះទេ។

[១៣:៤៤:០២]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទសូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ ខ្ញុំអានសម្រង់នៃឯកសារសរសេរដោយដៃដោយលោក លោកសាក្សី។ តើវគ្គទិតៀនស្វ័យទិតៀនេះមិនបណ្តាលឲ្យមានបរិយាកាសភ័យខ្លាច ហើយនិងការឆ្លើយដាក់គ្នាទៅលើបក្ខជន ឬក៏អ្នកចូលរួមទៅក្នុងកិច្ចប្រជុំទាំងអស់នោះទេឬ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** មិនមានទេ ព្រោះអ្នកចូលរួមជាច្រើនាក់សុទ្ធតែមានសភាពការណ៍ដូចខ្ញុំដែរបាទ។ គឺមានការអប់រំនៅបស្ចិមប្រទេស ហើយមានគ្រួសារ មានប្រពន្ធជាជនជាតិបរទេស។

[១៣:៤៥:០០]

ហើយយើងខ្ញុំបំពេញភារកិច្ច និងធ្វើការងារនៅក្រោមការដឹកនាំរបស់លោក អៀង សារី។ លោក អៀង សារី គាត់ធ្លាប់បានទៅរៀនសូត្រនៅប្រទេសបារាំង ដូច្នោះគាត់មិនមានអីដូចថា តឹងតែង ឬមានគំនិតសង្ស័យពីចំណុចនេះទេ។ ព្រោះគាត់ស្គាល់ពួកយើងទាំងអស់គ្នាច្បាស់ណាស់បាទ។

**ស៖** បាទ ឥឡូវនេះខ្ញុំសូមចូលទៅនិយាយជំពូកថ្មីមួយទៀត តើលោកដឹងអ្វីខ្លះអំពីគណៈកម្មាធិ-ការអចិន្ត្រៃយ៍នៃគណៈមជ្ឈិមចន្លោះឆ្នាំ៧៥ ដល់៧៩?

**ឆ៖** ខ្ញុំមិនបានដឹងអីទេ ខ្ញុំគ្រាន់ដឹងថា លោក អៀង សារី ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈមជ្ឈិម តែគាត់ម្នាក់ប៉ុណ្ណឹង។ អ្នកផ្សេងទៀតខ្ញុំមិនបានទេបាទ ហើយតាមស្ថានមើលគឺអាហ្នឹងមិនជាការពិបាកអីទេអាហ្នឹង គឺថាៗ ប៉ុល ពត ហើយនិងលោក នួន ជា ក៏នៅក្នុងដែរ។ អាហ្នឹងខ្ញុំសន្និដ្ឋាន ប៉ុន្តែម្នាក់ទៀត ខ្ញុំអត់ច្បាស់ទេបាទ។

[១៣:៤៦:៤៧]

**ស៖** តើលោក ហេតុអ្វីបានជាលោកដឹងថា អៀង សារី, ប៉ុល ពត, នួន ជា ហ្នឹងស្ថិតនៅក្នុង

គណៈអចិន្ត្រៃយ៍?

**ឆ៖** គឺខ្ញុំដឹងច្បាស់គឺថា--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

**លោក ហ្សាស្តេី ប៉ោះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរដែលលើកឡើងដោយព្រះរាជអាជ្ញា ដោយសារតែសក្ខីកម្មរបស់សាក្សីថា គាត់ -- ព្រះរាជអាជ្ញាបានលើកឡើងថា សាក្សីដឹងថា ប៉ុល ពត, នួន ជា, អៀង សារី គឺជាសមាជិកនៃគណៈអចិន្ត្រៃយ៍។ ប៉ុន្តែការពិតសាក្សីគាត់និយាយថា គាត់ស្មាន ឬក៏គាត់សន្និដ្ឋានថា ប៉ុល ពត, នួន ជា គឺជាសមាជិកប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំស្នើដល់ព្រះរាជអាជ្ញាសូមមេត្តារៀបចំសំណួរសាជាថ្មីឡើងវិញ។ សូមអរគុណ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** តើលោកដឹងថា អ្នកទាំងអស់ហ្នឹងនៅក្នុងគណៈអចិន្ត្រៃយ៍ហ្នឹងតាមរបៀបណា? តើលោកបានប្រភពព័ត៌មាននោះដោយផ្ទាល់ ឬក៏ដោយប្រយោល?

[១៣:៤៨:០៨]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំដឹងថាដោយផ្ទាល់ពីគាត់ចុះ ព្រោះពីលោក អៀង សារី ដែលជាអ្នកទទួលខុសត្រូវផ្ទាល់ជាមួយខ្ញុំ ថាគាត់ជាសមាជិកអចិន្ត្រៃយ៍នៃមជ្ឈិមបក្ស។ ហើយព្រោះគាត់នៅតាមក្រឹត្យក្រមនេះ គាត់នៅក្រោម ប៉ុល ពត និងលោក នួន ជា។ ដូច្នេះខ្ញុំសន្និដ្ឋានថា អ្នកទាំងពីរខាងលើនេះ ក៏ជាសមាជិកគណៈអចិន្ត្រៃយ៍របស់បក្ស -- របស់មជ្ឈិមបក្សដែរបាទ។

**ស៖** តែបើតាមលោកដឹង ឬក៏តាមពាក្យចចាមអារ៉ាមនោះ តើមានអ្នកផ្សេងទៀតនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នេះដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាថា ក្នុងឋានៈជាសមាជិកបក្ស យើងដឹងអំពីអ្វីដែលបក្សឧទ្ទេសនាមប្រាប់យើង។ ដូច្នោះមិនមាននរណាឧទ្ទេសនាមប្រាប់ថា លោកនេះ លោកនោះជា -- ប្រាប់ខ្ញុំថា លោកនេះ លោកនោះជាសមាជិកអចិន្ត្រៃយ៍នៃគណៈមជ្ឈិមបក្សទេ។ ហើយដែលខ្ញុំដឹងលោក អៀង សារី នេះគឺថា ដោយខ្ញុំដឹងច្បាស់ថា គាត់ជា -- បើយើងនិយាយទៅគឺថា គាត់ក្នុងចលនាបដិវត្តន៍

ចំណោមពួកបញ្ញាជនដែលមកពីស្រុកបារាំងហ្នឹង គាត់លើកលែងតែលោក វ័ត្ន សាមឿន និងលោក កេង វ៉ាន់សាក់ គាត់ជាអ្នកដូចថាបដិវត្តន៍ដើងចាស់ជាងគេបាទ។

**សៈ** តើលោកបានធ្លាប់ឮគេនិយាយអំពី អៀង សារី អំពីតួនាទីគណៈអចិន្ត្រៃយ៍នៅក្នុងការរៀបចំបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆៈ** ខ្ញុំមិនបានដឹងទេ ប៉ុន្តែគ្រាន់ដឹងថាគាត់ទទួលខុសត្រូវខាង ខាងកិច្ចការបរទេសរបស់មជ្ឈិមបក្ស ទី១ ហើយជាពិសេសចំពោះបញ្ញាជនដែលមកពីប្រទេសបារាំង ដែលធ្លាប់ជាសមាជិកនៃវង់ម៉ាក្ស-ឡេនីន នេះ គឺដែលគាត់ជាអ្នកបង្កើតហ្នឹង គឺគាត់ទទួលខុសត្រូវ គាត់គឺថា គាត់ជាអ្នកដូចថា ទទួលខុសត្រូវខាងពួកយើង គឺយើងខ្ញុំនេះបាទ។

[១៣:៥១:១៩]

ខ្ញុំសូមបញ្ជាក់ពាក្យ "ទទួលខុសត្រូវ" ដែលខ្ញុំនិយាយនេះ ដូចខ្ញុំន៎ ទទួលខុសត្រូវនេះចង់និយាយថា មិនមែនទទួលខុសត្រូវដូចខ្ញុំបានបញ្ជាក់ទេ គឺថាអ្នកទទួលខុសត្រូវមជ្ឈិមដូចថា ពួកខ្ញុំនេះជាបញ្ញាជនដែលមជ្ឈិម ទទួលខុសត្រូវចំពោះមជ្ឈិមបក្ស។ ចំពោះមជ្ឈិមបក្ស មានន័យថាចំពោះ ប៉ុល ពត តែម្ដងបាទ។ ដូច្នោះ ប៉ុល ពត ក៏អ្នក ជាអ្នកសម្រេចចាត់តាំងយើងឲ្យទៅធ្វើការនៅកន្លែងណាៗ គឺថាគាត់ជាអ្នកចាត់តាំង ហើយលោក អៀង សារី គ្រាន់តែអ្នកដែលទទួលខុសត្រូវផ្ទាល់របស់យើងទាំងអស់គ្នាក្នុងកិច្ចការបំពេញភារកិច្ចទេ។ ហើយការនេះគឺថាចំពោះខ្ញុំ ក៏ដូចចំពោះបញ្ញាជនឯទៀតដែលមកស្រុកបារាំងដែរបាទ។

**សៈ** នៅពេលដែលលោកនិយាយអំពីការសម្រេចរបស់ ប៉ុល ពត តើលោកចង់និយាយអំពីការសម្រេចដែលគាត់ធ្វើដោយខ្លួនឯងម្នាក់ឯង ឬក៏ដោយស្របតាមលក្ខន្តិកៈបក្ស ដែលថាត្រូវធ្វើសេចក្ដីសម្រេចជាសមូហភាព?

[១៣:៥២:៤៩]

**ឆៈ** តាមមើល តាមដែលខ្ញុំដឹង ដូចមិនពិបាកអីទេ ព្រោះសម្រេច -- ព្រោះអ្នកដែលមកពីស្រុកបារាំង សុទ្ធតែគាត់បញ្ញាជនដែល បញ្ញាជនកុម្មុយនីស្តដែលមកពីស្រុកបារាំង គាត់ក៏ធ្លាប់ស្គាល់ដែរ។ ដូច្នោះគាត់ស្គាល់ម្នាក់ៗហ្នឹង គឺថាគាត់ចាំបាច់សួរមតិអ្នកណាទេ តាមមើលទៅគាត់សម្រេចបានទេបាទ។

**សៈ** បាទឥឡូវខ្ញុំចោទសំណួរឡើងវិញ។ ខ្ញុំនិយាយអំពី ប៉ុល ពត អម្បាញ់មិញ ដែលលោក

និយាយថា ប៉ុល ពត ធ្វើសេចក្ដីសម្រេច។ តើគឺជាសេចក្ដីសម្រេចដែល ប៉ុល ពត សម្រេចតែម្នាក់ឯង ឬក៏ដូចដែលមានចែងនៅក្នុងមាត្រា៦ នៅលក្ខន្តិកៈបក្សហ្នឹង គឺត្រូវធ្វើសេចក្ដីសម្រេចជាសមូហភាព?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប! សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់។ ប្រសិនបើព្រះរាជអាជ្ញាចង់ចោទសួរ ថាតើការធ្វើសមូហភាពហ្នឹងធ្វើដោយរបៀបណា? គាត់អាចចោទសួរថាតើសាក្សីដឹងថាមានការប្រជុំជាសមូហភាព ឬក៏បានស្គាល់អំពីការប្រជុំជាសមូហភាព? ប្រសិនបើមិនសួរដូច្នេះទេ គឺហាក់ដូចជាការឲ្យស្មានទៅលើអ្វីដែល ប៉ុល ពត បានធ្វើ។ សូមអរគុណ។

[១៣:៥៤:៣១]

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ព្រោះថាអម្បាញ់មិញនេះសាក្សីនិយាយថា មានសេចក្ដីសម្រេចមួយចំនួនដែល ប៉ុល ពត ធ្វើដោយខ្លួនឯង។ អ៊ីចឹងហើយខ្ញុំចង់ដឹងថា តើនៅក្នុងក្របខ័ណ្ឌណាខ្លះ ដែលមានធ្វើការសេចក្ដីនេះ? ហើយចង់សួរថាតើគាត់ដឹងតាមវិធីណាដែរ?

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់មិនសមស្រប។ សេចក្ដីជំទាស់គ្មានប្រសិទ្ធភាព។ សាក្សីត្រូវឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាចុងក្រោយអម្បាញ់មិញនេះ!

**លោក សួង ស៊ីគឿន**

**ឆ៖** ខ្ញុំមិនបានដឹងច្បាស់ទេ ប៉ុន្តែខ្ញុំធ្លាប់រស់នៅជាមួយគាត់ ខ្ញុំក៏ក្តាប់បានវិធីដែលគាត់សម្រេចអីខ្លះដែរ មិនមែនថាគាត់សម្រេចស្អីៗមិនសួរមតិដទៃទៀតទេ។ ប៉ុន្តែបញ្ហាខ្លះវាមិនចាំបាច់សួរទេ ព្រោះអាចសម្រេចបានដែរ ដូចខ្ញុំនិយាយអំមិញច្បាស់អំពីបញ្ញាជន។ បញ្ញាជនកុម្មុយនីស្តដែលមកពីស្រុងបារាំងវិញ ដែលខ្ញុំនិយាយពីករណីច្បាស់អ៊ីចឹងបាទ។ គាត់ស្គាល់ម្នាក់ៗច្បាស់ ដូច្នោះសមត្ថភាពទាំងគោលជំហរនយោបាយទាំងអី ពេលនោះគាត់ធ្វើសេចក្ដីសម្រេចដោយមិនចាំបាច់ គឺថាសួរមតិអ្នកណាក៏បានដែរបាទ។ ប៉ុន្តែឲ្យថា ឲ្យខ្ញុំដឹងច្បាស់ថា ឥឡូវគាត់សម្រេចចំពោះអ្នកនេះ តែម្នាក់ ឬមានពិគ្រោះ

មតិជាមួយអ្នកណាផ្សេងទៀត អាហ្នឹងខ្ញុំមិនអាចឆ្លើយបានទេបាទ។

[១៣:៥៦:២២]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯលៈ**

**ស៖** បាទ ដើម្បីបំភ្លឺលោកសាក្សីព្រោះថា ខ្ញុំមិនសូវច្បាស់ទេ។ លោកនិយាយអំពី ប៉ុល ពត នៅក្នុងចម្លើយរបស់លោក អ៊ីចឹងមែនទេ អម្បាញ់មិញនេះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ខ្ញុំនិយាយអំពី ប៉ុល ពត គាត់ធ្វើសេចក្ដីសម្រេចចំពោះបញ្ហាជនដែលមកពីស្រុកបារាំងបាទ។

**ស៖** បាទ សូមអរគុណ។ លោកដែលលោកធ្វើការនៅមន្ទីរប-១ តើនៅក្រៅ -- ក្រៅពីធ្វើទស្សនកិច្ចនៅបរទេសនោះ តើលោក អៀង សារី អវត្តមានជាញឹកញាប់នៅប-១ ដើម្បីប្រជុំជាមួយនឹងថ្នាក់ដឹកនាំផ្សេងទៀតនៃបក្សដែរឬទេ?

**ឆ៖** បាទ ធម្មតាទេ គាត់ទទួលកិច្ចការបរទេស។ ដូច្នោះ គាត់មិនបានស្ថិតនៅក្នុងប្រទេសជាប់លាប់ដូចកម្មាភិបាល និងអ្នកដឹកនាំដទៃទេបាទ។

**ស៖** បាទ ដូច្នេះ ខ្ញុំនិយាយអំពីប្រជុំជាមួយថ្នាក់ដឹកនាំផ្សេងទៀតនៃបក្សកុម្មុយនីស្តកម្ពុជា តើគាត់ប្រជុំជាច្រើនដងជាមួយនឹងអ្នកទាំងអស់នេះ ហើយនៅកន្លែងណាដែរ?

**ឆ៖** លោកប្រធាន សូមឲ្យលោកព្រះរាជអាជ្ញាគាត់បញ្ជាក់ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដឹកនាំនៅ ប-១ ឬដឹកនាំទូទៅប្រទេសបាទ?

[១៣:៥៨:២៩]

**ស៖** បាទ ខ្ញុំនិយាយអំពីប្រទេសទាំងមូលតែម្ដង គឺថា ឧទាហរណ៍ដូចជា បក្ខជនជាសមាជិកគណៈអចិន្ត្រៃយ៍ជាដើម ដូចដែលលោកបានលើកឡើងអម្បាញ់មិញនេះ?

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។

**ស៖** នៅជិតគណៈអចិន្ត្រៃយ៍ តើមានគណៈសន្តិសុខដែរឬទេ នៅក្នុងមជ្ឈិមបក្សដដែល?

**ឆ៖** ខ្ញុំមិនបានដឹងអំពីការចាត់តាំងច្បាស់លាស់នៃមជ្ឈិមបក្សទេបាទ។ មិនដឹងមានគណៈកម្មាធិការសន្តិសុខ យ៉ាងម៉េចៗ ខ្ញុំមិនបានដឹងទេ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំចង់បង្ហាញឯកសារមួយទៅសាក្សី -- ឯកសារពីរ សូមទោស។ គឺថា ឯកសារទី១ គឺជាចម្លើយទី២ របស់គាត់ចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺថាឯកសារ D91/26 មិនទាន់មានលេខកូដ E3 នៅឡើយទេ។ ជាភាសាបារាំងគឺថា ទំព័រទី៥។ ជាភាសាខ្មែរទំព័រ 00204153, ជាភាសាអង់គ្លេស 00223642។ នេះ គឺជាឯកសារទី១ ហើយខ្ញុំសូមអនុញ្ញាតបញ្ចាំងទៅលើអេក្រង់។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកទៅជូនសាក្សីពិនិត្យ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ នេះសម្រង់ដូចតទៅនេះ៖ "បើតាមខ្ញុំដឹងគណៈសន្តិសុខរបស់បក្សផ្សំឡើងដោយលោក ប៉ុល ពត, នួន ជា និង សុន សេន"។ បាទ សូមបញ្ចប់ការដកស្រង់។

ខ្ញុំចង់បង្ហាញឯកសារមួយទៀតនៅឯកសារដែលខ្ញុំបានដាក់ជូនសាក្សីហើយគឺថា E3/42 ឬក៏ D167 ទំព័រដែលខ្ញុំចាប់អារម្មណ៍នោះ គឺជាភាសាខ្មែរគឺថា 00327208, ជាភាសាអង់គ្លេសគឺ 003272 18 និងជាភាសាបារាំង គឺទំព័រទី៧។

[១៤:០២:១៥]

**លោក ស្លុង ស៊ីគឿន៖**

បាទ អរគុណ។

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ ខ្ញុំសូមបញ្ចាំងចម្លើយទី២ នេះទៅលើអេក្រង់ លោកប្រធាន សូមអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បាទ នេះចម្លើយទី២ របស់លោក លោកសាក្សី។ លោកនិយាយដូចតទៅនេះ៖ "គណៈកម្មាធិការសន្តិសុខមាន ប៉ុល ពត, នួន ជា, សុន សេន ហើយបន្ទាប់ពី សុន សេន ទៅសមរភូមិនៅបូព៌ា

វន វ៉េត រហូតដល់ចាប់ខ្លួនគាត់"។ សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើមុខងារគណៈសន្តិសុខនេះជាអ្វី? មានមុខងារអ្វីខ្លះ?

**លោក សួង ស៊ីគឿង៖**

**ឆ៖** ខ្ញុំមិនបានដឹងទេ ហើយសមាសភាពនេះ ខ្ញុំដឹង ពេលដែលខ្ញុំនៅទីនោះ ខ្ញុំអត់បានដឹងទេ។ អ្វីៗជាច្រើន ខ្ញុំក្រោយឆ្នាំ១៩៧៩ ទេបាទ សូមជម្រាប។

**ស៖** តើអ្នកណាជាប្រាប់លោកនៅឆ្នាំ៧៩ នោះថាជាអ្នកនៅជាសមាសភាពនៃគណៈសន្តិសុខនេះ?

**ឆ៖** ខ្ញុំមិនចាំថានរណាប្រាប់ខ្ញុំទេ ប៉ុន្តែវាមានសារព័ត៌មាន ហើយសៀវភៅខ្លះ ដែលបានសរសេរពីបញ្ហានេះដែរ ប៉ុន្តែថាឲ្យខ្ញុំចាំថាសារព័ត៌មានណា សៀវភៅណា ខ្ញុំមិនចាំទេបាទ។

**ស៖** នៅចន្លោះឆ្នាំ៧៥ និងឆ្នាំ៧៩ តើលោកធ្លាប់ឮគេនិយាយអំពីមន្ទីរ៨៧០ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំឮមន្ទីរ៨៧០ ហ្នឹង គឺខ្ញុំឮ ហើយការទាក់ទងខ្លះគឺម្នាក់ដែលឈ្មោះ ប៉ង់ ហ្នឹងណ៎ាគាត់នៅ ដឹងថាគាត់នៅមន្ទីរដែលខ្ញុំដឹងច្បាស់គឺគាត់នៅមន្ទីរ៨៧០ ព្រោះគាត់បាន នែ៎ ក្នុងរយៈពេលមួយនោះ ខ្ញុំមិនចាំឆ្នាំទេ ខ្ញុំមិនចាំកន្លែងទេ ប៉ុន្តែកន្លែងធ្វើការ គាត់បានឌុបម៉ូតូខ្ញុំពីកន្លែងដែលខ្ញុំធ្វើការហ្នឹងទៅធ្វើការជាមួយ ប៉ុល ពត មកក្រសួងការបរទេសវិញបាទ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ ដឹងថាមន្ទីរ៨៧០ហ្នឹងមានឈ្មោះ ប៉ង់ ហ្នឹងបាទ ជាអ្នកគឺថាធ្វើជាប្រចាំការនៅទីនោះ។

[១៤:០៥:៤៩]

**ស៖** តើមន្ទីរ៨៧០នេះ មានទីតាំងនៅឯណា? សូមទោស មន្ទីរដែលលោកជិះម៉ូតូទៅហ្នឹង តើមានទីតាំងនៅឯណា? ហើយមន្ទីរហ្នឹងមានឈ្មោះដែរឬទេ?

**ឆ៖** មិនជាមន្ទីរទេ ដែលគាត់ឌុបម៉ូតូខ្ញុំនោះ ជាកន្លែងទទួលភ្ញៀវ អាច-- ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែអាចជាវិមានរដ្ឋាភិបាល គេហៅថា ប-២ បាទ។ ប-២ ហ្នឹងឥឡូវអាផ្ទះទេសាភិបាលបាវាំងនៅមាត់ទន្លេនោះណ៎ា បាទផ្ទះហ្នឹងបាទ។ ហើយខ្ញុំចាំប្រហែលផ្ទះហ្នឹង ព្រោះបើថា ប៉ុល ពត គាត់ទទួលភ្ញៀវ គាត់ទទួលនៅហ្នឹង។

**ស៖** តើ ប៉ុល ពត គាត់ធ្វើការនៅកន្លែងណាដែរនៅសម័យនោះ? តើលោកដឹងទេ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងទេបាទ។

**ស៖** នៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់លោក តើលោកធ្លាប់ទៅកន្លែងណាដែលមេដឹកនាំដូចជា

ប៉ុល ពត, ខៀវ សំផន, នួន ជា ដែលនៅពេលដែលលោកទៅធ្វើជាអ្នកបកប្រែនោះ សូមឱ្យលោករៀបរាប់។

**ឆ៖** ខ្ញុំទៅបកប្រែឱ្យ ប៉ុល ពត នៅផ្ទះហ្នឹង ផ្ទះអំមិញហ្នឹង គឺថាវិមានរដ្ឋាភិបាលផ្ទះនៅមាត់ទន្លេហ្នឹង ពីដើមគេហៅ ជំនាន់សង្គមរាស្ត្រនិយម គឺថាជាវិមានរដ្ឋាភិបាល។ ជំនាន់បារាំងគឺថា ផ្ទះទេសាភិបាលបារាំងប្រចាំប្រទេសកម្ពុជាហ្នឹងបាទ។ ដល់ ប៉ុល ពត គាត់ធ្វើការនៅទីនោះ ខ្ញុំទៅបកប្រែឱ្យគាត់ពេលដែលគាត់ទទួលគណៈប្រតិភូនារីវៀតណាមមកទស្សនកិច្ច នៅប្រទេសកម្ពុជានៅឆ្នាំ ដូចដើមឆ្នាំ៧៧បាទ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។ កន្លែងធ្វើការឯទៀត ខ្ញុំមិនបានដឹងទេបាទ។

[១៤:០៨:៤២]

**ស៖** ក្រៅពី ប៉ង់ ដែលជាសមាជិកមន្ទីរ៨៧០ តើមានអ្នកណាផ្សេងទៀត ដែលជាសមាជិកនៃមន្ទីរនោះដែរ?

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។ ខ្ញុំសូមបញ្ជាក់ថា នៅពេលនោះខ្ញុំមិនបានដឹងទេបាទ។

**ស៖** លោកបាននិយាយថា ប៉ង់ យកលោកមកដាក់នៅ -- ឌុបលោកមកក្រសួងការបរទេសជិះម៉ូតូ តើគាត់មកក្រសួងការបរទេស ញឹកញាប់ដែរឬទេ? ហើយលោកធ្លាប់ឃើញគាត់ទេនៅឱកាសផ្សេងៗទៀតនោះ?

**ឆ៖** បាទ មិនបានឃើញទេបាទ។ ខ្ញុំឃើញគាត់តែម្តងហ្នឹងទេ។

**ស៖** តើលោកអាចជម្រាបបានទេ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកជួបលោក ខៀវ សំផន ញឹកញាប់ដែរឬទេ? ហើយបើជួបៗក្នុងក្របខ័ណ្ឌអ្វីខ្លះ?

[១៤:១០:០៨]

**ឆ៖** គឺចំពោះអ្នកដឹកនាំនៅពេលនោះ អ្នកបកប្រែ បើជាភាសាបារាំងខ្ញុំជាអ្នកទទួលបកប្រែ។ ដូច្នោះ ខ្ញុំបកប្រែជូនគាត់ ពេលដែលគាត់ក្នុងឋានៈជាប្រមុខរដ្ឋ គាត់ទទួលសារតាំងពីសំណាក់ឯកអគ្គរដ្ឋទូតប្រទេសជាមិត្តប្រចាំកម្ពុជាប្រជាធិបតេយ្យបាទ។

**ស៖** ក្រៅពីក្របខ័ណ្ឌផ្លូវការនេះ តើលោកធ្លាប់បកប្រែជាភាសាបារាំងឱ្យគាត់ នៅពេលដែលគាត់ពិភាក្សាជាមួយ ខៀវ សំផន ដែរឬទេ?

**ឆ៖** លោកប្រធាន! អ្នកណាពិភាក្សាជាមួយ ខៀវ សំផន បាទ ខ្ញុំ -- លោក ខៀវ សំផន នោះ? សូមលោកព្រះរាជអាជ្ញាបញ្ជាក់ អ្នកណាធ្វើការជាមួយលោក ខៀវ សំផន ឱ្យខ្ញុំបកប្រែនោះបាទ?

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាតាំងសំណួរចុងក្រោយសាជាថ្មីម្ដងទៀត សាក្សីមិនយល់សំណួរទេ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

**ស៖** ខ្ញុំចង់ថា ក្រៅពីក្របខ័ណ្ឌវិជ្ជាជីវៈក្នុងការបកប្រែភាសាឲ្យគាត់នោះ តើ-- គឺចង់សំដៅថា នៅពេល -- ក្រៅពីការបកប្រែជាមួយអ្នកការទូតផ្សេងៗទៀត បរទេសនោះ តើលោកធ្លាប់មានប្រជុំ ឬក៏ពិភាក្សាអ្វីជាលក្ខណៈឯកជនជាមួយនឹងលោក ខៀវ សំផន ដែរទេ? ខ្ញុំចង់សំដៅទៅលោកផ្ទាល់តែម្ដង។

**លោក ស្វង ស៊ីគឿន៖**

**ឆ៖** ខ្ញុំមិនដែលមានពេលគាត់ជួបជាឯកជនទេ ហើយសូមបញ្ជាក់នៅពេលនោះ គឺថាការជួបគ្នា យើងជួបសុទ្ធតែក្នុងពេលបំពេញភារកិច្ចរៀងៗខ្លួនបាទ។ ខ្ញុំចាំបានច្បាស់ថា គាត់អញ្ជើញមកក្រសួងការបរទេសពីរដង។ ជួបខ្ញុំពីរដង ប៉ុន្តែជួបពេលនោះ គឺថាគាត់ជជែកពីឲ្យខ្ញុំសរសេរអត្ថបទ ដើម្បីចុះផ្សាយ នៃជាភាសា -- ចុះផ្សាយក្នុងកាសែតៗ នៅពេលនោះ។ ក៏ប៉ុន្តែពីរដងនោះ មិនបានសម្រេចអីទេ មិនបានមានអត្ថបទអីចេញនោះទេបាទ។ ខ្ញុំចាំបានតែប៉ុណ្ណឹងទេបាទ។

[១៤:១៣:២៧]

**ស៖** តើលោកធ្លាប់អមដំណើរលោក ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ ទៅទីក្រុងប៉េកាំងដែរឬទេ ក្នុងពេលបេសកកម្មនៅរដូវក្ដៅឆ្នាំ៧៥នោះ?

**ឆ៖** ចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ ខ្ញុំធ្លាប់បានអមដំណើរលោក ខៀវ សំផន ទៅប្រជុំសន្និសីទកំពូលប្រទេសមិនចូលបក្សសម្ព័ន្ធ នៅស្រីលង្កា នៅឆ្នាំ១៩៧៦ តែមួយដងហ្នឹងគត់។ ហើយនៅពេលនោះ ក៏លោក អៀង សារី ក៏គាត់ក្នុងឋានៈគាត់ជារដ្ឋមន្ត្រីក្រសួងការបរទេស គាត់ក៏អមដំណើរគណៈប្រតិភូរបស់យើងខ្ញុំដែរបាទ។

[១៤:១៤:៤០]

**ស៖** តើលោកបានជួប ឬក៏មានទំនាក់ទំនងជាមួយលោក នួន ជា ដែរឬទេ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំបានជួបគាត់ផ្ទាល់ម្ដងតាមទូរស័ព្ទបាទ។ គាត់បានសុំឲ្យខ្ញុំសរសេរអត្ថបទពីនយោបាយការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ ដើម្បីចុះក្នុងកាសែតឈ្មោះ

"កម្ពុជា"។ តែមួយពេលហ្នឹងទេ ហើយខ្ញុំមិនបានជួបទេបាទ។ ខ្ញុំបានឃើញគាត់ ពេលដែលខ្ញុំទៅរៀនសាលាបក្ស ព្រោះគាត់ហើយនិង ប៉ុល ពត ជាអ្នកឧទ្ទេសនាមនៅក្នុងឱកាសពេលនោះបាទ។

**ស៖** នៅពេលដែលលោកមើលឃើញពីចម្ងាយថា ប៉ុល ពត ជាអ្នកធ្វើបទឧទ្ទេសនាម។ តើវគ្គអប់រំនយោបាយមែនទេ? ហើយការអប់រំនោះ តើប្រព្រឹត្តទៅនៅឯណាដែរ?

**ឆ៖** សាលាបក្សហ្នឹង គឺថាធ្វើនៅបុរីកីឡាបាទ។

**ស៖** តើវាជាវគ្គរៀនសូត្រសម្រាប់តែសមាជិកបក្សទេ មែនទេ?

[១៤:១៦:២៩]

**ឆ៖** បាទ សម្រាប់តែកម្មាភិបាលរបស់បក្ស។ ចាប់តាំងពីប្រធានគណៈតំបន់ឡើងទៅ។ គណៈស្រុក ប្រធានគណៈស្រុក ប្រធានគណៈតំបន់បាទ។

**ស៖** ក្រៅពី ប៉ុល ពត តើអ្នកណាដែលធ្វើបទឧទ្ទេសនាមនៅក្នុងវគ្គអប់រំនយោបាយ?

**ឆ៖** គឺដូចខ្ញុំបានជម្រាបហើយ ខាងដើមហ្នឹងគឺមាន ប៉ុល ពត ហើយនិងលោក នួន ជា។ មានពីរនាក់ ធ្វើឧទ្ទេសនាម បទឧទ្ទេសនៅក្នុងវគ្គនៅក្នុងសាលាបក្សនេះ។

**ស៖** តើលោកអាចបញ្ជាក់អំពីពេលវេលាដែលលោកបានចូលរួមនៅក្នុងវគ្គអប់រំនយោបាយនេះបានទេ ថានៅពេលណាដែរ?

**ឆ៖** ខ្ញុំចាំច្បាស់នៅឆ្នាំ គឺឆ្នាំ១៩៧៦។ ថ្ងៃខែវាអាច ខ្ញុំចាំមិនច្បាស់ អាចខែ៦។ ខែ៦ ឆ្នាំ១៩៧៦ ។

**ស៖** តើមានប្រធានបទនយោបាយ ឬមនោគមន៍វិជ្ជាអ្វីខ្លះ ដែលត្រូវបានលើកឡើងនៅក្នុងវគ្គដែលឧទ្ទេសនាមដោយ ប៉ុល ពត និង នួន ជា នេះ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ ព្រោះវាយូរឆ្នាំហើយបាទ។

[១៤:១៨:៣៨]

**ស៖** តើនៅក្នុងវគ្គនេះ គេមាននិយាយអំពីសភាពការណ៍នយោបាយទូទៅនៅក្នុងប្រទេស? តើមានការនិយាយអំពីសភាពខ្មាំងនៅក្នុងកិច្ចប្រជុំទាំងអស់នេះដែរឬទេ? តើលោកមាននឹកឃើញទេ?

**ឆ៖** គឺជាក់ច្បាស់ណាស់ គឺថាសភាពការណ៍ការវិវត្តន៍នៃបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យឆ្លងចូលបដិវត្តន៍សង្គមនិយាយនៅក្នុងប្រទេស ហើយសភាពការណ៍អន្តរជាតិដែលចលនាបដិវត្តន៍រំដោះជាតិ និងចលនាសង្គមនិយមកំពុងតែរីកសន្ធោសន្ធៅនៅសកលលោកក្នុងពេលនោះបាទ។

**ស៖** ក្រៅពីកិច្ចប្រជុំវគ្គរៀនសូត្រនយោបាយនេះ តើលោកមានធ្លាប់ចូលរួមមហាសន្និបាតប្រចាំ

ឆ្នាំធំៗនៅស្តាតអូឡាំពិកដែរឬទេក្នុងឋានៈលោកជាបក្ខជននោះ។ ឧទាហរណ៍ដូចជាក្នុងឱកាសបុណ្យខួបបក្សកុម្មុយនីស្តកម្ពុជាជាដើម?

[១៤:២០:០៥]

**ឆ៖** បាទ ខ្ញុំចាំថានៅឆ្នាំ១៩៧៨ ខ្ញុំបានចូលរួមមីទ្ទិងអបអរសាទរកំណើតបក្សនៅបុរីកីឡា នៅកីឡាដ្ឋានអូឡាំពិក។

**ស៖** ហើយនៅក្នុងឱកាសនោះ តើអ្នកណាជាវាគ្មិននៅស្តាតអូឡាំពិក?

**ឆ៖** ពេលនោះ គឺថាលោក ប៉ុល ពត គឺជាវាគ្មិនបាទ។

**ស៖** តើមេដឹកនាំធំៗបក្សផ្សេងទៀតនោះមានវត្តមាននៅទីនោះដែរឬទេ? ឧទាហរណ៍ដូចជា នួន ជា, អៀង សារី, ខៀវ សំផន...។ល។ អាចមាន សុន សេន ឬក៏ វន វ៉េត ជាដើម?

**ឆ៖** បាទ នៅក្នុងពេលនោះ អ្នកដឹកនាំសំខាន់ៗរបស់បក្សក៏មានវត្តមាននៅទីនោះដែរ។ ប៉ុន្តែខ្ញុំមិនចាំថា មានអ្នកណាខ្លះទេបាទ។

[១៤:២១:៣១]

**ស៖** តើលោកមាននៅចាំអំពីខ្លឹមសារនៃបទឧទ្ទេសនាមរបស់ ប៉ុល ពត នៅក្នុងឱកាសបុណ្យខួបបក្សឆ្នាំ៧៨ គឺប្រហែលជានៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ៧៨? តើលោកមានចាំអំពីខ្លឹមសារនៃបទឧទ្ទេសនាមនេះទេ?

**ឆ៖** បាទ ខ្ញុំចាំ ព្រោះពេលនោះគឺថា ការតានតឹងរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ឈានដល់ដំណាក់កាលមួយតឹងតែងជាទីបំផុត។ ហើយខ្ញុំចាំច្បាស់ថា ប៉ុល ពត គាត់ថា យុទ្ធជនកម្ពុជាប្រជាធិបតេយ្យមួយរូប មានសមត្ថភាពកម្ទេចយុទ្ធជនកងទ័ពប្រជាជនវៀតណាមប្រាំបីនាក់។ ដូច បូកចុះបូកឡើងទៅ ប្រជាជនវៀតណាមស្លាប់ទាំងអស់ ខ្មែរយើងនៅសល់២លាននាក់ទៀតដែរ។ ខ្ញុំ ពេលនោះខ្ញុំថា ខ្ញុំព្រឺក្បាល ហើយខ្ញុំថា ខ្ញុំគិតក្នុងខ្លួនខ្ញុំថា "ពិបាកនឹងជឿ"។

**ស៖** ក្នុងឋានៈជាអ្នកទទួលខុសត្រូវខាងផ្នែកឃោសនាការនិងព័ត៌មាននៅក្នុងមន្ទីរប-១ គឺលោកតាមដានព្រឹត្តិការណ៍បច្ចុប្បន្ននៃប្រទេស។ តើលោកដឹងទេថា នួន ជា គាត់ទៅសន្និបាតដែលកើតមាននៅតាមភូមិភាគនានានោះ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ព្រោះមិនមែនជាភារកិច្ចរបស់ខ្ញុំ។

**ស៖** លោកបាននិយាយថា លោកបានទទួលទូរស័ព្ទពី នួន ជា ពាក់ព័ន្ធនឹងការតាក់តែងអត្ថបទ

តើវាមានទំនាក់ទំនងជាមួយនឹងការតាក់តែងសៀវភៅខ្មៅនៃនយោបាយសាធារណរដ្ឋវៀតណាម ចំពោះកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** មិនមានទាក់ទង--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប! សូមសាក្សីចាំស្ដាប់អង្គជំនុំជម្រះសម្រេចលើការជំទាស់របស់មេធាវីសិន។

បាទ សូមអញ្ជើញលោកមេធាវី!

[១៤:២៤:៤១]

**លោក ហ្សាស្ដើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ដូចជាយឺតពេលបន្តិច ប៉ុន្តែដើម្បីកត់ត្រា ខ្ញុំសូមជំទាស់ទម្រង់នៃការសួរសំណួររបស់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញា នៅក្នុងសំណួររបស់គាត់នោះ គាត់បានដាក់ព័ត៌មាន គាត់ដាក់ទ្រឹស្ដី ហើយថា ការទូរស័ព្ទហ្នឹង គឺនិយាយពីអ្វីរួចទៅហើយ។ ហើយគាត់បាន គ្រាន់តែសួរថា តើការសន្ទនាហ្នឹងសន្ទនាពីអ្វី? ប៉ុន្តែសហព្រះរាជអាជ្ញាបានដាក់ព័ត៌មាននៅក្នុងសំណួររបស់គាត់ ប៉ុន្តែយឺតពេលបន្តិច ប៉ុន្តែខ្ញុំមិន -- ថាតើដោះស្រាយបញ្ហាដូចម្ដេចទេ? ប៉ុន្តែនៅក្នុងអនាគតដូចជាចាំបាច់ដែលថាលោកប្រធានបានឮសំណួរ ឬក៏បង្គាប់ឲ្យសហព្រះរាជអាជ្ញាកុំឲ្យសួរសំណួរដែលមានលក្ខណៈជាសំណួរនាំមុខ ដែលគាត់ផ្ដល់ព័ត៌មានជូនទៅសាក្សីនៅក្នុងទម្រង់សំណួររបស់គាត់ជាមុនហើយស្រេចនោះ។

[១៤:២៥:៤២]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានតាមពិតនេះ គឺជាទិដ្ឋភាពដែលសាក្សីគាត់បាននិយាយរួចមកហើយ។ ដូច្នេះ ខ្ញុំគិតថា មិនមែនជាសំណួរនាំមុខទេ ពីព្រោះខ្លួនគាត់ផ្ទាល់ គាត់ជាអ្នកនិយាយនៅក្នុងឯកសារលេខ E3/42 ឬក៏ D177។ គាត់មានកំណត់ហេតុនេះនៅក្នុងដៃរបស់គាត់ហើយ គឺនៅទំព័រខ្មែរ 00327206 ទៅ 07, ភាសាអង់គ្លេស 00327217, ជាភាសាបារាំង 00327227។ ដូច្នេះខ្ញុំ -- ខ្ញុំមិនដឹងថាតើយើងអាចស្ដាប់ចម្លើយរបស់សាក្សីតែម្ដង ឬក៏ខ្ញុំត្រូវអានសម្រង់នៃកំណត់ហេតុនេះ លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ គឺថាយើងបានអានកំណត់ហេតុពីមុនរបស់គាត់ហើយ នេះមិនមែនជាបញ្ហាទេ។ បញ្ហា គឺថាតើយើងសួរគាត់នៅក្នុងតុលាការដូចម្តេច? យើងចង់បានសក្ខីកម្មដែលមានតម្លៃជាភស្តុតាងរបស់គាត់ គប្បីតែសួរសំណួរដោយចំហ។ ការសួរសំណួរនាំមុខ គឺជាការបំពានទៅនឹងវិធាន ហើយនិងជាពិសេសនៅក្នុងនីតិវិធីតុលាការ។ ឥឡូវនេះយើងឃើញហើយ គឺមិនអ៊ីចឹង ចាំថាសាក្សីបាននិយាយអំពីសន្ទនាតាមទូរស័ព្ទជាមួយលោក នួន ជា នោះទេ ប៉ុន្តែ ហើយគាត់បានឆ្លើយថាគាត់បានជួប។ ដូច្នេះនេះជាចំណុចសំខាន់ដែលគួរពិចារណា ដែលថាគួរតែសំណួរបើកចំហ ហើយមិនគប្បីសួរសំណួរនាំមុខទៅសាក្សីរូបនេះទេ។ សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៨:៤៣]

**ប្រធានអង្គជំនុំ៖**

បាទសេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់មិនសមស្របទេ។ ដូច្នេះ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយតបរបស់សាក្សី តបទៅនឹងសំណួរចុងក្រោយដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញា។

**លោក សួង ស៊ីគឿន៖**

**ឆ៖** ការសន្ទនាតាមទូរស័ព្ទរបស់ខ្ញុំជាមួយនឹងលោក នួន ជា គ្មានទាក់ទងជាមួយនឹងការសរសេរអត្ថបទនៃសៀវភៅខ្មៅ របស់កម្ពុជាប្រជាធិបតេយ្យទេបាទ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន ខ្ញុំប្រហែលជាអាចអាននូវសម្រង់នេះ ដើម្បីឱ្យអាចសួរសំណួរផ្សេងទៀតពាក់ព័ន្ធទៅនឹងបញ្ហានេះ។ ពីព្រោះខ្ញុំគិតថា នៅក្នុងកំណត់ហេតុនោះគឺមានទំនាក់ទំនងមួយចំនួនរវាងកិច្ចប្រជុំពាក់ព័ន្ធនឹងសៀវភៅខ្មៅ ហើយនិងទូរស័ព្ទរបស់ នួន ជា។ ដូច្នេះ ខ្ញុំសូមអានឃ្លាដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ គឺនៅក្នុងឯកសារ E3/42 ហើយនិងមានលេខ D167 ដែលលោកសាក្សីគាត់មាននៅនឹងមុខហើយ។ ដូច្នេះសូមយោងទៅលើទំព័រ 00327206 ទៅដល់ 07 ជាភាសាបារាំងគឺនៅទំព័រទី៦, អង់គ្លេស 00327217។ សូមការអនុញ្ញាតពីលោកប្រធានដើម្បីដាក់បញ្ចាំងឯកសារនេះនៅលើអេក្រង់។

[១៤:៣០:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ាំងសង់ វ៉ាយជ៍ ដេស្នាឯល៖**

**ស៖** ខ្ញុំនឹងដកស្រង់នូវអ្វីដែលលោកបានឆ្លើយ នេះគឺជាសំណួរមួយដែលបានសួរថា៖ “តើលោកដែលបានជួបជាមួយ នួន ជា នៅចន្លោះឆ្នាំ៧៥ និង៧៩ ដែរឬទេ? ចម្លើយ៖ ខ្ញុំមិនដែលមានទំនាក់ទំនងផ្ទាល់ជាមួយគាត់ទេ។ ខ្ញុំបានជួបគាត់តែនៅពេលនៃការប្រជុំរៀបចំនៅខែកញ្ញា ឆ្នាំ១៩៧៧ ដើម្បីសរសេរសៀវភៅខ្មៅស្ដីពីនយោបាយការបរទេសរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ចំពោះកម្ពុជាប្រជាធិបតេយ្យ។ មានតំណាងជាច្រើនរបស់ក្រសួងការបរទេស ដូចជា ជួន ប្រាសិទ្ធ, គាត ឈន់ និងខ្ញុំ។ យើងត្រូវបានកោះប្រជុំដោយ ប៉ុល ពត ហើយមានតែគាត់ទេ ដែលជាអ្នកនិយាយ។ ហើយ នួន ជា ជាអ្នកសង្កេតការណ៍ និងជាអ្នកចូលរួមអកម្ម។ បន្ទាប់ពីកិច្ចប្រជុំខ្ញុំចាំថា នួន ជា បានទូរស័ព្ទមកខ្ញុំនៅចុងឆ្នាំ១៩៧៧ ប្រាប់ឲ្យខ្ញុំសរសេរអត្ថបទមួយស្ដីពីនយោបាយការបរទេសកម្ពុជាប្រជា-ធិបតេយ្យសម្រាប់កាសែតកម្ពុជា”។ សូមបញ្ចប់ការដកស្រង់។ ដូច្នេះ ខ្ញុំសូមនិយាយអំពីការតាក់តែងសៀវភៅខ្មៅនេះ។ តើតួនាទីរបស់ នួន ជា និង អៀង សារី មានអ្វីខ្លះនៅក្នុងការតាក់តែងសៀវភៅខ្មៅដែលបោះពុម្ពឡើងដោយក្រសួងការបរទេសនេះ?

[១៤:៣២:២៦]

**លោក ស្ួង ស៊ីគឿន៖**

**ឆ៖** លោកទាំងពីរហ្នឹងគ្មានជាប់ទាក់ទងនឹងអ្វីនឹងការបោះពុម្ពផ្សាយសៀវភៅខ្មៅរបស់ក្រសួងការបរទេសទេ។ លើកលែងតែគាត់បានចូលរួម ចូលស្ដាប់ ពេលនុ៎ងគឺថា តាមដែលខ្ញុំចាំគឺ ប៉ុល ពត គាត់បានកោះហៅកម្មាភិបាលមួយចំនួនរបស់ក្រសួងការបរទេស។ អ្នកដែលខ្ញុំចាំច្បាស់គឺថាមាន ខ្ញុំបាទ, លោក គាត ឈន់, លោក ជួន ប្រាសិទ្ធ ហើយនិងលោក នី កន ក្នុងឋានៈគាត់ជាប្រធានផ្នែកពិធីការ។ ហើយមានវត្តមាននៅទីនោះមានលោក នួន ជា ហើយនិងលោក អៀង សារី។ ហើយលោក ប៉ុល ពត, ប៉ុល ពត គាត់បានឧទ្ទេសនាមខ្លឹមសារ ហើយយើងប៉ុន្មាននាក់ហ្នឹងជាអ្នកកត់ហេតុទេ គឺថារបៀបធ្វើការកម្ពុជាប្រជាធិបតេយ្យអីចឹង កុំៗថា ដូចថាឥឡូវ គេថាខ្ញុំសរសេរសុន្ទរកថា ឬលោកណាលោក - - តាមខ្ញុំឮថា លោក គាត ឈន់ ហ្នឹងសរសេរសុន្ទរកថាអី គាត់មិនមែនសរសេរ ខ្ញុំក៏មិនមែនសរសេរទេ ចេះតែកត់ហេតុទេ។ គឺថា ខ្ញុំចង់ជម្រាបឲ្យបានដឹង គឺថាកត់ហេតុទៅ យើងគ្រាន់តែសរសេរឲ្យស្អាត អ្វី

ដែលគាត់បានកត់ហេតុហ្នឹង ហើយដាក់ដូចថា កែសម្រួលឃ្លាខ្លះ ក៏ប៉ុន្តែពាក្យពេចន៍ ហើយខ្លឹមសារដែលសំខាន់ៗយើងទុកទាំងអស់ រួចទៅយកទៅឆ្លងគាត់ម្តងទៀត បានយកមកបោះពុម្ពផ្សាយ។

[១៤:៣៤:០៧]

ដូច្នោះ គ្មានគំនិតអីថ្មីរបស់យើងទេ ពេលនុ៎ងខ្ញុំចាំច្បាស់ពីគាត់ឧទ្ទេសនាមអំពីឈ្មោះ កូសាំងស៊ីនដែលជាវៀតណាមខាងត្បូងហ្នឹង។ ហើយខ្ញុំក៏មិនសូវយល់ ពេលនោះខ្ញុំក៏មិនសូវយល់គាត់និយាយពីថា "កូ" ហ្នឹងគឺថា តាមពាក្យថា វៀតណាមហ្នឹងគឺថា កូនស្រី ឬស្អីទេ ខ្ញុំចាំថា កូនស្រីទី៩ របស់ស្តេចណាទេ ស្អីអ៊ីចឹង។ ហើយខ្ញុំចាំពេលនុ៎ងគឺលោក ជួន ប្រាសិទ្ធ ហើយនិងលោក គាត ឈន់ គាត់ជជែកគ្នាថា យី!ន៎ែ ដូចជាមិនមែនអ៊ីចឹងទេ តាមប្រវត្តិការកកើតវៀតណាមខាងត្បូង កូសាំងស៊ីន។ កូសាំងស៊ីន គឺថា វៀតណាមខាងត្បូង ជាពាក្យបារាំង អង្កាល់បារាំងចូលមកធ្វើអាណានិគមនិយមហ្នឹង វៀតណាមហ្នឹងចែកជាបី វៀតណាមខាងត្បូងហ្នឹង ហៅ កូសាំងស៊ីន យើងហៅកម្ពុជាក្រោមនោះ។ ហើយវៀតណាមកណ្តាលហ្នឹង គេហៅ អណ្ណាម ហើយវៀតណាមខាងជើងហ្នឹងហៅតុងកឹង។

[១៤:៣៥:១៤]

ដូច្នោះ -- ក៏ប៉ុន្តែចុះឡើងៗជជែកគ្នាចុះឡើងទៅដាក់ដដែលហ្នឹង កូសាំងស៊ីនអី តាមសៀវភៅខ្មៅ ហើយខាងផ្នែកខ្ញុំហ្នឹងជាអ្នកទទួលផ្សាយ។ ដូច្នោះមិនមានវត្តមានរបស់លោក នួន ជា និង លោក អៀង សារី មិន -- គាត់មិនបានចូលរួមសរសេរសៀវភៅហ្នឹងទេ គឺមែនទែនគឺថា ប៉ុល ពត ខ្លួនឯងផ្ទាល់គាត់អ្នកសរសេរ។ ហើយខ្ញុំចាំបានថាពេលនោះលោក សារិន ឆាក ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសក៏គាត់មានវត្តមាននៅទីនោះដែរ នៅក្រសួងការបរទេសដែរ។ គាត់បានឃើញសៀវភៅខ្មៅហ្នឹង ហើយគាត់ថា អាហ្នឹងគាត់និយាយជាមួយខ្ញុំ គាត់ថាសៀវភៅខ្មៅសរសេរអ៊ីចឹងវាវាក់កំភែល គាត់ថា អ៊ីចឹង ពាក្យគាត់ហ្នឹង គាត់ថាវាក់កំភែល។ ហើយខ្ញុំក៏នៅតែស្ងៀមទៅ ព្រោះអានេះ រឿងរ៉ាវមានតែប៉ុណ្ណឹងទេបាទ។

[១៤:៣៦:២៧]

**ស៖** ប្រសិនបើសៀវភៅនេះត្រូវបានបោះពុម្ពដោយក្រសួងការបរទេស តើលោកដឹងទេថា តើលោក អៀង សារី គាត់មានបានអានសៀវភៅនេះមុនពេលបោះពុម្ពដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអគរគុណលោកប្រធាន។ ខ្ញុំមិនបានជំទាស់ពីដំបូង ព្រោះថាដោយសារអង្គហេតុហ្នឹងបានលើកឡើង ប៉ុន្តែឥឡូវហ្នឹងព្រះរាជអាជ្ញាគាត់លើកយកអង្គហេតុដដែលមកទៀត។ ដូច្នេះ ខ្ញុំគិតថានៅចំពោះមុខចៅក្រមអាជីព គាត់បានប្រកាសថា ការងារនៅក្រសួងការបរទេស គឺជាការប្រកាសរបស់ខាងព្រះរាជអាជ្ញា។ ប៉ុន្តែអ្វីដែលខ្ញុំចង់និយាយគឺថា វាជាការនាំមុខ ព្រោះថាខាងព្រះរាជអាជ្ញាបានលើក -- ខាងសាក្សីបាននិយាយថា គាត់បានប្រាប់ ប៉ុល ពត -- ប៉ុល ពត បានប្រាប់គាត់។ ហើយឥឡូវនេះ អ្វីដែលគាត់ចង់ធ្វើគឺចង់ជួយដល់ក្រសួងការបរទេស។ ខ្ញុំយល់ថាសាក្សីគាត់ចង់និយាយអំពី -- ខាងព្រះរាជអាជ្ញាចង់និយាយអំពីក្រសួងការបរទេស ប៉ុន្តែសាក្សីគាត់ចង់និយាយផ្សេង។

[១៤:៣៧:៥៦]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

**ស៖** លោកប្រធាន ខ្ញុំសូមឲ្យសួរទៅកាន់សាក្សីថា គាត់និយាយអំពីក្រសួងការបរទេសមែនទេ ដែលជាអ្នកបោះពុម្ពផ្សាយសៀវភៅខ្មៅ ពីព្រោះថាសៀវភៅនេះមានចុះនិទ្ទេសក្រសួងការបរទេសនៅទំព័រដំបូងនោះ។

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ គឺជា ខ្ញុំបាទហ្នឹងឯង ក្នុងឋានៈជាផ្នែកឃោសនានិងព័ត៌មានដែលយកសៀវភៅហ្នឹងយកទៅបោះពុម្ពផ្សាយ។ ទៅបកប្រែជាពីរភាសា ជាភាសាបារាំងផង ជាភាសាអង់គ្លេសផង ហើយបោះពុម្ពផ្សាយបាទ។

**ស៖** ដូច្នេះ ខ្ញុំយល់ហើយ ព្រោះថាលោកជាអ្នកចូលរួមក្នុងការបោះពុម្ពផ្សាយនេះ ហើយគឺក្រសួងការបរទេសពិតជាអ្នកបោះពុម្ពមែន។ ដូច្នេះមានន័យថា អៀង សារី ខ្លួនឯងផ្ទាល់នេះបានអានសៀវភៅនេះមែនទេដើម្បីផ្ទៀងផ្ទាត់ខ្លឹមសារ ដើម្បីឲ្យវាស្របគ្នាទៅនឹងកិច្ចសន្ទនាជាមួយ ប៉ុល ពត មុនពេលបោះពុម្ពឯកសារនេះ។

[១៤:៣៩:១៣]

**ឆ៖** តាមមើលពីមិនចាំបាច់ទេ។ គឺថាលោក ជួប ប្រាសិទ្ធ អាចផ្ញើទៅ អាចអ៊ីចេះ អាចផ្ញើទៅ ប៉ុល ពត តាមរយៈលោក អៀង សារី នូវឯកសារហ្នឹង គាត់ធ្វើហើយលោក គាត ឈន់ និង លោក ជួន ប្រាសិទ្ធ គាត់សរសេររៀបរាប់ហើយ សរសេរជាសៀវភៅស្រួលបួលហើយ គាត់ផ្ញើទៅ ប៉ុល ពត

ហ្នឹងតាមលោក អៀង សារី ។ អាចទេ ជួនកាលគាត់ផ្ញើផ្ទាល់លោក អៀង សារី គាត់ --អ៎! លោក ប៉ុល ពត គាត់មកយកឯកសារហ្នឹងផ្ទាល់។ ខ្ញុំចង់ជម្រាបថា លោក ប៉ុល ពត គាត់ទាក់ទងជាមួយយើងខ្ញុំផ្ទាល់មិនចាំបាច់លោក អៀង សារី គាត់ដឹងទេ លោកអៀង សារី ជាអ្នក -- ជួនកាលគាត់អត់ដឹងទេ។

[១៤:៣៩:៥៧]

ហើយរឿងនេះគឺថា ខ្ញុំសួរ -- អាហ្នឹងជារឿងក្រៅទេលោកប្រធាន សូមអនុញ្ញាត។ ប៉ុន្តែគ្រូខ្ញុំ មីស្ស៊ី ស្តេហ្វាន គូកទ័រ ហ្នឹង គាត់*ប៉ាត្រុងតែស* ខ្ញុំ។ គាត់ថា នៅរបបកុម្មុយនីស្តទាំងអស់នៅអឺរ៉ុបហ្នឹង សហភាពសូវៀត ហុងគ្រី អាល់បានី រ៉ូម៉ានី គេធ្វើតែរបៀបហ្នឹង។ គឺថាបើលោកជាប្រធាន អាប្រធានហ្នឹងអត់បានការអីទេមែនទែនណែ៎ អ្នកទី២ អ្នកលេខាអីទេ ដែលធ្វើការងារជាក់ស្តែង ហើយមានអំណាចមែនទែន។ អាហ្នឹងអ៊ីចឹង។ គឺថារបៀបរបបដូច្នោះ តាមមើលទៅមិនមែនដូចអឺរ៉ុបទេ មិនមែនដូចនៅអាមេរិកអីទេ។ អាហ្នឹងហើយដែលគេហៅថា គេហៅថា ខ្មែរយើងរបៀបខ្មែរយើងផ្សេង របៀបអឺរ៉ុបផ្សេង របៀបបារាំងផ្សេង របៀបអាមេរិកផ្សេង។ ខ្ញុំមិននិយាយតឆ្ងាយទេ ខ្ញុំចង់តែជម្រាបរបៀបធ្វើការអ៊ីចឹង។ ដូច្នោះប្រធានមែន ប៉ុន្តែជួនកាលអត់ដឹងទេ ហើយជួនកាលខ្ញុំធ្វើតែប្រធានផ្នែកព័ត៌មាន ប៉ុន្តែជួនកាលឯកសារចេញពីកន្លែងខ្ញុំហ្នឹង ដាក់ឈ្មោះខ្ញុំ ដាក់អីខ្ញុំ ប៉ុន្តែខ្ញុំអត់ដឹង គេចេញបាត់ផ្សាយបាត់ទៅ។ ខ្ញុំដឹងតាមវិទ្យុ ខ្ញុំដឹងតាមកាសែត អាហ្នឹងរបៀបធ្វើការគេអ៊ីចឹងបាទ។ បាទសូមជម្រាបប៉ុណ្ណឹងបាទ។

[១៤:៤១:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្រួល ផ្តល់កន្លែងសម្រាកនៅបន្ទប់សម្រាកសម្រាប់សាក្សី និងអ្នកជំនាញដល់សាក្សី នៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់ប្រាប់តុលាការមុននឹងចាប់ផ្តើមនេះ ថាខ្ញុំនឹងមិនអាចបញ្ចប់នៅល្ងាចនេះទេ ហើយនិងព្រមព្រៀងជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំនឹងយកពេលវេលាគាត់ ១៥នាទី នៅព្រឹកស្អែកនេះ ដើម្បីបញ្ចប់ការសួរសំណួររបស់ខ្ញុំ លោកប្រធាន។

[១៥:០៣:៤០]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកសាក្សី អម្បាញ់មិញនេះ លោកបាននិយាយអំពីការដែលថា ប៉ុល ពត បានទាក់ទងលោក ហើយនិងអ្នកដឹកនាំផ្សេងៗទៀត នៃក្រសួងការបរទេស។ តើ ប៉ុល ពត ទាក់ទងលោកតាមវិធីណា? តាមទូរស័ព្ទ? លោកអាចជម្រាបពីរបៀបទាក់ទងលោកនេះបានដែរឬទេ? គាត់ទាក់ទងលោកតាមវិធីណាដែរ?

**លោក ស្ួង ស៊ីគឿន៖**

**ឆ៖** បាទ នៅពេលនោះ ខ្ញុំចាំមិនច្បាស់ទេ ប៉ុន្តែខ្ញុំដឹង មិនមែនតាមលោក អៀង សារី ទេបាទ។ ព្រោះលោក អៀង សារី គាត់មិនមែន គឺមកជួបយើងរាល់ថ្ងៃទេ។ ១អាទិត្យ គាត់មកពីរ ឬបីដង តែប៉ុណ្ណោះ។ តាមខ្ញុំចាំ គឺថា ខ្ញុំមិនច្បាស់ទេ ប៉ុន្តែខ្ញុំ គឺថាលោក នី កន ក្នុងឋានៈគាត់ជាពិធីការ គាត់បានហៅខ្ញុំ បបួលខ្ញុំទៅ បាទអ៊ីចឹង។

**ស៖** បាទ អ៊ីចឹង តាមពិតទៅ ប៉ុល ពត មិនដែលទាក់ទងលោកដោយផ្ទាល់ជាបុគ្គលនោះទេ ពីព្រោះថា តាមរយៈ អៀង សារី ឬក៏អ្នកផ្សេងទៀត។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ គាត់មិនដែលទាក់ទងខ្ញុំផ្ទាល់ទេបាទ។

[១៥:០៥:២០]

**ស៖** បាទ សូមអរគុណ។ លោកសាក្សី ឥឡូវនេះខ្ញុំសូមចូលនិយាយជំពូកថ្មីមួយទៀត។ តើនៅ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបានសង្កេតឃើញថាមានបាត់ខ្លួននៅក្នុងក្រសួងការបរទេស គឺថាសមាជិកក្រសួងផ្ទាល់តែម្តង ឬក៏បុគ្គលផ្សេងទៀតដែលត្រូវបានតែងតាំងមកក្រសួងការបរទេសនេះជាបណ្តោះអាសន្ន?

**ឆ៖** បាទ ខ្ញុំបានឃើញអ្នកដែលបាត់ខ្លួនដែរ។

[១៥:០៦:១៧]

**ស៖** តើបុគ្គលិកប្រភេទណាដែរ? តើមានប្រភេទបុគ្គលផ្សេងៗដែលធ្វើការនៅមន្ទីរប-១ ដែលបាត់ខ្លួនដែរឬទេ? ឧទាហរណ៍ដូចជាឯកអគ្គរាជទូត បញ្ញាជន ឬក៏កម្មាភិបាលនៅមន្ទីរប-១ ឬក៏អ្នកតស៊ូនៅមន្ទីរប-១ ជាដើម។

**ឆ៖** អ្នកដែលចេញពី ប-១ ទៅដូចជាពីមុនគាត់ធ្វើមុនលោកស្រី អ្នកស្រី សួរ សែ ហ្នឹងគាត់ឈ្មោះ វ៉ែន គាត់បានធ្វើជាលេខាសាខារបស់បក្សនៃ -- នៅខាងផ្នែកការិយាល័យ ហើយគាត់បានធ្វើជាមុនលោក អៀង សារី គាត់ -- គេតែងតាំងលោកធ្វើជាប្រធានផ្នែកនាយកដ្ឋាននយោបាយទូទៅហ្នឹងគាត់ឈ្មោះ វ៉ែន ហើយឈ្មោះគាត់ឈ្មោះដើមគាត់ ខ្ញុំដូចមិនចាំឈ្មោះស្អី សំអាត ទេបាទ។ គាត់មកមួយរយៈហើយក៏បាត់ទៅ។ អាហ្នឹងជាឧទាហរណ៍មួយ ហើយនៅៗផ្នែកផ្សេងទៀតដូចជាឈ្មោះ កែវ ប្រធានអាកាសចរណ៍ស៊ីវិល ពេលនោះអាកាសចរណ៍ស៊ីវិលកម្ពុជាគឺនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងការបរទេស គឺឈ្មោះ កែវ ហ្នឹងគាត់ក៏បាត់ខ្លួនដែរ។ ប៉ុន្តែខ្ញុំមិនដឹងគេ ធម្មតាបាត់ខ្លួនហ្នឹងគឺថាអាចទៅបំពេញភារកិច្ចនៅកន្លែងផ្សេង ឬក៏បាត់តែម្តង។ អាហ្នឹង ខ្ញុំមិនអាច ខ្ញុំមិនបានដឹងទេ។ ហើយម្នាក់ដែលនិស្សិតមួយ គាត់ជាវិស្វករខាងៗរ៉ែ អាំងស៊ីញ៉ែរ ឌីមិន គាត់ជួយរៀបចំផ្ទះ ជួយរៀបចំក្រសួង -- គាត់នៅផ្ទះៗ កូឡាប នៅជិតមុខវាំងហ្នឹង ជាមួយខ្ញុំដែរហ្នឹង គឺថាគាត់មកក្រសួងការបរទេសបានមួយរយៈ គាត់ទៅក្រសួងឧស្សាហកម្មក៏បាត់ខ្លួនដែរ។ ហើយមិត្តភក្តិខ្ញុំដែលជួយរៀបចំក្រសួងការបរទេសហ្នឹង ឈ្មោះ ទន់ ជោតស៊ីរិន ហ្នឹង ហៅ កើត ហ្នឹងក៏បាត់ខ្លួនដែរ។ ដូច្នោះបាត់ខ្លួនដែលខ្ញុំដឹងនេះ -- ប៉ុន្តែ ខ្ញុំមិនដឹងថាតើគេផ្លាស់ភារកិច្ច ឬត្រូវចាប់ខ្លួនទេ។ ខ្ញុំមិនបានដឹងទេ។ ព្រោះអត់អ្នកណាឧទ្ទេសនាមប្រាប់ខ្ញុំពីបញ្ហានេះទេ។ ស្រាប់តែបាត់ៗទៅតែម្តងទៅបាទ។

[១៥:០៩:៣៩]

**ស៖** បាទ សូមអរគុណលោកសាក្សី។ ជាបឋមខ្ញុំសូមចាប់ផ្តើមនិយាយអំពីជោគវាសនានៃអតីតអ្នកការទូត ឯកអគ្គរាជទូតនៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា តើបន្ទាប់ពីការដណ្តើមបាន

ក្រុងភ្នំពេញ តើអ្នកណាជាអ្នកអំពាវនាវឲ្យអតីតឯកអគ្គរាជទូតត្រឡប់ចូលមកប្រទេសកម្ពុជាវិញ?

**ឆ៖** អាហ្នឹងគឺថា ទី១ ក្រោយពីថ្ងៃ១៧ មេសា ១៩៧៥ អ្នកការងារទូតហ្នឹងបំពេញការងារនៅក្រៅប្រទេសទេ។ ប៉ុន្តែធម្មតា ការសម្រេចដែលឲ្យអ្នកការងារទូតហ្នឹងត្រឡប់ពី -- មកក្នុងប្រទេសវិញនៅចុងឆ្នាំ១៩៧៥ហ្នឹង គឺធម្មតា ប៉ុល ពត គេអ្នកសម្រេចបាទ។ មិនមែនលោក អៀង សារី គាត់អ្នកសម្រេចទេ មិនមែនរដ្ឋមន្ត្រីការបរទេសសម្រេច គឺថាដឹកនាំប្រទេសសម្រេចតែម្តងបាទ។

[១៥:១១:០៨]

**ស៖** បាទ លោកសាក្សី លោក -- យើងនិយាយអំពីការសម្រេចរបស់ ប៉ុល ពត ជាថ្មីម្តងទៀត តើលោកដឹងថា ប៉ុល ពត ធ្វើការសម្រេចទាំងអស់នេះតាមរបៀបណា? ហើយអ្នកណាជាអ្នកប្រាប់លោកយ៉ាងដូច្នេះ?

**ឆ៖** អានេះ បើមិនមែនជាលោក អៀង សារី ទេមានអ្នកណាដែលនៅពីលើ មានតែ ប៉ុល ពត ហ្នឹងឯងដែលធ្វើសេចក្តីសម្រេច។ ហើយខ្ញុំមានឧទាហរណ៍មួយច្បាស់លាស់ គឺថាពួកនិស្សិតដែលបញ្ញាជនដែលចូលមកក្នុងប្រទេសហ្នឹង គឺថាឆ្លងកាត់តាមស្ថានទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសចិន ហើយនៅទីនោះគេប្រមូលអស់ហើយ គឺថានាឡិកា របស់របរដែលខ្សែដៃ ខ្សែក្រវ៉ាត់អី របស់គ្រឿងអលង្ការ គេប្រមូលទុកអស់ហើយនៅស្ថានទូតហ្នឹង។ ដូច្នេះសេចក្តីសម្រេចឲ្យស្ថានទូតនោះប្រមូលសេចក្តីសម្រេចហ្នឹង មិនមែនលោក អៀង សារី គាត់អ្នកសម្រេចទេ។ អាហ្នឹង ខ្ញុំដឹងច្បាស់ ព្រោះខ្ញុំនៅហ្នឹង គឺថា ប៉ុល ពត ជាអ្នកសម្រេចតែម្តង។ ព្រោះនៅដូចខ្ញុំបាននេះ គឺថា ឧបមាថានៅស្ថានទូតហ្នឹងនីមួយៗមិនមែនជា ឯកអគ្គរដ្ឋទូតជាអ្នកដឹកនាំពិតប្រាកដទេ ជាលេខាបក្សនៅក្នុងស្ថានទូតហ្នឹងជាអ្នកដែលដឹកនាំ ឃើញទេ! របៀបរបបធ្វើការងារ គឺថារបបកុម្មុយនីស្ត វាអ៊ីចឹង។ លេខាបក្សធំជាងឯកអគ្គរដ្ឋទូត ឃើញទេ! អាហ្នឹងខ្ញុំមានពិសោធន៍ផ្ទាល់ ខ្ញុំនិយាយច្បាស់អាហ្នឹង អត់ន៏នេះទេ។ ដូច្នោះ ប៉ុល ពត គាត់សម្រេចការងារទូតខ្លះ គឺថារដ្ឋមន្ត្រីក្រសួងការបរទេសអត់ដឹងទេ គាត់ទាក់ទងមកផ្ទាល់មកលេខាសាខាបក្សនៅក្នុងស្ថានទូតនីមួយៗ ដើម្បីធ្វើការសម្រេច។

[១៥:១៣:២៤]

**ស៖** បាទ ត្រង់នេះហើយ គឺលោកនិយាយថាមិនមែនជាសេចក្តីសម្រេចរបស់លោក អៀង សារី។ ដូច្នេះ វាពិតជាសេចក្តីសម្រេចរបស់ ប៉ុល ពត ហើយ។ តើលោកបានទៅចូលរួមការប្រជុំគណៈមជ្ឈិមដែរឬទេ?

**ឆ៖** ខ្ញុំគ្មានតួនាទីអីទៅចូលរួមប្រជុំគណៈមជ្ឈិមហ្នឹងទេបាទ។

**ស៖** អ៊ីចឹងតើមានការបញ្ជូនកំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍ ជូនលោក ហើយដើម្បីឲ្យលោកដឹងថា មានការសម្រេចដែលធ្វើដោយ ប៉ុល ពត ហើយនិងសេចក្តីសម្រេចដែលធ្វើជាសមូហភាពនៅគណៈអចិន្ត្រៃយ៍។ លោកសាក្សី តើលោកដែលទទួលកំណត់ហេតុកិច្ចប្រជុំនៅគណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** ខ្ញុំមិនដែលបានទទួលទេ បាទ។

[១៥:១៥:០៨]

**ស៖** បាទ លោកសាក្សីសូមអរគុណ។ បើតាមអតី -- ក្នុងចំណោមអតីតអ្នកការទូតនៅមុនឆ្នាំ១៩៧៥ ដែលត្រូវបានហៅឲ្យមកប្រទេសកម្ពុជាវិញនៅចុងឆ្នាំ១៩៧៥ តើលោកអាចឲ្យឈ្មោះអ្នកការទូតទាំងអស់ហ្នឹង ហើយនិងមុខតំណែងរបស់គាត់បានដែរឬទេ?

**ឆ៖** ខ្ញុំដឹងថាមានលោក សារិន ឆាក គាត់ជារដ្ឋមន្ត្រីក្រសួងការបរទេសនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ លោក ជា សាន ឯកអគ្គរដ្ឋទូតប្រចាំសហភាពសូវៀត។ លោក ហួត សម្បត្តិ ឯកអគ្គរដ្ឋទូតប្រចាំនៅយូហ្គោស្លាវី។ លោក អ៊ី ស៊ុបគន្ធី ភារធារីស្តីទីប្រចាំស្ថានទូតនៅអាល់បានី។ ព្រះអង្គអ្នកអង្គម្ចាស់មេធាវី ភារធារីស្តីទីប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ និងអ្នកផ្សេងទៀតខ្ញុំចាំមិនអស់ទេបាទ។ ហើយពេលសព្វថ្ងៃ ពេលឥឡូវនេះក៏ខ្ញុំនឹកឃើញមិនអស់ដែរបាទ។

**ស៖** តើ នូ ប៊ិច ហៅ ពេញ (ស៊ិក) ហ្នឹងតើជាឈ្មោះដែលលោកស្គាល់ដែរឬទេ ដែលជាអ្នកការទូតនៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា?

[១៥:១៧:០៦]

**ឆ៖** បាទ លោក នូ ប៊ិច ហ្នឹងគាត់ឯកអគ្គរដ្ឋទូតប្រចាំឈីលីនៅពេលនោះបាទ។

**ស៖** ហើយ អ៊ិន សូផន។ បាទ សុំទោសបើសិនជាខ្ញុំអានមិនសូវត្រូវ។ តើគាត់ជាអ្នកទទួលបន្ទុកភារធារីនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមែនទេ នៅប្រទេសអាល់បានី?

**ឆ៖** បាទ អ៊ិន សូផន គឺគាត់ជាប្អូនរបស់ អ៊ិន សូកាន ហ្នឹង។ អ៊ិន សូកាន ជាអតីតប្រធានសហភាពនិស្សិតខ្មែរនៅប្រទេសបារាំងហ្នឹង។ គាត់ -- បាទចុងក្រោយហ្នឹងគាត់ធ្វើជាភារធារីនៃស្ថានទូតកម្ពុជានៅប្រទេសអាល់បានីបាទ។

**ស៖** នៅក្នុងក្រុមអ្នក -- អតីតអ្នកការទូតនោះ តើមានពួកគាត់ប៉ុន្មាននាក់ដែលបានឆ្លងមកក្រសួងការបរទេស ពេលដែលគាត់ត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ -- នៅចុងឆ្នាំ១៩៧៥? តើពួក

គាត់មានចំនួនប៉ុន្មាននាក់ដែរដែលមកឆ្លងនៅក្រសួងការបរទេសនេះ?

[១៥:១៨:៣៧]

**ឆ៖** មែនទែនទៅពួកន៎ែ ឯកអគ្គរដ្ឋទូត ឬអ្នកការទូតទាំងនោះ ពេលត្រឡប់ចូលមកក្នុងប្រទេសវិញ មិនបានឆ្លងកាត់តាមក្រសួងការបរទេសទេ ដែលខ្ញុំដឹងហ្នឹង ព្រោះនៅពេលនុ៎ងគឺថាលោក អៀង សារី បានហៅខ្ញុំទៅទទួលពួកគេនៅកន្លែង នៅផ្ទះមួយនៅៗក្នុងក្រុងភ្នំពេញ ខ្ញុំមិនចាំនៅកន្លែងណា ប៉ុន្តែខ្ញុំបានជួបគេនៅពេលនោះ។ ប៉ុន្តែពួកនេះមិនបានឆ្លងតាមរយៈក្រសួងការបរទេសទេ លើកលែងតែលោក តូច ខាំឌឿន ដែលជាអតីតប្រធានសហភាពនិស្សិតខ្មែរប្រចាំប្រទេសបារាំង ហើយជាអតីតសមាជិក គាត់ជាបក្ខជនដែរ អតីតសមាជិកវង់ ម៉ាក្ស-ឡេនីន ហ្នឹងគាត់ឆ្លងមក គាត់មកឆ្លងកាត់មកធ្វើការនៅក្រសួងការបរទេសបាទ។ ហើយនិងលោក សារិន ឆាក មួយរយៈ ជាមួយនឹងលោកឧត្តមសេនីយ៍ ដួង សំអុល មកក្រសួងការបរទេសមួយរយៈបាទ។

[១៥:២០:០៣]

**ស៖** តើក្រសួងការបរទេស ជាអ្នកទទួលអតីតឯកអគ្គរាជទូត នៅព្រលានយន្តហោះពោធិ៍ចិនតុងឬ?

**ឆ៖** ខ្ញុំមិនបានដឹងថា អ្នកណាទៅទទួលគាត់ទេ -- ពួគាត់ទេ ប៉ុន្តែខ្ញុំដែលខ្ញុំដឹង គឺថាខ្ញុំបានទៅជួបគាត់នៅពេលដែលគាត់មកដល់ភ្នំពេញហើយ នៅផ្ទះមួយនៅក្នុងទីក្រុងភ្នំពេញតែប៉ុណ្ណោះ។ ហើយបន្ទាប់ពីជួបនោះ គេបញ្ជូនគាត់ទៅណា ខ្ញុំក៏អត់បានដឹងដែរបាទ។

**ស៖** បាទ នៅពេលដែលលោកបានជួបគាត់នៅផ្ទះមួយនៅទីក្រុងភ្នំពេញ តើនេះនៅក្នុងក្របខ័ណ្ឌនៃមុខងាររបស់លោកនៅក្រសួងការបរទេស ឬក៏យ៉ាងណា?

**ឆ៖** បាទ ពេលនុ៎ងខ្ញុំទៅជាមួយលោក អៀង សារី ហើយនិងកម្មាភិបាលក្រសួងការបរទេសមួយចំនួនទៀត ប៉ុន្តែខ្ញុំមិនចាំថាអ្នកណាទេបាទ។

[១៥:២១:២៨]

**ស៖** ហើយនៅជួបគ្នានោះ នៅកន្លែងណារវាងលោក អៀង សារី, លោក ហើយនិងកម្មាភិបាលផ្សេងៗទៀត ហើយនិងអតីតអ្នកការទូតទាំងអស់ហ្នឹង កន្លែងហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំមិនបានចាំទេបាទ ព្រោះទី១ ខ្ញុំស្គាល់ទីក្រុងភ្នំពេញមិនច្បាស់ ហើយពេលវេលាក៏យូរដែរហើយ ហើយខ្ញុំក៏មិនបានយកចិត្តទុកដាក់អីទេ ព្រោះរឿងហ្នឹងវាចំពោះខ្ញុំវាដូចអត់មានសារសំខាន់អីទេ។

**សះ** តើនៅពេលក្រោយមកទៀត លោកដឹងអំពីជោគវាសនារបស់មនុស្សទាំងអស់នេះ តើអ្នកការទូតទាំងអស់នេះ ដែលជោគវាសនារបស់គេហ្នឹងត្រូវបានកំណត់ដោយរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា ជី សាន, ស៊ុបគន្ធី, ហួត សម្បត្តិ, នូ ប៊ុច ហៅ ស៊ិន, អ៊ិន សូផន, ស៊ីសុវត្ថិ មេធាវី តើមានរឿងអ្វីកើតឡើងចំពោះពួកគាត់ទាំងអស់នេះ?

[១៥:២២:៤៥]

**ឆះ** នៅពេល គឺថានៅពេលនោះ ខ្ញុំអត់បានដឹងពីអ្វីដែលកើតឡើងចំពោះអ្នកទាំងនោះទេ។ ព្រោះមិនមែននៅក្នុងក្របខ័ណ្ឌនៃភារកិច្ចរបស់ខ្ញុំបាទ។ ហើយអ្វីដែលខ្ញុំដឹង គឺខ្ញុំដឹងក្រោយថ្ងៃ -- ក្រោយឆ្នាំ១៩៧៩ មកខ្ញុំដឹងបាទ។

**សះ** តើលោកដឹង -- តើលោកអាចជម្រាបយើងបានទេ អំពីអ្វីដែលលោកដឹងនៅ ដែលឆ្នាំ៧៩ ហើយនេះ ដឹងអំពីអ្វីដែលកើតមានឡើងចំពោះរូបពួកគាត់ទាំងអស់គ្នាហ្នឹង លោកអាចជម្រាបជូនបានទេ?

**ឆះ** ការដឹងនេះ មិនមែនដឹងជាគឺថា ដឹងទាំងដុលជាដំណឹងដូចថា បាត់អ្នកនេះ បាត់អ្នកនោះ គឺថាដឹងមួយៗអ៊ីចឹងទៅ ហើយខ្ញុំក៏មិនចាំដែរ។ មិនចាំថានេះទេ ហើយជាពិសេសមានអ្នកដែលជានិស្សិតនៅ -- ធ្លាប់នៅទីនោះ ដែលគេជួបខ្ញុំក្រោយមកនៅប៉ារីស ឬនៅស្រុកខ្មែរក្រោយមក គេប្រាប់ហើយបាទ ព្រោះគេធ្លាប់នៅជាមួយអ្នកទាំងនោះបាទ។ ប៉ុន្តែថា ឲ្យខ្ញុំដឹងថា អ្នកណាបាត់ពីឆ្នាំណា កន្លែងណា ថ្ងៃណាអី ខ្ញុំមិនបានដឹងច្បាស់អ៊ីចឹងទេ បាទ។

[១៥:២៤:៣៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្លាឯលះ**

បាទ សូមអរគុណលោកសាក្សី។ លោកប្រធាន ដើម្បីកត់ត្រា ខ្ញុំចង់លើកឡើងថា ឈ្មោះ នូ ប៊ុច ហៅ ស៊ិន ហើយនិង ស៊ី សាន ហៅ -- ឈាន សាន ហៅ ជា មាននៅលើឯកសារ IS5.70។ នេះគឺជាបញ្ជីអ្នកទោសនៅមន្ទីរស-២១ ហើយនៅក្នុងឯកសារនេះមានសរសេរថា "ពួកគាត់ទាំងអស់គ្នាបានឆ្លងកាត់តាមមន្ទីរក-១៧" ហើយមានឈ្មោះឯកសារមួយទៀត ដែលមានឈ្មោះ អ៊ិន សូផន នៃក្រសួងការបរទេស គឺឯកសារ D199/14.5 គឺជាបញ្ជីប្រហារជីវិតនៅមន្ទីរស-២១ ដែលមានឈ្មោះថា "ឈ្មោះអ្នកទោសដែលត្រូវបានប្រហារជីវិតនៅថ្ងៃទី៩ ធ្នូ ឆ្នាំ១៩៧៧"។ ហើយបន្ទាប់មកទៀត គឺទាក់ទងនឹងលោក ហួត សម្បត្តិ គឺថាមានឯកសារ IS5.31 ដែលមានឈ្មោះលោក ហួត សម្បត្តិ នៅមន្ទីរស-២១ ហើយនិងចំពោះលោក គន្ធី គឺថាលេខឯកសារ D366/7.1.83 ដែលជាចម្លើយសារភាពរបស់

លោក គន្ធី។ ទាក់ទងទៅនឹងលោក ខាំឡឿន លោកសាក្សី លោកបាននិយាយថា គាត់ជាសមាជិកវង់ម៉ាក្ស-ឡេនីន តើលោកជាសមាជិកជាមួយគាត់ដែរ នៅការិយាល័យសមាគមនិស្សិតខ្មែរនៅទីក្រុងប៉ារីសនោះ លោកជាសមាជិកដែរមែនទេ?

[១៥:២៦:៣១]

**ឆៈ** បាទខ្ញុំជាសមាជិកវង់ម៉ាក្ស-ឡេនីន ជាសមាជិកការិយាល័យនែ៎ វង់ម៉ាក្ស-ឡេនីន ជាមួយលោក តូច ខាំឡឿន ហើយក្រោយពីគាត់សុំលាលែងពីតំណែង ជាប្រធានសហភាពនិស្សិតខ្មែរគឺថា ខ្ញុំជំនួសគាត់នៅជាប្រធានសហភាពនិស្សិតខ្មែរបាទ។

**សៈ** នៅពេលដែលគាត់ត្រឡប់មកប្រទេសកម្ពុជានោះ តើគាត់បានធ្វើការនៅ*បេអង* -- មន្ទីរប-១ដែរឬទេ?

**ឆៈ** បាទ គាត់ធ្វើការនៅក្រសួងការបរទេសបាទ។

**សៈ** ហើយមានរឿងអីកើតឡើងចំពោះ តូច ខាំឡឿន ហើយនិងប្រពន្ធរបស់គាត់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆៈ** គាត់ធ្វើការ ហើយផ្ទះគាត់ហ្នឹង នៅជាប់ផ្ទះរបស់ខ្ញុំ ហើយខ្ញុំ និងគាត់ និងប្រពន្ធគាត់ហ្នឹងគឺជាមិត្តជិតស្និទ្ធនឹងគ្នាណាស់ ហើយកូនគាត់ស្រីហ្នឹង កូនបងគាត់ស្រីហ្នឹងជា គេហៅថា ជាកូនចិញ្ចឹមរបស់ខ្ញុំទៀត។ ដូច្នោះការទាក់ទងនេះជិតស្និទ្ធណាស់ ជាកូនធម៌ៗបាទ។ អឺ! ថ្ងៃដែលគាត់ចេញពីផ្ទះហ្នឹងទៅ ខ្ញុំចាំច្បាស់ គឺនៅខែ៣ ឆ្នាំ១៩៧៧ ពេលនោះគឺលោក អៀង សារី ត្រូវចេញទៅធ្វើទស្សនកិច្ចនៅប្រទេសម៉ាឡេស៊ី និងសិង្ហបុរី ជាមួយលោក ជួន ប្រាសិទ្ធ។ ហើយពេលដែលចេញទៅនេះ គឺថាប្រពន្ធគាត់អរណាស់ គឺគាត់យល់ថា គេឲ្យគាត់ទៅជនបទ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺថាបើកម្មាភិបាល អ៎! បើបញ្ញាជនណាមកពីក្រៅប្រទេស ហើយឲ្យទៅលត់ដំនៅជនបទ គឺថាជាកិត្តិយសជាការទុកចិត្តមួយកម្រិត ប្រពន្ធគាត់អរណាស់ ហើយអ្នកជិតខាងហ្នឹង ក៏និយាយប្រាប់គ្នាតៗគ្នាថា គេឲ្យគាត់ទៅបង្រៀនអង់គ្លេស ភាសាអង់គ្លេសនៅជនបទ នែ៎ ហើយខ្ញុំបានដឹងពីការចាប់ខ្លួនរបស់គាត់ពេលក្រោយមកទេបាទ។

[១៥:២៩:៣២]

**សៈ** បាទដូច្នេះ បើសិនជាខ្ញុំយល់មិនច្រឡំទេ គឺថាលោកមិនបានចូលរួមក្នុងការចាប់ខ្លួន របស់គាត់ទេ ពីព្រោះថា ពេលនោះគាត់ទៅជនបទគ្រួសារទាំងអស់។ តើលោកបាន មានបានឃើញគាត់ទេនៅពេល

ដែលគាត់ចេញពីមន្ទីរប-១ នោះ លោកមាននឹកឃើញថា អ្នកណាជាអ្នកនាំគាត់ចេញទៅ អ្នកដឹកគាត់ចេញទៅជនបទនោះ លោកមានបានឃើញអ្នកណាទេ អ្នកដឹកគាត់ចេញទៅនោះ?

**ឆ៖** ខ្ញុំមិនបានឃើញទេ ប៉ុន្តែខ្ញុំឃើញគាត់រៀបចំសាខោអាវអី គឺថា រៀបចំដំណើរចេញទៅអាហ្នឹងខ្ញុំបានឃើញ ត្រង់ថា អ្នកណា ឡានអ្នកណាគេមកយកគាត់ ខ្ញុំមិនបានដឹងទេបាទ។

[១៥:៣០:២៥]

**ស៖** តើលោក អៀង សារី បាននិយាយប្រាប់លោកអំពីការចាប់ខ្លួនរបស់លោក តូច ខាំឌឿន ដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ គឺក្នុងពេលប្រជុំមួយ ក៏គេថា គាត់សរសេរ គាត់អានចម្លើយសារភាពរបស់ តូច ខាំឌឿន។ ចម្លើយសារភាពនេះមាន ខ្ញុំសូមសរុបខ្លឹមសារខ្លះៗ គឺហេតុអ្វីបានគេចាប់គាត់ គឺ តូច ខាំឌឿន ហ្នឹង ទទួលការចាត់តាំងអំពីបងគាត់ គឺ តូច ភឿន។ តូច ភឿន ហ្នឹង គឺជារដ្ឋមន្ត្រីក្រសួងសាធារណការនៃកម្ពុជាប្រជាធិបតេយ្យ។ តូច ភឿន ហ្នឹង គាត់ជា នៅពេលក្នុងរបបលោកសេនាប្រមុខ លន់ នល់ ពេលសង្គ្រាមពីឆ្នាំ១៩៧០ ដល់៧៥ គាត់ជាបណ្តាញសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជាបង្កប់នៅទីក្រុងភ្នំពេញ។

[១៥:៣១:៣៥]

បន្ទាប់មក គឺថាបណ្តាញសម្ងាត់របស់បក្សកុម្មុយនីស្តកម្ពុជាទាំងអស់ហ្នឹង រួមទាំងអ្នកទទួលខុសត្រូវរបស់បណ្តាញនេះ ដែលឈ្មោះ សុខ ត្រូវបានគេចោទប្រកាន់ បានអ្នកដឹកនាំកម្ពុជាប្រជាធិប-តេយ្យចោទថា ជាបណ្តាញរបស់អង្គការចារកម្មសហរដ្ឋអាមេរិក ដែលហៅថា សេ.អ៊ី.អា នេះ។ ដូច្នោះ គេចាប់ទាំងអស់ ចាប់ទាំង តូច ភឿន នោះ។ តូច ភឿន ក៏ចាត់តាំងតាមចម្លើយសារភាពនេះ តូច ភឿន បានចាត់តាំង តូច ខាំឌឿន ហ្នឹង ឲ្យសរសេរពីភាពការណ៍ដែលកើតឡើងនៅក្នុងកម្ពុជាប្រជាធិប-តេយ្យហ្នឹង ព័ត៌មានអំពីសភាពការណ៍នេះ គឺថា តូច ភឿន គាត់អ្នកផ្តល់ព័ត៌មានឲ្យ។ តូច ខាំឌឿន ហ្នឹង សរសេរទៅ បកប្រែជាភាសាអង់គ្លេស បញ្ជូនចេញទៅក្រៅ ដោយប្រពន្ធគាត់ តូច វណ្ណាហ្នឹង ជា--ធ្វើការជាពិធីការ។ ដូច្នោះ ពិធីការមានសិទ្ធិទាក់ទងជាមួយស្ថានទូតបរទេសប្រចាំទីក្រុងភ្នំពេញហ្នឹង។ ហើយស្ថានទូតដែលអ្នកបញ្ជូនឯកសាររបស់ តូច ខាំឌឿន ទៅក្រៅប្រទេសហ្នឹង គឺជាស្ថានទូតនៃប្រទេសអេហ្ស៊ីប។ ដូច្នេះ វាដំណើរទំនងបែបផែនរឿងហ្នឹង វា ដូចថាវាមានឡូហ្ស៊ីករបស់វាណាស់ គួរឲ្យជឿបានណេះ បើតាមដំណើររឿងអ៊ីចឹង។ ប៉ុន្តែវាដូចជាគេតែងរឿងមួយ មានអ្នកដើរតួកុន ដើរតួ ហើយ

ការដើរតួ វាសមល្មមជាក្នុងការជីវិតជាក់ស្ដែងអ៊ីចឹងណ៎ាបាទ។ អាហ្នឹងតាមដំណើរអ៊ីចឹង។ ដូច្នោះ តូច ខាំឿន ហ្នឹង ជាអ្នកផ្ដល់ -- សរសេរព័ត៌មាន ផ្ដល់ព័ត៌មានហ្នឹង ទៅឲ្យក្រៅប្រទេស ទៅឲ្យបណ្ដាញ សេ.អ៊ី.អា នៅប្រទេស តាមរយៈស្ថានទូតអេហ្ស៊ីប ប្រចាំទីក្រុងភ្នំពេញ។ បាទ ដំណើររឿងវាអ៊ីចឹង បាទ។

[១៥:៣៣:៥៥]

**ស៖** សូមអរគុណ។ សម្រាប់ជាប្រតិចារឹក ខ្ញុំឮអ្នកបកប្រែនិយាយអំពី ឌុក ខាំឿន ក៏ប៉ុន្តែ ចំពោះខ្ញុំនោះ គឺខ្ញុំសំដៅទៅឈ្មោះ តូច ខាំឿន និង តូច ភឿន ទេ មិនមែន ឌុក ខាំឿន ទេ។ បកប្រែជា ភាសាបារាំងមក ឮតែ ឌុក ខាំឿន ទៅវិញ។ លោកសាក្សី លោកបានបញ្ជាក់ថា លោកបានអាន -- លោក អៀង សារី បានអានចម្លើយសារភាពរបស់លោក តូច ខាំឿន នៅក្នុងកិច្ចប្រជុំ។ តើកិច្ចប្រជុំនេះ កើតឡើងនៅពេលណា? ហើយអ្នកណាខ្លះដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ ថ្ងៃកាលបរិច្ឆេទ ហើយអ្នកណា គឺថាមានវត្តមាននៅកន្លែងនោះ ក៏ខ្ញុំចាំ មិនច្បាស់ដែរ។ ខ្ញុំគ្រាន់តែអាចថា និយាយបានថា នៅក្នុងរយៈ គឺថាឆ្នាំ១៩៧៧ ហើយអ្នកដែលមាន វត្តមានពេលនោះ គឺថាអ្នកដែលធ្វើការងារកម្មាភិបាល ដែលធ្វើការងារជាមួយខ្ញុំនៅក្នុងក្រសួងការបរទេស ផ្នែកការិយាល័យ ផ្នែកការងារទូតហ្នឹង។ ដែលសុទ្ធៗតែជាពួកម៉ាកជិតស្និទ្ធរបស់ តូច ខាំឿន គឺដូចជា លោក ជួន ប្រាសិទ្ធ, លោក គាត ឈន់, លោក ឱក សុគន្ធ ជាដើមបាទ។

[១៥:៣៥:៤៧]

**ស៖** នៅក្នុងពេលប្រជុំនោះ តើ អៀង សារី គាត់យល់ឃើញថា ការចោទ ឬក៏ការក្បត់ដែល បានសរសេរនៅក្នុងចម្លើយនោះ អាចជឿជាក់បានដែរឬទេ?

**ឆ៖** ខ្ញុំធ្វើសេចក្ដីសន្និដ្ឋានមិនបានទេ ប៉ុន្តែខ្ញុំគ្រាន់តែបញ្ជាក់ថាលោក អៀង សារី គាត់ជិតស្និទ្ធ ជាមួយលោក តូច ខាំឿន ណាស់ ហើយបញ្ហានេះ ខ្ញុំដឹងច្បាស់ ហើយពេលដែលគេមកចាប់លោក តូច ខាំឿន ហ្នឹងគឺថាពេលដែលគាត់មិននៅ។ ខ្ញុំអាចច្បាស់ ខ្ញុំអាចថាច្បាស់ថា បើពេលគាត់នៅប្រហែល ជាមិន ព្រឹត្តិការណ៍ហ្នឹងមិនមានកើតឡើងទេបាទ។

[១៥:៣៦:៥០]

**ស៖** អ៊ីចឹងមាន -- លោកចង់មានន័យថាដោយសារតែគាត់ស្គាល់ តូច ខាំឿន តាំងពីនៅស្រុក បារាំង ហើយគាត់ជាអ្នកជិតស្និទ្ធនឹង អៀង សារី។ អ៊ីចឹងបាន អៀង សារី ការពារគាត់អ៊ីចឹងមែនទេ?

**ផ៖** អាហ្នឹងវាថាអ៊ីចឹងក៏បានដែរ ព្រោះ អៀង សារី គាត់បានការពារកម្មាភិបាលមួយចំនួនច្រើននៅក្រសួងការបរទេសហ្នឹង គឺថាក្នុងដោយសារ មិនមែនដោយសារជិតស្និទ្ធជាមួយគាត់ ហើយដោយសារអ្នកហ្នឹងការដែលភស្តុតាងអីហ្នឹង គឺខ្ញុំចង់ជម្រាបថាការចម្លើយសារភាពនេះវា គេតែងរឿងទេ បើឧទាហរណ៍ដូចខ្ញុំៗផ្ទាល់ហ្នឹង ក្នុងចម្លើយសារភាពដដែលហ្នឹង តូច ខាំឡឿន ដដែលហ្នឹង ខ្ញុំហ្នឹងនៅប៉េកាំង ខ្ញុំជាភ្នាក់ងាររបស់អង្គការ កា.ហ្សេ.បេ នៅប៉េកាំងហ្នឹង ខ្ញុំយកការណ៍ឲ្យសហភាពសូវៀត ហើយដល់មកភ្នំពេញហ្នឹង ខ្ញុំជាភ្នាក់ងាររបស់ សេ.អ៊ី.អា ហើយនៅក្រុមៗខ្ញុំហ្នឹងមានឈ្មោះប្រាំនាក់ ហើយក្រុមហ្នឹងឈ្មោះ ស-៨០៨។ មានឈ្មោះអ៊ីចឹងទៀត ឈ្មោះ ស-៨០៨ ច្បាស់ថែស។ ហើយប្រជុំហ្នឹងប្រាំនាក់ប្រជុំប្រចាំអាទិត្យនៅការិយាល័យលោក ជួន ប្រាសិទ្ធ។ ប្រាំនាក់ហ្នឹងមានខ្ញុំ សួង ស៊ីគឿន, ជួន ប្រាសិទ្ធ, គាត ឈន់, តូច ខាំឡឿន និង ហាក់ សៀងឡាយនី។ ហាក់ សៀងឡៃនី ហ្នឹងគាត់មិនមែនជាភ្នាក់ងារ សេ.អ៊ី.អា ទេ ព្រោះគាត់ជាប្រធានគណបក្សកុម្មុយនីស្តខ្មែរនៅសហភាពសូវៀត។ បក្សកុម្មុយនីស្តដែលនិយមសូវៀត។ ដូច្នោះ យើងឃើញថាអាចម្លើយសារភាពហ្នឹងវាជាការតែងសេចក្តីបង្ខំ។ ដូច្នេះមិនអាចឲ្យជឿបានទេ គ្រាន់ដូចថា គ្រាន់ដូច្នោះលោកច្បាស់ណាស់អាកន្លែងហ្នឹងច្បាស់ណាស់បាទ។

[១៥:៣៩:១៨]

**ស៖** អម្បាញ់មិញនេះ លោកបានបញ្ជាក់ថាអ្វីដែលគេរៀបរាប់នោះ គឺអាចជឿជាក់បាន។ ក៏ប៉ុន្តែខ្ញុំចង់និយាយអំពីការឆ្លើយដាក់កម្មាភិបាលមួយចំនួននៅប-១ ដែលនោះ ក្នុងនោះមានលោកខ្លួនឯងផងគាត ឈន់, ជួន ប្រាសិទ្ធ, និង ហាក់ សៀងឡាយនី អីជាដើម។ តើលោកចង់មានន័យអ៊ីចឹងមែនទេ?

**ផ៖** បាទ ព្រោះអាហ្នឹងភ្នាក់ងារ សេ.អ៊ី.អា ហើយច្បាស់ៗអ៊ីចឹង អាហ្នឹងអត់មានអីសង្ស័យទេ គេចាប់ភ្លាមតែម្តង។ ក៏ប៉ុន្តែគ្រាន់ថាបើចាប់ទាំងអស់ហ្នឹងទៅ បិទទៅក្រសួងការបរទេសហ្នឹង បើអស់ក្រសួងការបរទេស មិនបាច់ៗធ្វើការអីទៀតទេ។ ដូច្នោះវា អាហ្នឹងវាដូចថា វាហួសហេតុពេកណាបាទ។

[១៥:៤០:២៦]

**ស៖** សូមអរគុណ។ ជាទូទៅ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបាននិយាយអំពីការឆ្លើយដាក់អម្បាញ់មិញ។ តើមានរឿងអ្វីកើតឡើងដែរនៅពេលដែលអ្នកណាម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងឯកសារនោះ? ហើយត្រូវមានការឆ្លើយដាក់ប៉ុន្មានដែរ ដើម្បីឲ្យមានផលវិបាកដល់បុគ្គលនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា មិនគ្រាន់តែឆ្លើយដាក់ទេ គេហៅថាមានឯកសារ។ ដើមឡើយៗ នៅឆ្នាំ ៧៦, ៧៧អី បើជាអ្នកណាម្នាក់មានឯកសារបី ឯកសារហ្នឹងខ្ញុំចង់និយាយថាម៉េច។ ឧបមាថា ខ្ញុំមានមិត្តភក្តិនៅក្រសួងសាធារណការអីចឹង ដល់ពេលល្ងាចគេជប់លៀងតូចតាចហ្នឹង គេហៅខ្ញុំទៅចូលរួម។ ខ្ញុំក៏ទៅចូលរួមនោះ ព្រោះពេលដែលគេធ្វើអី រដ្ឋមន្ត្រី ដូចថា លោក តូច ភឿន គាត់រដ្ឋមន្ត្រី ក្រសួងសាធារណការ គាត់យ៉ាងហោចណាស់ ក៏គាត់មានជើងមាន់អីឱ្យហូបដែរ ជាជាងអាការហូបបបរពេល៧៦ហ្នឹង ទាំងអស់គ្នាហូបបបរ។ ប៉ុន្តែពេលនុ៎ង គឺថាខ្ញុំឃើញក្រពះ គេឱ្យហូបបបរ អត់មានបញ្ហាទេបាទ។ ដូច្នោះ ទៅហូបហើយ ទៅជប់លៀងអីជាមួយគេ។ អ្នកឯងចូលជប់លៀងហ្នឹង បើសិនជាក្នុង -- ដល់ក្រោយមក បើសិនជាក្នុងអ្នកចូលរួមប្រជុំហ្នឹងគេចាប់ម្នាក់ទៅ យើងទៅចូលរួមប្រជុំហ្នឹង យើងចូលរួមជប់លៀងហ្នឹង យើងអត់មានអីសោះ យើងបានមួយឯកសារដែរ។ ហើយតែទៅបីដង បានបីឯកសារ។

[១៥:៤២:១១]

លោក គាត ឈន់ គាត់មានពួកម៉ាកច្រើន គាត់ទៅចូលរួមច្រើនដែរ។ គាត់បបួលខ្ញុំទៅ ថាខ្ញុំអត់ទេ ខ្ញុំមិនទៅទេ ខ្ញុំឈឺក្រពះផង ខ្ញុំទៅជប់លៀងមិនកើតទេ។ ហើយខ្ញុំក៏អត់ទៅ ខ្ញុំរួចខ្លួន។ គាត់មានជាង ៦០ឯកសារ។ ដូច្នេះ បី (ឮមិនច្បាស់) ដល់អីចឹងអត់មានបញ្ហាទេ ចាប់យ៉ាងស្រួល។ ដល់ក្រោយមក បីឯកសារអីចឹង ឆ្លើយដាក់អីចឹង ហើយរបៀបអីចឹងវាច្រើនពេកៗ បានគេបន្ថែមពីរឯកសារ រួចបានប្រាំ។ ដូច្នោះខ្ញុំរួចខ្លួន បីឯកសារហ្នឹងបានរួចខ្លួន។ ប្រាំឯកសារ ខ្ញុំរួចខ្លួន ហេតុអ្វី? ឥឡូវខ្ញុំសូមជម្រាបព្រោះសូមអត់ទោស អារឿងហ្នឹងវាគឺថា បីឯកសារ បួនឯកសារ គឺមានឈ្មោះខ្ញុំ គេចោទខ្ញុំ។ ចោទខ្ញុំថាម៉េច? ថា ស្លូង ស៊ីគឿង ហ្នឹងជាសេរីវ ៗគឺថានិយមសូវៀតណ៎ះ និយមសូវៀត និយមវៀតណាមនេះ អាហ្នឹងសេរីវហើយ។ មិនតាមមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា សេរីវបួន។ ហើយក្រឡាស់ឯកសារហ្នឹង អ្វីបានក្រឡាស់? គឺ ហេង ពេជ នេះគេចាប់ ហេង ពេជៗ ជានិស្សិតមកពីសហភាពសូវៀត។ ហេង ពេជគេឆ្លើយថា ពួកមកពីស្រុកបារាំងទាំងអស់សុទ្ធតែពួកសេរីវ។ ប៉ុន្តែគាត់អត់និយាយឈ្មោះ អត់និយាយឈ្មោះ គាត់ថា ៗពួកអ្នកមកពីស្រុកបារាំងសុទ្ធតែសេរីវ។ ដូច្នោះ វាអត់មានឈ្មោះខ្ញុំទេ ដូច្នោះដាក់មួយឯកសារម៉េចកើត បើអត់មានឈ្មោះខ្ញុំ។ ក៏ប៉ុន្តែគេឱ្យពិន្ទុដែរ គេឱ្យកន្លះ។ ដូច្នោះមានបួនកន្លះ។ ខ្ញុំរួចខ្លួនទៅបួនកន្លះ ព្រោះគេយកទាល់តែប្រាំឯកសារបានចាប់ខ្លួនបាន។

[១៥:៤៣:៥៥]

ក៏ប៉ុន្តែ ខ្ញុំសូមជម្រាបនៅក្រសួងការបរទេសនោះ មានតែខ្ញុំទេមានឯកសារតិចជាងគេ។ អ៊ីចឹងបានក្នុង ខ្ញុំមើលក្នុងវេបសាយណាមួយនេះ គឺដាក់រូបខ្ញុំហ្នឹងគឺថា អ្នកបន្តវេនពី ប៉ុល ពត។ គេដាក់ខ្ញុំអ៊ីចឹងណ៎ា។ (សើច) អ្នកបន្តវេនពី ប៉ុល ពត ហើយជួនកាលចេញពីសាលាហ្នឹងទៅ គេថាខ្ញុំទៀតហើយ ចាំមើល៍ អាស៊ីសេរី ឬក៏ថា វី.អូ.អេ ហ្នឹងគាត់ថាម៉េចអាហ្នឹង ចាំមើល ចាំទៀត ជួនកាលអាចេញវេបសាយ ចេញរបៀបអ៊ីចឹង។ វារបៀបនេះ។ អាហ្នឹង ខ្ញុំចង់ជម្រាបថា ឯកសារអីមានអ៊ីចឹង។ ដូច្នោះវាដល់ក្រោយមក៧៥, ៧៨ ជាប្រវត្តិសាស្ត្រ ៧៨បានមាន គឺថាឯកសារ គឺថាលើកលែងទោសអនុគ្រោះ៨ចំណុច។ ពេលនោះហើយ ដែលឈប់មានការបែងចែករវាងប្រជាជនថ្មី និងប្រជាជនចាស់។

[១៥:៤៤:៥៥]

ហើយវាសភាពការណ៍វាសម្រួល គឺថាឯកសារប្រាំបី ឯកសារនេះ គឺថាជាអ្នកស្រី អៀង ធីរិទ្ធ ដែលគាត់អ្នកផ្ដើមផ្ដួច។ អង្កាល់ហ្នឹងគាត់ប៊ាននិយាយជាមួយ ប៉ុល ពត ព្រោះត្រូវជាប្អូនថ្លៃ។ មែនទែនលោក អៀង សារី មិនសូវប៊ានទេ ប៉ុន្តែនារីប៊ាននិយាយជាង ហើយជាពិសេសបងប្អូនថ្លៃប៊ាននិយាយ។ ឃើញទេ មិនមែនប៉ុន្តែដល់ក្រោយមក ប៉ុល ពត គាត់ការប្រពន្ធថ្មីទេ រឿងវាផ្សេងទៅទៀត ឃើញទេរឿងរ៉ាវដែលខ្ញុំចង់និយាយប្រាំបីឯកសារហ្នឹង។ ប៉ុន្តែដូច្នោះរឿងនេះ គឺថាវាយើងមិនយល់ទេ ឧបមាថាឥឡូវគេចោទខ្ញុំអ៊ីចឹង អ្នកដែលចោទហ្នឹងគេអត់ឲ្យទល់មុខគ្នា តែចោទបានហើយ គឺថាចោទ ចង់មូលបង្កាច់ហ្នឹងបានហើយ អ៊ីចឹងបានថាវាវិនាសកម្ម វាមានអ៊ីចឹង។ ហើយការវិនាសកម្មនេះគឺខ្ញុំឃើញថានៅទួលស្លែង ខ្ញុំទៅជា មើលទួលស្លែង គឺថាមិត្តភក្តិខ្ញុំដែលស្លូតត្រង់ ខ្ញុំៗហួសៗចិត្តតែម្ដង ស្លូតត្រង់ហើយជាធ្វើគ្រូពេទ្យ ហើយស្លូត ហើយគឺថាមនុស្សល្អ គឺយកគ្នាទៅសម្លាប់ចោល វាអាណោចអាធ័មណាស់។ អ៊ីចឹងបានខ្ញុំឃើញថា សូមអត់ទោសបងៗ ខ្ញុំថា បើខ្ញុំដឹងមុន ខ្ញុំអត់ចូលជិតទេ។ ប៉ុន្តែសំណាងខ្ញុំ បើសិនខ្ញុំដឹងនៅពេលនោះ ខ្ញុំក៏មិនបានរស់ដែរ ព្រោះខ្ញុំៗមិនខ្លាចទេ វាដល់ក វាដល់ ដូចថាធ្វើដល់អ៊ីចឹង វាមិនមែនអីជាសង្គមនិយម មិនមែនអីជាបដិវត្តន៍ មិនមែនអីជាបម្រើប្រជាជន បម្រើជាតិទេណេះ។ ខ្ញុំឈឺចាប់ណាស់ ហើយខ្ញុំឃើញលោកប្រធាន ខ្ញុំបងៗដែលគាត់លះបង់មួយជីវិតរបស់គាត់ ខ្ញុំស្គាល់ច្បាស់ណាស់ លោកប្រធានស្គាល់ គឺថាព្រះបីអង្គ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ។ ព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ, ព្រះធម៌ ព្រះសង្ឃ ទៅបាត់ហើយ នៅតែព្រះពុទ្ធ ឥឡូវព្រះពុទ្ធនៅអង្គុយហ្នឹង ឃើញទេ។ ដូច្នោះខ្ញុំឃើញថា ខ្ញុំសូមចប់ប៉ុណ្ណឹងបាទ អត់ទោសបាទ។

[១៥:៤៧:២៦]

**ស៖** សូមអរគុណលោកសាក្សី។ សូមឲ្យលោកឆ្លើយឲ្យបានច្បាស់ ហើយឲ្យខ្លីៗចំពោះសំណួររបស់ខ្ញុំ។ ខ្ញុំដឹងថាលោកត្រូវការនិយាយ លោកបាននិយាយអំពីមិត្តភក្តិបីដែលស្មោះត្រង់ ហើយលោកប្រាប់ឈ្មោះនៅក្នុងឯកសាររបស់លោកគឺ ខៀវ ជិនលៀង, អ៊ិន សូផន ហើយនិង អ៊ិន ចំរើន។

**ឆ៖** បាទ ហ៊ិន ចំរើន គាត់ជាវិស្វករខាងសាធារណការនៅប្រទេសបារាំងបាទ។

**ប្រធានអង្គជំនុំ៖**

សូមៗលោកតំណាងសហព្រះរាជអាជ្ញាបញ្ជាក់ឈ្មោះឲ្យបានច្បាស់ ព្រោះគាត់កែតម្រូវឡើងវិញ។ ពីព្រោះឈ្មោះហ្នឹងគឺ ហ៊ិន ទេ មិនមែន ស៊ិន ទេ ហើយសូមតាំងសំណួរឲ្យបានជាក់ច្បាស់ ដើម្បីសាក្សីនឹងអាចឆ្លើយចំទៅនឹងគោលបំណងនៃការមានបំណងសួរគាត់។ សូមអញ្ជើញ!

**លោក វាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ឯកសារនេះគឺលេខ D147 ឬក៏ E3/101 នៅទំព័រទី៤ ជាភាសាខ្មែរ 00290437, ភាសាអង់គ្លេស 00290443។ ខ្ញុំសូមអានឯកសារនេះ ហើយសូមឲ្យលោកសាក្សីឆ្លើយបញ្ជាក់ ហើយគឺសូមអនុញ្ញាតផ្តល់ឯកសារជូនគាត់។ សូមបញ្ជាក់ម្តងទៀត គឺលេខជាភាសាខ្មែរនោះគឺ 00290437 ដូច្នេះខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងនូវសម្រង់នៃឯកសារនេះនៅលើអេក្រង់។

[១៥:៤៩:៤០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីដើម្បីពិនិត្យ។

**សួរដោយលោក វាំងសង់ វ៉ាយដ៏ ដេស្មាឯល៖**

**ស៖** នេះគឺជាឃ្លាមួយ ដែលនិយាយអំពីការវិលត្រឡប់មកវិញ របស់បញ្ញាជនទាំងឡាយ។ ខ្ញុំសូមអានឃ្លានេះ គេនិយាយអំពីបញ្ញាជនវិលត្រឡប់ចូលប្រទេសវិញ។ សំណួរសួរថា "តើគេប្រើវិធីសាស្ត្រអ្វីដើម្បីឲ្យត្រឡប់មកវិញ?" ចម្លើយ "ខ្ញុំនៅចាំដូចជា ឧទាហរណ៍នៅខែកញ្ញា ឆ្នាំ៧៥ នាឱកាសនៃការធ្វើដំណើរទៅអង្គការសហប្រជាជាតិ នៃគណៈប្រតិភូដែលមានខ្ញុំមួយរូបដែរនោះ ពួកយើងបានឈប់នៅប៉ារីស ហើយមានកិច្ច -- មានរៀបចំកិច្ចប្រជុំមួយដើម្បីជំរុញឲ្យបញ្ញាជនទាំងឡាយវិលត្រឡប់ចូលមកប្រទេសវិញ។ នាពេលនោះ មានមិត្តភក្តិខ្ញុំមួយចំនួនដែលគេហៅថា បញ្ញាជនចម្រើន ដូចជា

ទៀវជិនឡេង, អ៊ិន សូផាន់ និងហ៊ិន ចំរើន។ ពួកគេបានវិលត្រឡប់មកកម្ពុជាវិញ ហើយក្រោយមកបានបាត់ខ្លួនទាំងអស់។ ខ្ញុំបានឃើញឈ្មោះរបស់ពួកគេនៅទួលស្លែងកាលពីឆ្នាំមុន ហើយខ្ញុំមានការរន្ធត់យ៉ាងខ្លាំង ហើយខ្ញុំនឹងតាំងចិត្តថា នឹងរៀបរាប់ពីប្រវត្តិរបស់ពួកគេ ហើយនេះក៏ជាមូលហេតុចម្បងដែលធ្វើឱ្យខ្ញុំសហការជាមួយតុលាការនេះផងដែរ”។ ខ្ញុំចង់ដឹងច្បាស់ថា តើអ្នកទាំងបីដែលលោកបានឆ្លើយនេះ គឺថាមែនទេនៅក្នុងឯកសារមួយនេះ?

[១៥:៥១:៣៨]

**ឆ៖** បាទ មែនបាទ ក៏ប៉ុន្តែដែលខ្ញុំនិយាយពីឈ្មោះដែលនៅទួលស្លែង គឺមិនមែនអ្នកហ្នឹងទេ គឺថែមលើអ្នកហ្នឹងទៀត គឺមិត្តភក្តិដែលខ្ញុំបានស្គាល់ បានរាប់អាននៅពេលដែលខ្ញុំរៀននៅអនុវិទ្យាល័យព្រះសីហនុ នៅកំពង់ចាម ហើយមានពីររូបជាបងប្អូនគ្នា ហើយគាត់ជាជនជាតិឡាវ គាត់នៅប៉ាក់សេ អង្កាល់ហ្នឹងនិស្សិត អ៊ូកូនសិស្សឡាវ នៅៗប៉ាក់សេៗ នៅខាងត្បូងប្រទេសឡាវសព្វថ្ងៃហ្នឹងគឺថា មករៀនអត់មាន អង្កាល់នុ៎ងអត់មានវិទ្យាល័យ អនុវិទ្យាល័យទេ លាវ មករៀនស្រុកខ្មែរ រៀននៅកំពង់ចាម ហើយខ្ញុំឃើញឈ្មោះ បួន, ប្រាំ, ប្រាំមួយនាក់ទៀត ធ្វើឱ្យខ្ញុំរន្ធត់ នេះគឺថាធ្វើឱ្យខ្ញុំចង់ -- ប៉ុន្តែបន្ថែមពីលើឈ្មោះ គឺថា ជា ជិនឡេង គាត់ជាអតីតប្រធានកំពង់ផែកំពង់សោម កំពង់ផែទីក្រុងព្រះសីហនុសព្វថ្ងៃហ្នឹង នៅពេលសង្គមរាស្ត្រនិយមគាត់បានទៅប្រទេសបារាំង គាត់ៗប្រពន្ធគាត់ជាជនជាតិបារាំង គាត់មានកូនមួយ ហើយគាត់សុខចិត្តលះបង់កូនគាត់ និងប្រពន្ធគាត់ដើម្បីចូលមក គឺថារួមចំណែកកសាងប្រទេសវិញ។

[១៥:៥៣:០៣]

គាត់ជាពួកម៉ាកជិតស្និទ្ធរបស់លោក អៀង សារី ក៏ដូចរបស់ខ្ញុំដែរ។ អ៊ិន សុផាន់ ជាវិស្វករខាងគេហៅថា *លេកូហ្សង់ត្រាល់ ដឺហ្សាយ ម៉ានីហ្វាក់ទ័រ* នៅទីក្រុងប៉ារីស។ គាត់ជាប្អូនបង្កើតរបស់ អ៊ិន សុកាន។ អ៊ិន ចំរើន ដូច្នោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកសហព្រះរាជអាជ្ញាបន្តការតាំងសំណួរ!

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាងលេ៖**

**ស៖** ខ្ញុំបានឃើញមានការលើកឈ្មោះមួយចំនួនហើយពាក់ព័ន្ធទៅនឹងចំណុចនេះ។ ខ្ញុំសូមចូលទៅចំណុចផ្សេងទៀត។ អម្បាញ់មិញនេះ គឺនិយាយអំពីចំនួនឯកសារឆ្លើយដាក់ ដើម្បីអាចចាប់ខ្លួនបាន

ហើយលោកបាននិយាយអំពីចម្លើយសារភាពរបស់ តូច ខាំឌឿន។ នៅពេលដែលលោកនិយាយអំពីឯកសារនេះ គឺលោកនិយាយអំពីការចោទប្រកាន់នៅក្នុងចម្លើយសារភាព របស់បុគ្គលដែលបានចាប់ខ្លួនកាលពីមុនមែនទេ? លោកចង់សំដៅអ៊ីចឹងមែនទេ?

[១៥:៥៤:៣៧]

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទៗ។

**ស៖** លោកក៏បាននិយាយផងដែរ ថាលោកខ្លួនឯងផ្ទាល់ហ្នឹងក៏ត្រូវបានគេឆ្លើយដាក់ គឺគេចោទប្រកាន់នៅក្នុងឯកសារមួយចំនួន ហើយមានបួនដងកន្លះដែលគេឆ្លើយដាក់លោក។ តើលោកដឹងថា គេឆ្លើយដាក់លោកនេះតាមយ៉ាងម៉េចដែរបានលោកដឹង? ហើយលោកមានបានឃើញផ្ទាល់ទេនូវចម្លើយសារភាព ដែលគេឆ្លើយដាក់លោកនោះ?

[១៥:៥៥:១៧]

**ឆ៖** ខ្ញុំអត់បានឃើញទេបាទ ហើយខ្ញុំដឹងដោយសារមួយថ្ងៃនោះ ខ្ញុំចាំបាននៅឆ្នាំ១៩៧៧ ចំពោះខែខ្ញុំមិនបានចាំទេ លោក អៀង សារី បានហៅខ្ញុំទៅក្នុងការិយាល័យគាត់ នៅក្រសួងការបរទេសហ្នឹង ហើយគាត់បានប្រាប់ខ្ញុំថា នៅក្នុងចម្លើយសារភាពរបស់លោក រស់ សារិន។ លោក រស់ សារិន នេះគាត់ក៏ជាចាងហ្វាងអាកាសចរណ៍ស៊ីវិលកម្ពុជា គឺថា រ៉ូយ៉ាល់អ៊ែកាំបូដ នៅពេលនោះ ហើយគាត់ជាមិត្តភក្តិរបស់ខ្ញុំពីអនុវិទ្យាល័យព្រះស៊ីសុវត្ថិ ក៏ជាមិត្ត -- គាត់ក៏ជាមិត្តភ័ក្តរបស់លោក គាត ឈន់ ដែរ។ លោក រស់ សារិន ក្នុងចម្លើយសារភាពរបស់គាត់ ព្រោះគេចោទគាត់ថាជាប្រធាន អ៊ំ ជាភ្នាក់ងារ សេ.អ៊ី.អា គាត់ថា លោក គាត ឈន់ ហើយនិងខ្ញុំ ក៏ជាភ្នាក់ងារ សេ.អ៊ី.អា ដែរ។ ដូច្នោះហើយ លោក អៀង សារី គាត់ហៅខ្ញុំទៅសួរពីបញ្ហានេះ។ ហើយខ្ញុំសូមបញ្ជាក់មួយទៀត កាលៈទេសៈអនុគ្រោះដល់ខ្ញុំច្រើនបានខ្ញុំមិនត្រូវចាប់ខ្លួន។ ខ្ញុំចាំបានថា នៅឆ្នាំ១៩៧១ ពេលនោះខ្ញុំត្រូវទៅប្រទេសអាល់ហ្សេរី ជាមួយនឹងលោក ចាន់ យូរ៉ាន់ ដើម្បីប្រជុំសន្និសីទរបស់ -- ក្នុងឋានៈជាតំណាងរបស់រណសិរ្សរួបរួមជាតិកម្ពុជាក្នុងសន្និសីទរបស់ពួកអ្នកកាសែតៗប្រជាធិបតេយ្យ ដែលជាអង្គការមហាជនរបស់ចលនាកុម្មុយនីស្តនៅពេលនោះ ហើយខ្ញុំឆ្លងកាត់ទីក្រុងប៉ារីស។

[១៥:៥៧:១៩]

ពេលនោះលោក រស់ សារិន គាត់ធ្វើជាតំណាងអាកាសចរណ៍ -- ជាតំណាងរបស់លោកសេនា

ប្រមុខ លន់ នល់ ព្រោះ ៧១ រដ្ឋប្រហាររំលំសម្តេច នរោត្តម សីហនុ នៅថ្ងៃទី២៣ អ៎! ថ្ងៃទី១៨ មីនា ១៩៧០ ហ្នឹងបានកើតឡើងហើយ។ ដូច្នោះ--

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញ!

សាក្សីព្យាយាមស្តាប់ចម្លើយ ស្តាប់សំណួរឲ្យបាន ហើយឆ្លើយតបកម្រិតត្រឹមសំណួរដែលសួរបានហើយ។ ឆ្លើយតបទៅនឹងបំណង នៃសំណួរដែលសួរ។ គប្បីខ្លី សមស្របទៅនឹង -- សមល្មមទៅនឹងសំណួរដែលសួរបានហើយ។

[១៥:៥៨:១៩]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** សូមទោសលោកសាក្សីដែលកាត់លោក។ យើងដឹងថា តាមពិតលោកត្រូវបានគេចោទប្រកាន់ ក៏ប៉ុន្តែលោកមិនត្រូវបានចាប់ខ្លួនទេ។ ប៉ុន្តែជាក់ស្តែងនោះ ក្រោយពេលពិភាក្សាជាមួយ អៀង សារី។ តើ អៀង សារី មានប្រាប់ឲ្យលោកធ្វើអ្វីមួយទេ ក្រោយពេលដែលមានការចោទប្រកាន់ រស់ សារិន នៅក្នុងចម្លើយសារភាពនោះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ក្រោយមកគាត់សរសេរអានេះ សរសេរប្រវត្តិរូប ជាភាសាខ្មែរនេះ ដែលខ្ញុំបានឃើញអំមិញហ្នឹង ហើយដែលមជ្ឈមណ្ឌលឯកសារកម្ពុជា គេបានច្បាប់ចម្លងនេះ ប្រវត្តិរូបបដិវត្តន៍របស់សមមិត្ត គង់។ នេះបានឯកសារនេះបាទ។

[១៥:៥៩:៣០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណ។ ប្រហែលជាសំណួរចុងក្រោយហើយលោកប្រធាន មុននឹងផ្អាកសវនាការ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** នៅក្នុងប្រវត្តិរូបសង្ខេប ដែលឯកសារលេខ D504 (ស៊ិក)។ ខ្ញុំគិតថា លោកព្យាយាមយកចិត្តទុក ដាក់ក្នុងការសរសេរ គឺចុះខែមិថុនា ឆ្នាំ៧៧។ ហើយប្រវត្តិរូបនេះគឺ ចោទថាមានអ្នកខ្លះក្បត់ អ្នកខ្លះជា មនុស្សអាក្រក់ ជាភាសាអង់គ្លេសនោះ ថា *ខនធីមថេប័ល*។ ខ្ញុំសូមលើកឡើងនូវឈ្មោះអ្នក ដែលសរសេរ នៅក្នុងប្រវត្តិរូបដែលគេចោទថា ជាជនក្បត់ ឬក៏មនុស្សចង្រៃ ដូចមានជា រស់ សារិន។ ខ្ញុំគិតថា មិនចាំបាច់ផ្តល់ ERN ទេ គ្រប់ទេ តែ ERN នៃឈ្មោះនេះ គឺ 00003478, ជាភាសាអង់គ្លេស 00816730, ជាភាសាបារាំង 00290760។ បន្ទាប់មក លោករៀបរាប់ឈ្មោះមួយចំនួនទៀត ដូចជា សេង សារ៉ាត "អេស-អ៊ី-អា-អ៊ិន-ហ្សេ អេស-អា-វេ-តេ", គុំ រ៉េត "កា-អូ-អឹម អ៊ែ-អ៊ី-តេ-អាស", ហ៊ូ នឹម, ហាក់ សៀងឡាយនី ដែលលោកបាននិយាយពីមុននេះ, កែវ មាស លោកបញ្ជាក់ថាគាត់ជាប្រធាន អា.កា.អ៊ី, សុខ ទួនផល្លា, តូច ភឿន និង តូច ខាំឌឿន ដែលលោកបានឆ្លើយពីមុនរួចមកហើយ។ ប្រសិនបើចាំបាច់ ខ្ញុំអាចប្រាប់លេខ ERN បាន ប៉ុន្តែវាត្រូវការចំណាយពេលវេលាវែង។ នៅពេលដែលសរសេរប្រវត្តិរូបតាមសំណើរបស់ អៀង សារី តើវាជាការត្រឹមត្រូវ ឬក៏ជាការធម្មតាទេ ដែលលោកប្រើប្រាស់ពាក្យបែបនេះ ដើម្បីដកខ្លួនឲ្យឆ្ងាយចេញពីបុគ្គលទាំងអស់នេះនោះ?

[១៦:០២:០៤]

**ឆ៖** អាហ្នឹងគឺបុគ្គលទាំងនោះ បក្សបានប្រកាសថា ជាភ្នាក់ងារ ស៊ី.អ៊ី.អា ក្បត់របស់បក្ស។ ដូច្នោះ គឺថាអាហ្នឹងធម្មតា យើងបញ្ជាក់អ៊ីចឹង ទុកជាយើងជឿ ឬមិនជឿ ក៏ក្នុងឋានៈជាបក្ខជន យើងចេះតែដាក់អ៊ីចឹង ណេះ អាហ្នឹងជាធម្មតាទេ។ ខ្ញុំមិនដឹងថាដាក់អ៊ីចឹងទៅ គេអាចចោទប្រកាន់ថា ខ្ញុំព្រោះគេថាៗខ្ញុំជាឱកាសនិយម។ អាហ្នឹងជាធម្មតា។ ក៏ប៉ុន្តែបើយើងមិនចាក់ដាក់វិញនែ៎ វាមានបច្ច័យយ៉ាងម៉េច? អាហ្នឹងហើយ ដែលគេហៅថា ប្រជាធិបតេយ្យខ្មែរនោះ បើចិនគាត់ថា សង្គមនិយមតាមរបៀបចិន។ ខ្ញុំថា បើថានេះនិយាយប្រាប់លោកខ្លះៗ ថាប្រជាធិបតេយ្យរបៀបខ្មែរ។ សម្លម្ជូរ សម្លកកូរក៏ដោយ ក៏ប៉ុន្តែតាមរបៀបខ្មែរ កុំកាឡៃ ឧបមាអ៊ីចឹង។ ហើយយើងស្ទីថា នៅបារាំង នៅអាមេរិក នៅសុទ្ធតែល្អទាំងអស់។

[១៦:០៣:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ បាន អរគុណៗ។ ឥឡូវ កិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសម្រាកហើយ

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី៧ ខែសីហា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន ដែលនឹងតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា ហើយនិងក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមភាគី និងសាធារណជនជ្រាប។

[១៦:០៤:១៥]

លោក សួង ស៊ីគឿន ការស្តាប់សក្ខីកម្មរបស់លោក នៅមិនទាន់ចប់នៅឡើយទេ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្ម នៅថ្ងៃស្អែកទៀត។ ហើយមេធាវីប្រឹក្សា ដូចគ្នា គឺអញ្ជើញមកប្រឹក្សាសាក្សី នៅក្នុងអំឡុងពេលដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់វិញ និងឲ្យអញ្ជើញគាត់ ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង នៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យនាំខ្លួនពួកគាត់ទាំងបីរូប ត្រឡប់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង១៦:០៥ នាទី)*